ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការចងក្រងប្រវត្តិសាស្ត្ររបស់ខ្លួន
- ស្លាកស្នាមរបួសផ្លូវចិត្តអាថ៌កំបាំងនៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤០ ខែសីហា ឆ្នាំ២០១១

# ស្វែងរកការពិត

លេខ១៤០ ខែសីហា ឆ្នាំ២០១១


## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

### មាតិកា


◆ការចងក្រងប្រវត្តិសាស្ត្ររបស់ខ្លួន ....................... ១

**ផ្នែកឯកសារ**

◆ស្លាកស្នាមរបួសផ្លូវចិត្តអាចកំបាំងនៅកម្ពុជា ....................... ២

◆រៀនប្រវត្តិសាស្ត្រដើម្បីទប់ស្កាត់ជម្លោះ និងបង្រួបបង្រួមជាតិ ....................... ៤

◆ប៉ៃលិន : ទឹកដីនៃសម្រស់ធម្មជាតិ ....................... ៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ស្វាយ បេកក្នុងសម័យសង្គ្រាម ....................... ១៣

◆អតីតជនបដិវត្តន៍ជនជាតិភាគតិចការ៉ែត ....................... ១៦

◆អតីតកុមារ ធី រៀបរាប់ពីរបបខ្មែរក្រហម ....................... ១៨

◆ស្រុកវាលវែង ពីមុន និងបច្ចុប្បន្ន ....................... ២១

**ផ្នែកច្បាប់**

◆ការវិភាគទៅលើវិធានឃុំខ្លួន ....................... ២៤

◆ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់តុលាការ ....................... ២៨

**វេទិកាពិភាក្សាសាធារណៈ**

◆ការសង្គ្រោះយកយុត្តិធម៌មកវិញក្នុងករណីជនជាប់ចោទ ....................... ៣៧

◆ការចរចាទៅលើប្រវត្តិនៃយុត្តាធិការរបស់ ....................... ៤៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រឿងរ៉ាវពិតរបស់ខ្ញុំ ....................... ៥៣




សិស្សានុសិស្សនៅខេត្តតាកែវចូលរួមវេទិកាសាធារណៈ


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្មេរលេខនេះ :** ឌី ខាំបូលី, គាឆាណា សៃណាទី, ហ្សាវ៉ន គឹម, សេី សាយ្យណា, សុខ វណ្ណៈ, ឡុង ដានី, ស៊ីហ៊ីនី វ៉ាង, ជី ទេរិទ្ធិ, អាណា មុរ៉ំហុត, ដេវីដ សេហ៊ុរ និង ឡៃ ហួត **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ :** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ :** ម៉ម សុផាត



**Email: dccam@online.com.kh, Homepage: www.dccam.org**

# ការចងក្រងប្រវត្តិសាស្ត្ររបស់ខ្លួន

អនុទូតចិន ជីវ តាក្វាន់ បានរៀបរាប់ឲ្យពិភពលោកបានដឹងអំពីរឿងរ៉ាវជីវិតរបស់គាត់នៅប្រាសាទអង្គរវត្តកាលពី៨០០ ឆ្នាំមុន ។ ចាប់តាំងពីពេលនោះមក អ្នកស្រាវជ្រាវជាច្រើនផ្សេងទៀតបានសរសេរប្រវត្តិសាស្ត្រប្រទេសរបស់យើងសម្រាប់ឲ្យយើងសិក្សា ។ អ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនបានសិក្សាស្រាវជ្រាវពីសម្បត្តិវប្បធម៌ដ៏មានតម្លៃរបស់យើង ហើយក្នុងពេលថ្មីៗនេះបានសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ ។ ប៉ុន្តែសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» បានបង្ហាញឲ្យឃើញថា នៅទីបំផុតប្រជាជនកម្ពុជាបានចាប់ផ្តើមការងារស្រាវជ្រាវនិងកត់ត្រារឿងរ៉ាវពីអតីតកាលនៃប្រទេសជាតិរបស់ខ្លួន ។ សៀវភៅប្រវត្តិសាស្ត្រនេះបង្ហាញអំពីការសិក្សាស្រាវជ្រាវនិងបង្ហាញអំពីអត្ថបទប្រវត្តិសាស្ត្របែបនេះជាលើកទីមួយដែលសរសេរដោយជនជាតិខ្មែរ ។

សម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ការសរសេរអំពីរឿងរ៉ាវប្រវត្តិសាស្ត្រនៅក្នុងសម័យកាលដ៏ខ្មៅងងឹតនេះ សម្រាប់ក្មេងជំនាន់ក្រោយ អាចជាការប្រថុយប្រថាន ទៅនឹងការរើឡើងវិញនូវស្នាមរបួសចាស់ ។ ប្រជាជនកម្ពុជាជាច្រើនព្យាយាមបំភ្លេចបទពិសោធន៍ឈឺចាប់ដែលខ្លួនបានជួបប្រទះនៅក្នុងរបបនេះ ហើយបានធ្វើដំណើរទៅមុខ ។ ប៉ុន្តែយើងមិនអាចធ្វើដំណើរទៅមុខបានទេ (ប្រសិនបើគ្មានការផ្សះផ្សាជាមួយខ្លួនឯងនិងជាមួយអ្នកដទៃ) ដរាបណាយើងមិនទាន់ប្រឈមមុខនឹងអតីតកាលដើម្បីស្វែងយល់អំពីអ្វីដែលបានកើតឡើងនិងមូលហេតុ ដែលនាំឲ្យកើតមានរឿងរ៉ាវបែបនោះ ។ លុះត្រាណាយើងស្វែងយល់អំពីប្រវត្តិពីអតីតកាលឲ្យបានច្បាស់ ទើបយើងអាចចាប់ផ្តើមដំណើរការផ្សះផ្សាពិតប្រាកដមួយបាន ។



ពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែលដាក់តាំងនៅវិទ្យាល័យបាក់ទូក

ការសរសេរសៀវភៅប្រវត្តិសាស្ត្រនេះគឺក្នុងគោលបំណងបម្រើឲ្យការសិក្សារបស់សិស្សថ្នាក់វិទ្យាល័យ ។ ទោះជាយ៉ាងនេះក្តី សៀវភៅនេះក៏អាចឲ្យមនុស្សពេញវ័យសិក្សាស្វែងយល់បានដែរ ។ យើងទាំងអស់គ្នាអាចរៀនសូត្រពីប្រវត្តិសាស្ត្ររបស់យើង ។ ដោយប្រឈមមុខនឹងសម័យកាលដ៏ខ្មៅងងឹតនេះ យើងអាចធ្វើការសិក្សាអំពីព្រឹត្តិការណ៍អតីតកាលទាំងនេះ និងប្រែក្លាយប្រទេសយើងឲ្យទៅជាប្រជាជាតិមួយដែលប្រជាជនបានចូលរួមក្នុងការទប់ស្កាត់ការកើតមានឡើងនូវអំពើប្រល័យពូជសាសន៍នាពេលអនាគត ទាំងនៅក្នុងប្រទេសរបស់យើង ទាំងនៅក្នុងប្រទេសផ្សេងៗជាច្រើនទៀត ដែលកំពុងតែប្រឈមមុខទៅនឹងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ។ តាមរយៈការទទួលខុសត្រូវក្នុងការបង្ហាត់បង្រៀនកូនចៅរបស់យើងតាមរយៈអត្ថបទប្រវត្តិសាស្ត្រ ដូចជាសៀវភៅនេះកម្ពុជាអាចបោះជំហានទៅមុខ និងបណ្តុះបណ្តាលកូនខ្មែរជំនាន់ក្រោយដែលជាអ្នកធានាថាគ្រាប់ពូជនៃអំពើប្រល័យពូជសាសន៍នឹងមិនអាចចាក់ឫសនៅក្នុងប្រទេសរបស់យើងសាជាថ្មីម្តងទៀតបានទេ ។

ខ្ញុំបានជឿជាក់ថា មានតែការរៀនសូត្រអំពីប្រវត្តិសាស្ត្រប៉ុណ្ណោះ ដែលយើងអាចចាប់ផ្តើមផ្សាភ្ជាប់ឡើងវិញនូវបំណែកជាច្រើននៃសង្គមបាក់បែករបស់យើង ។ **ឆាំង យុ**

# ស្លាកស្នាមរបួសផ្លូវចិត្តអាចកំបាំងនៅកម្ពុជា ៖
# សុខភាពផ្លូវចិត្តក្រោយរបបខ្មែរក្រហម



គណៈកម្មាធិការអចិន្ត្រៃយ៍នៃរបបខ្មែរក្រហមមានបំណងធ្វើឲ្យប្រាកដថា ប្រជាជនធ្វើតាមអ្វីដែលខ្លួនចង់បាន ហើយនិងកម្ចាត់ចោលនរណាដែលមានគំនិត និងសកម្មភាពប្រឆាំងនឹងគោលនយោបាយរបស់ខ្លួនដោយដាក់សម្ពាធដល់អ្នកទាំងនោះតាមរយៈការគ្រប់គ្រងចិត្តសាស្ត្រ ។ ការរំលោភរាតត្បាតដល់សាសនា សិល្បៈ វប្បធម៌ ទំនាក់ទំនងគ្រួសារដែលធ្លាប់មានពីមុនមក ហើយនិងរចនាសម្ព័ន្ធឋានៈសង្គមរបស់ខ្មែរបានប្រឆាំងនឹងជំនឿរបស់ខ្មែរដែលបានចាក់ឫសយ៉ាងជ្រៅរួចមកហើយ ។ ខ្មែរក្រហមបានធ្វើឲ្យអស្ថិរភាពចិត្តសាស្ត្រដ៏ធំធេងដែលធ្លាប់មានភាពជាក់លាក់ពីមុនមកនៅក្នុងតថភាពទាំងអស់នោះ ។ ចិត្តសាស្ត្ររបស់កម្ពុជាបានផ្លាស់ប្តូរទៅរកភាពខ្ទេចខ្ទាំក្នុងស្ថានភាពមួយដ៏យូរអង្វែង ។ នៅក្នុងសង្គមមួយដែលធ្លាប់ជួបប្រទះនូវអំពើប្រល័យពូជសាសន៍ និងសង្គ្រាម របួសផ្លូវចិត្តបានប៉ះពាល់យ៉ាងខ្លាំងដល់ចិត្តសាស្ត្ររបស់ប្រជាជន ។ ផលប៉ះពាល់នៃអារម្មណ៍ផ្លូវចិត្តទាំងនេះមិនអាចវាស់ស្ទង់បានឡើយ ។ មានស្ថិតិដ៏ជាក់លាក់មួយដែលបញ្ជាក់អំពីជំងឺទាក់ទងអារម្មណ៍ផ្លូវចិត្តដែលមានកម្រិតខ្ពស់នៅក្នុងប្រទេសក្រោយជម្លោះ ។

សៀវភៅនេះពិចារណាទៅលើការជាប់ពាក់ព័ន្ធទៅនឹងសុខភាពផ្លូវចិត្តពីរបបខ្មែរក្រហមក្នុងចំណោមប្រជាជនកម្ពុជា ។ អ្នកជំនាញខាងសុខភាពផ្លូវចិត្តបានពិភាក្សាអំពីការកើនឡើងនៃជំងឺផ្លូវចិត្តធ្ងន់ធ្ងរ *(PTSD)* និងជំងឺធ្លាក់ទឹកចិត្ត ក្នុងចំណោមជំងឺផ្លូវចិត្តសំខាន់ៗទាំងឡាយនៅក្នុងប្រទេសកម្ពុជា ។

អ្នកជំនាញទាំងនោះក៏ពិភាក្សាអំពីសម្ពាធដ៏ធ្ងន់ធ្ងរទូទៅដែលមានកម្រិតខ្ពស់នៃជំងឺផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជាដែលជាសង្គមមួយក្រោយជម្លោះ ។ អ្នកជំនាញផ្នែកច្បាប់ពិភាក្សាអំពីអ្វីដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចជួយសម្រាលជនរងគ្រោះនិងសាក្សីអំពីការប៉ះទង្គិចជំងឺផ្លូវចិត្តដើម្បីចៀសផុតពីការប៉ះទង្គិចអារម្មណ៍ផ្លូវចិត្តជាថ្មីម្តងទៀតនិងដើម្បីធ្វើឲ្យប្រាកដថាជនរងគ្រោះនោះទទួលបានបទពិសោធន៍យុត្តិធម៌ដ៏មានអត្ថន័យមួយ ។ សៀវភៅនេះនឹងផ្តល់អនុសាសន៍ដើម្បីឲ្យមានការដោះស្រាយបញ្ហាទាក់ទងនឹងសុខភាពផ្លូវចិត្តឲ្យបានទូលំទូលាយទូទាំងប្រទេស ។

សៀវភៅនេះរៀបរាប់ពីបញ្ហាសុខភាពផ្លូវចិត្តជាបីផ្នែក ។ ផ្នែកទី១ រៀបរាប់ពីការបកស្រាយដោយអ្នកជំនាញផ្លូវចិត្តជាច្រើនរូបទាក់ទងនឹងចិត្តសាស្ត្រ និងប្រទេសកម្ពុជាដើម្បីពិចារណាទៅលើផលប៉ះពាល់លើចិត្តសាស្ត្រមនុស្សបង្កឡើងដោយជំងឺផ្លូវចិត្ត ។ ផ្នែកនេះផ្តល់នូវទិដ្ឋភាពទ្រឹស្តី និងស្ថិតិនៃផលលំបាកជំងឺផ្លូវចិត្តក្នុងកម្រិតបុគ្គលនិងសង្គម ពិនិត្យពិច័យទៅលើផលប៉ះពាល់ដល់មនុស្សជាច្រើនជំនាន់នៃរបួសផ្លូវចិត្តធ្ងន់ធ្ងរ និងបកស្រាយពីអ្វីដែលផលប៉ះពាល់ទាំងនោះបន្តប៉ះពាល់ដល់ប្រទេសជាតិ និងការអភិវឌ្ឍប្រទេស ។

ផ្នែកទី២ បកស្រាយពីកិច្ចការងាររបស់អ្នកជំនាញច្បាប់និងស្វែងរកមើលទំនាក់ទំនងរវាងការរងរបួសផ្លូវចិត្ត និងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្វីដែលពិសេសសម្រាប់ផ្នែកទី២នេះគឺឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃជំងឺផ្លូវចិត្តចំពោះកិច្ចការរបស់តុលាការចំពោះអ្នកចូលរួម សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី ហើយពិនិត្យទៅលើទស្សនៈនៃភាពយុត្តិធម៌ទាក់ទងទៅនឹងរបួសផ្លូវចិត្ត ។ មានមតិជាច្រើនបានរិះគន់ដល់ប្រតិកម្មរបស់តុលាការទៅនឹងស្ថានភាពជំងឺផ្លូវចិត្តរបស់អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម ។

ផ្នែកទី៣ ពិនិត្យទៅលើកិច្ចខំប្រឹងប្រែងជាច្រើនដែលបម្រើឲ្យមានការអន្តរាគមន៍ និងដើម្បីព្យាបាលស្ថានភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា ។ ផ្នែកនេះវាយតម្លៃពីប្រព័ន្ធសុខភាពផ្លូវចិត្តឯកជននិងផ្លូវចិត្តសាធារណៈនៅក្នុងប្រទេសកម្ពុជា ដោយទាក់ទងទៅនឹងការព្យាបាលនៃស្ថានភាពជំងឺដែលទាក់ទងនឹងរបួសផ្លូវចិត្ត ។ សៀវភៅនេះសម្រេចបានតាមរយៈការសិក្សាជាច្រើនចេញពីគំនិតរបស់អ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត និងអ្នកដែលធ្វើការទាក់ទងនឹងជំងឺផ្លូវចិត្តដែលបានតស៊ូក្នុងការដោះស្រាយនូវតម្រូវការចាំបាច់នៅក្នុងប្រព័ន្ធមួយដែលលំបាកនិងស្មុគស្មាញយ៉ាងខ្លាំង ។

សៀវភៅនេះត្រូវបានត្រួតពិនិត្យដោយ អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ដារីន រិចឈើទើ និង ឆាំង យុ ។ ប្រធានក្រុមការងារត្រួតពិនិត្យគឺ អធើម ថាល់បុត ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# រៀនប្រវត្តិសាស្ត្រដើម្បីទប់ស្កាត់ជម្លោះ និងបង្រួបបង្រួមជាតិ

ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបណ្តុះបណ្តាលដល់គ្រូមូលដ្ឋាននៅទីរួមខេត្តកំពង់ចាម អំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ អ្នកចូលរួមដែលជាគ្រូបង្រៀនប្រវត្តិសាស្ត្រចំនួន៧២នាក់មកគ្រប់ស្រុកនិងក្រុងទូទាំងខេត្តកំពង់ចាមបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ។ គ្រូថ្នាក់ជាតិចំនួនបីរូបមកពីក្រសួងអប់រំ យុវជន និងកីឡា គ្រូថ្នាក់ខេត្តចំនួនប្រាំបួនរូប និងអ្នកជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនបួនរូបគឺជាអ្នកបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមនេះ ។ ឯកសារសំខាន់ៗដែលបានចែកជូនសិក្ខាកាមរួមមាន សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទស្សនាវដ្តីស្វែងរកការ









ពិត សៀវភៅណែនាំពីករណី០០២ ឯកសារអំពីគុក និងរណ្តៅសាកសព កាលប្បវត្តិអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សៀវភៅពន្យល់ពាក្យខ្មែរក្រហម និងផែនទីរណ្តៅសាកសព ព្រមទាំងផែនទីរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ខ្សែភាពយន្តឯកសារមួយចំនួនក៏បានបញ្ចាំងសម្រាប់សិក្ខាកាមដែរ ដូចជាក្រោយជញ្ជាំងមន្ទីរស-២១ កុមារកម្ពុជា គុកនៅព្រៃវែង ភ្នំបាសិត និងគុកទួលស្លែង រណ្តៅសាកសពក្បែរវត្ត និងភាពយន្តឯកសារអំពីសកម្មភាពរបស់កម្មាភិបាលខ្មែរក្រហមនៅតំបន់រំដោះខ្មែរក្រហមក្នុងឆ្នាំ១៩៧៣ ។

វគ្គបណ្តុះបណ្តាលនេះត្រូវបានតាក់តែងឡើងដើម្បីបំប៉នការយល់ដឹងបន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធីសាស្ត្របង្រៀនអំពីរបបនេះដល់គ្រូបង្រៀនប្រវត្តិសាស្ត្រដើម្បីយកទៅបង្រៀនដល់សិស្សបន្តទៀត ។ ការបង្រៀននេះត្រូវបានរំពឹងថានឹងនាំសិស្សានុសិស្សឲ្យប្រាសចាកពីកំហឹង ការស្អប់ និងការសងសឹកចំពោះរបបខ្មែរក្រហម ។ ម្យ៉ាងវិញទៀត គ្រូបង្រៀនអាចបង្រៀនសិស្សអំពីអតីតកាលដើម្បីជាមេរៀនមួយក្នុងការកសាងប្រទេសជាតិទៅរកភាពសុខសាន្ត ។ កិច្ចខំប្រឹងប្រែងនេះនឹងរួមចំណែកទប់ស្កាត់អំពើប្រល័យពូជសាសន៍ កសាងសន្តិភាព និងការបង្រួបបង្រួមជាតិនាពេលអនាគត ។

**ឌី ខាំបូលី**









# ប៉ៃលិន : ទឹកដីនៃសម្រស់ធម្មជាតិ និងភាពឃោរឃៅពីអតីតកាល

ពេលមើលនឹងភ្នែកដំបូង ប៉ៃលិន គឺជាទីក្រុងដ៏ស្រស់ស្អាតមួយ គ្របដណ្តប់ដោយភ្នំពណ៌ខៀវខ្ចីអមទៅដោយវាលស្រែពណ៌បៃតងដ៏ស្ងប់ស្ងាត់ ល្ហឹងល្ហើយ ហ៊ុំព័ទ្ធដោយដងស្ទឹងហូរកាត់ជ្រលងភ្នំបៃតងចាំង ពន្លឺព្រិចៗនៅក្រោមពន្លឺព្រះអាទិត្យដ៏ចិញ្ចែងចិញ្ចាច ។ ទឹកដីទីក្រុងប៉ៃលិននេះធ្លាប់សម្បូរទៅដោយត្បូងដែលពេលខ្លះសូម្បីតែភ្លៀងមួយមេក៏អាចធ្វើឲ្យត្បូងទទឹម និងត្បូងកណ្តៀងផុសចេញពីដីក៏មានដែរ ។ ដោយសារតែភាពសម្បូរបែបទាំងអស់នេះហើយដែលយើងមានការពិបាកក្នុងការទទួលស្គាល់ថាទីក្រុងប៉ៃលិនគឺជាតំបន់ខ្មែរក្រហម ហើយពិបាកនឹងជឿថាភាពឃោរឃៅ និងព្រៃផ្សៃរបស់ខ្មែរក្រហមអាចកើតឡើងនៅលើទឹកដីដែលពោរពេញដោយសម្រស់ និងភាពស្ងប់ស្ងាត់ ។



ទិដ្ឋភាពមុនចូលទីរួមខេត្តប៉ៃលិន

របបហិង្សាខ្មែរក្រហមបានចាប់ផ្តើមនៅឆ្នាំ១៩៧៥ជាពេលដែលជនជាតិដើមកូឡាបានរត់ភៀសខ្លួនពីទីក្រុងប៉ៃលិនទៅរស់នៅតាមព្រំដែនថៃ ដែលនៅទីនោះមានជនជាតិកូឡារាប់ពាន់នាក់ត្រូវបានសម្លាប់រង្គាល ។ បួនឆ្នាំក្រោយមក នៅពេលដែលអំណាចរបស់ខ្មែរក្រហមបានរលាយសាបសូន្យទៅ ជនជាតិកូឡាដែលនៅរស់រានមានជីវិតបានវិលត្រឡប់មករស់នៅតាមជើងភ្នំក្រវ៉ាញ ដោយប្រឈមមុខនឹងការតទល់ប្រដាប់អាវុធរវាងយោធាខ្មែរក្រហម និងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយវៀតណាម ។

ខ្មែរក្រហមបានកាន់កាប់អំណាចនៅទីក្រុងប៉ៃលិន ក្រោយពេលដែលកងទ័ពវៀតណាមបានដកថយចេញពីទឹកដីកម្ពុជានៅឆ្នាំ១៩៨៩ ។ រយៈពេលប្រាំពីរឆ្នាំក្រោយមកទៀត ខ្មែរក្រហមបានបន្តកាន់កាប់អំណាចនៅក្នុងស្រុកនេះដោយកេងប្រវ័ញ្ចយកប្រយោជន៍ចេញពីធនធានធម្មជាតិដ៏សម្បូរបែបដើម្បីបំពេញហោប៉ៅរបស់ខ្លួន ហើយបំផុសបំផុលឲ្យមានបនស្រីពេស្យាការជួញដូរគ្រឿងញៀន និងបនល្បែងតាមព្រំដែនថៃដែលបង្កជាគ្រោះថ្នាក់ដល់ប្រជាជនរស់នៅក្នុងតំបន់នោះ ។

នៅឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាថ្មីបានផ្តល់ការលើកលែងទោសដល់ អៀង សារី ជាថ្នូរដោះដូរនឹងការចុះចូលជាមួយនឹងរដ្ឋាភិបាល ។ អៀង សារី បានទទួលយកការលើកលែងទោសនោះ ហើយចុះចូលជាមួយនឹងរដ្ឋាភិបាលរួមជាមួយនឹងអតីតខ្មែរក្រហមចំនួនមួយម៉ឺននាក់ផ្សេងទៀត ។ ជាថ្នូរដោះដូរ អៀង សារី ត្រូវបានប្រគល់អំណាចឲ្យគ្រប់គ្រងតំបន់ប៉ៃលិនដែលជាតំបន់សេដ្ឋកិច្ចឯករាជ្យពិសេស ។ ដូច្នេះក្រោយពេលដែលខ្មែរក្រហមបានបែកបាក់ជាស្ថានពរនោះមេដឹកនាំខ្មែរក្រហមនៅតែមានអំណាចដដែល ។ ជាក់ស្តែង អ៊ី ឈាន ដែលជាអតីតកងការពាររបស់ ប៉ុល ពត បានក្លាយជាអភិបាលក្រុងប៉ៃលិន ។ ចំណែកឯកូនប្រុសរបស់ អៀង សារី ឈ្មោះ អៀង វុធ ត្រូវបានតែងតាំងជាអភិបាលក្រុងរង ។ ដោយមិនប្រឈមមុខនឹងបញ្ហាអ្វីសោះ អតីតខ្មែរក្រហមរាប់ពាន់នាក់បានចុះចូលជាមួយនឹងកងយោធពលខេមរភូមិន្ទ ។

យ៉ាងណាមិញ អំឡុងពេលដែលខ្មែរក្រហមធ្វើការគ្រប់


ស្ថានសន្តិភាពនៅទីរួមខេត្តប៉ៃលិន

ក្រុងតំបន់នេះបានបង្កជាប្រព័ន្ធសង្គមដ៏ស្មុគស្មាញមួយ នៅក្នុងទីក្រុងប៉ៃលិននេះ ។ ខ្មែរក្រហមដែលចុះចូលជាមួយនឹងរដ្ឋាភិបាលរាប់រយពាន់នាក់ កំពុងរស់នៅទីក្រុងជាមួយនឹងជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលទើបតែចូលមករស់នៅតំបន់នេះវិញដើម្បីស្វែងរកជីវភាពរស់នៅល្អប្រសើរជាងនេះ ។ ស្ថានភាពបែបនេះបង្កជាកត្តាប្រឈមមុខថ្មីមួយសម្រាប់អ្នកអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៖ ពាក់កណ្តាលនៃចំនួនសិស្សានុសិស្សទាំងអស់គឺជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមដែលត្រូវបានធំដឹងក្តីឡើងដោយជឿថារបបខ្មែរក្រហមបានបម្រើប្រយោជន៍ជាតិ ។ ប៉ុន្តែក្មេងៗជំនាន់ក្រោយទាំងអស់នេះមិនអាចបដិសេធមិនទទួលស្គាល់អំពើសាហាវឃោរឃៅរបស់របបខ្មែរក្រហមតទៅបានទេ ពីព្រោះថាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានក្លាយជាកម្មវិធីសិក្សាជាតិ និងជាផ្នែកមួយនៃការផ្សះផ្សាជាតិ ។ ជាលទ្ធផល កូនចៅរបស់អតីតកម្មាភិបាលខ្មែរក្រហមត្រូវតែផ្សះផ្សាទៅតាមការពិតត្រឹមត្រូវដែលឪពុកម្តាយនិងសាច់ញាតិបានចែករំលែកឲ្យដោយដើរឲ្យស្របទៅតាមគោលការណ៍របស់ក្រសួងអប់រំ ។ ហេតុដូច្នេះ គ្រូបង្រៀនត្រូវតែជួយក្មេងៗទាំងអស់នេះឲ្យសិក្សាស្វែងយល់កាន់តែច្បាស់ពីរឿងរ៉ាវវិវាទនៃប្រវត្តិសាស្ត្រខ្មែរក្រហមនេះ ។

### វេទិកាអប់រំសាធារណៈ

យើងបានធ្វើដំណើរមកទីក្រុងប៉ៃលិនតាមរយៈគម្រោងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីជួយសម្របសម្រួលដល់អ្នកអប់រំក្នុងការដោះស្រាយកត្តាប្រឈមមុខមួយចំនួនដែលកើតមាននៅក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ។ ក្រុមការងាររបស់យើងបានរៀបចំវេទិកាអប់រំសាធារណៈមួយនៅក្នុងបរិវេណវត្តសាមគ្គីគីរីសំរិទ្ធ ដែលត្រូវបានប្រជាជនហៅថាវត្តសាលាក្រៅថ្មី ដោយមានការចូលរួមពីអ្នកភូមិចំនួនសាមសិបនាក់ គ្រូបង្រៀនចំនួនដប់ប្រាំនាក់ សិស្សានុសិស្សថ្នាក់បឋមសិក្សា មធ្យមសិក្សា និងវិទ្យាល័យ និងព្រះសង្ឃផងដែរ ។ ក្រុមការងាររបស់យើង


សិស្សានុសិស្សកំពុងនាំគ្នាដើរចូលក្នុងទីកន្លែងប្រារព្ធវេទិកាសាធារណៈ

បានចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួនពីររយក្បាល ទស្សនាវដ្ដីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនពីររយច្បាប់ដល់អ្នកចូលរួមទាំងអស់ ហើយបានដឹកនាំឲ្យមានការពិភាក្សាជាក្រុមពីប្រធានបទដែលមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

គោលបំណងនៃការរៀបចំវេទិកាអប់រំសាធារណៈនេះឡើងគឺមានភាពសាមញ្ញបំផុត ប៉ុន្តែវាពិតជាមានសារសំខាន់បំផុត បើយើងផ្ដោតមកវិភាគពីប្រវត្តិរបស់ទីក្រុងប៉ៃលិននេះ ។ គោលបំណងនៃវេទិកាអប់រំនេះរួមមាន ៖ ដើម្បីជំរុញឲ្យមានការចែករំលែកបទពិសោធន៍រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងជំនាន់ក្រោយ ដើម្បីចងក្រងរឿងរ៉ាវពីអ្នករស់រានមានជីវិត ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមក្នុងករណីដែលអ្នកទាំងអស់នេះអាចភ្លេចរឿងរ៉ាវរបស់ខ្លួន និងដើម្បីបង្ហាញគ្រូបង្រៀន និងសិស្សានុសិស្សពីវិធីសាស្ត្រនៃការផ្សារភ្ជាប់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងបទពិសោធន៍ផ្ទាល់របស់ឪពុកម្ដាយ ជីដូនជីតា និងអ្នកភូមិចាស់ៗ ។

ក្រុមការងាររបស់យើងបានមកដល់វត្តសាលាក្រៅ នៅម៉ោងប្រាំពីរកន្លះព្រឹកដើម្បីរៀបចំទីកន្លែងសម្រាប់សកម្មភាពអប់រំសាធារណៈនេះ ។ គួរឲ្យភ្ញាក់ផ្អើល សិស្សបឋមសិក្សាមួយក្រុមធំបានមកដល់ទីតាំង ហើយនាំគ្នាឈរជាជួរក្រោមការត្រួតពិនិត្យរបស់គ្រូបង្រៀនដើម្បីរង់ចាំកម្មវិធីចាប់ផ្ដើម ។ ចំណែកឯអ្នកភូមិ និងសិស្សមធ្យមសិក្សាបានជួយក្រាលកន្ទេល ជញ្ជូនសៀវភៅ និងទស្សនាវដ្ដី និងរៀបចំប្រព័ន្ធសម្លេងមុននឹងកម្មវិធីចាប់ផ្ដើម ។ អ្នកភូមិនិយាយរាក់ទាក់គ្នាទៅវិញទៅមក ស្របពេលដែលអ្នកទាំងអស់គ្នាកំពុងរង់ចាំចូលរួមកម្មវិធីអប់រំ ។ ស្របពេលជាមួយគ្នានោះដែរ សិស្សមធ្យមសិក្សាមួយក្រុមទៀតបានមកដល់នាំគ្នាអង្គុយចាំនៅលើម៉ូតូ និយាយលេងសើចជាមួយគ្នាទៅវិញទៅមក ។ នៅពេលដែលយើងបានរៀបចំកម្មវិធីស្រេចបាច់ហើយ សិស្សសាលាបឋមសិក្សានាំគ្នាចូលមកអង្គុយគ្រប់ៗគ្នា ។ ឃើញដូច្នេះ ក្រុមការងាររបស់គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាធិបតេយ្យដែលដឹកនាំដោយកញ្ញា សើ សាយុណា បានចាប់ផ្ដើមបើកអង្គពិធីដោយធ្វើការរៀបរាប់ពីកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងពន្យល់ពីគោលបំណងសំខាន់នៃវេទិកាអប់រំសាធារណៈនេះដល់អ្នកចូលរួមទាំងអស់ ។



សិស្សានុសិស្ស និងអ្នកភូមិកំពុងអានសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមរួមគ្នា

បន្ទាប់មកទៀត លោកមេឃុំបានមានមតិសំណេះសំណាលបន្តិចបន្តួច ។ លោកសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានមករៀបចំវេទិកាអប់រំនិយាយពីប្រវត្តិសាស្ត្រខ្មែរក្រហម និងភាពលំបាកវេទនាដែលប្រជាជនបានទទួលរងក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងប៉ៃលិននេះដោយសង្កត់ធ្ងន់ពីសារសំខាន់នៃការអប់រំដើម្បីធានាថាប្រវត្តិសាស្ត្រឈឺចាប់មិនកើតឡើងម្តងទៀត ។ លោកមេឃុំបានមានមតិបញ្ចប់ដោយអរគុណដល់សម្តេច ហ៊ុន សែន ដែលបានផ្តួលរលំរបបខ្មែរក្រហម ហើយនាំមកនូវសន្តិភាពមកឲ្យប្រទេសកម្ពុជា ។ លោកមេឃុំសូមទទួលស្គាល់តួនាទីរបស់រដ្ឋាភិបាលក្នុងការស្រោចស្រង់ឲ្យទីក្រុងប៉ៃលិនរីកចម្រើនលូតលាស់ម្តងទៀត ។

បន្ទាប់ពីមតិសំណេះសំណាលរបស់មេឃុំ កញ្ញា សាយ្យាណា បាននិយាយជាសង្ខេបពីប្រវត្តិខ្មែរក្រហម ។ សាយ្យាណា បានសួរទៅកាន់សិស្សានុសិស្សទាំងអស់ថាតើអ្នកទាំងអស់នេះជឿលើប្រវត្តិនេះដែរឬទេ ។ ក្មេងប្រុសសិស្សសាលាម្នាក់បានលើកដៃឡើង ហើយនិយាយថា «ខ្ញុំជឿលើប្រវត្តិនេះ ពីព្រោះឪពុកម្តាយខ្ញុំបាននិយាយប្រាប់ខ្ញុំថាគ្មាននរណាម្នាក់បានអាហារហូបគ្រប់គ្រាន់ទេ» ។ សាយ្យាណា ក៏បានប្រាប់ដល់សិស្សានុសិស្សទាំងអស់នោះថា នៅពេលដែលអ្នកទាំងអស់នេះចូលរៀននៅថ្នាក់មធ្យមសិក្សា សិស្សនោះនឹងទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដើម្បីសិក្សាពីប្រវត្តិសាស្ត្រនេះ ។ បន្ទាប់មកទៀត សាយ្យាណា ក៏សួរទៅកាន់អ្នកចូលរួមថាតើមាននរណាមានចម្ងល់អ្វីដែរឬទេ ។ ភ្លាមនោះ ក្មេងស្រីម្នាក់បានលើកដៃ ហើយសួរថា «ហេតុអ្វីបានជាខ្មែរសម្លាប់ខ្មែរគ្នាឯង?» សាយ្យាណា បានសំណូមពរឲ្យអ្នកភូមិចាស់ៗឆ្លើយនឹងសំណួរនេះ ។ លោកអ៊ំចាស់ម្នាក់បានឆ្លើយថា «ដើម្បីបង្កើតសង្គម និងការអភិវឌ្ឍថ្មីខ្មែរក្រហមសម្លាប់ខ្មែរគ្នាឯង» ។ មានគ្រូបង្រៀនម្នាក់ និងអ្នកភូមិម្នាក់ទៀតក៏បានឆ្លើយតបនឹងសំណួរនេះដោយនិយាយថា «ខ្មែរក្រហមចង់អភិវឌ្ឍប្រទេសតាមគោលការណ៍ថ្មី» ។

មុននឹងអនុញ្ញាតឲ្យសិស្សសាលាបឋមសិក្សាចាកចេញ យើងបានចែកទស្សនាវដ្តីស្វែងរកការពិត និងផ្ទាំងពាក្យស្លោកដល់អ្នកទាំងអស់គ្នានោះ ។ នៅពេលដែលសិស្សសាលាបឋមសិក្សាបាននាំគ្នាចាកចេញអស់ហើយ សិស្សសាលាមធ្យមសិក្សា និងវិទ្យាល័យ អ្នកភូមិ និងគ្រូបង្រៀនបាននាំគ្នាបើក និងអានទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងអស់បាននាំគ្នាអង្គុយជាក្រុម ចង្អុលទៅលើរូបភាពដែលមាននៅក្នុងសៀវភៅ និងចែករំលែកខ្លឹមសារអត្ថបទរវាងគ្នាទៅវិញទៅមក ។ មានគ្រូបង្រៀនម្នាក់ដែលកំពុងតែមើលសៀវភៅបានសួរថា «តើរូបភាពនេះគឺជារូបភាពពិតមែនដែរឬទេ?» គាត់សួរសំដៅទៅលើរូបភាពមួយដែលបង្ហាញពីប្រជាជនកសិករនាំគ្នាសាងសង់ប្រឡាយ១មករា ។ សាយ្យាណា បានឆ្លើយថា «រូបភាពនេះគឺជារូបភាពពិត» ។ លោកគ្រូម្នាក់នោះក៏បាននិយាយថា «ខ្ញុំក៏ជាអ្នកជីកប្រឡាយនៅទីនោះដែរ» ហើយបានរៀបរាប់បន្ថែមទៀតថា «យើងគ្រប់គ្នាគ្មានអាហារហូបគ្រប់គ្រាន់ទេ ហើយធ្វើការឥតឈប់ឈរ ។ ប្រសិនបើខែភ្ជុំផង យើងត្រូវធ្វើការរហូតដល់ម៉ោងបួនភ្លឺដោយទទួលបានតែបបរាវមួយចានតែប៉ុណ្ណោះ» ។ យើងក៏បានកត់ឈ្មោះលោកគ្រូម្នាក់នេះទុក


សិស្សានុសិស្សកំពុងត្រងត្រាប់ស្តាប់វេទិកាសាធារណៈ

ហើយសូមសម្ភាសពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់រស់នៅក្រោមរបបខ្មែរក្រហម ។

មុននឹងបែងចែកក្រុមដល់អ្នកចូលរួមទាំងអស់ជាក្រុមពិភាក្សាតូចៗ ក្រុមការងារយើងបានចែកមតិស្ទាបស្ទង់មុនវេទិកាអប់រំសាធារណៈចាប់ផ្តើម ដើម្បីស្វែងយល់ពីចំណាប់អារម្មណ៍របស់អ្នកចូលរួមក្នុងការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការយល់ឃើញរបស់សហគមន៍ទាំងមូលស្តីពីរបបខ្មែរក្រហម ។ នៅពេលដែលអ្នកចូលរួមបានបំពេញមតិស្ទាបស្ទង់នេះចប់ ក្រុមការងារយើងបានបែងចែកអ្នកចូលរួមជាបីក្រុមធំៗ ដោយក្រុមនីមួយៗអានផ្នែកផ្សេងៗនៃជំពូកទីប្រាំពីរនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ យើងបានលើកទឹកចិត្តឲ្យអ្នកចូលរួមទាំងអស់អានផ្នែកនីមួយៗនៃក្រុមរបស់ខ្លួន ហើយជ្រើសរើសអ្នកតំណាងម្នាក់ឡើងធ្វើបទបង្ហាញពីខ្លឹមសារសំខាន់ៗ ។

ផ្នែកទីមួយនៃជំពូកនេះនិយាយពីស្ថានភាពរស់នៅលំបាកលំបិននៅក្រោមរបបខ្មែរក្រហម ។ គួរឲ្យចាប់អារម្មណ៍ អ្នកតំណាងក្រុមទីមួយមិនត្រឹមតែបានរៀបរាប់ពីព្រឹត្តិការណ៍ និងស្ថានភាពជាក់ស្តែងនៃជីវភាពរស់នៅក្នុងអំឡុងពេលនោះទេ ថែមទាំងលើកនេះក៏បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ដែលត្រូវបានបង្ខំឲ្យធ្វើការទាំងថ្ងៃទាំងយប់ដោយគ្មានរបបអាហារហូបគ្រប់គ្រាន់ ហើយរស់នៅដោយភាពភ័យខ្លាច ។ គាត់ក៏សូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ការរៀបចំកម្មវិធីនេះនៅទីក្រុងប៉ៃលិនដោយចែកជូននូវសៀវភៅប្រវត្តិសាស្ត្រ និងផ្តល់ជាវេទិកាមួយសម្រាប់ឲ្យគាត់បានចែករំលែកបទពិសោធន៍របស់គាត់ទៅកាន់ក្មេងៗជំនាន់ក្រោយ ។

ចំណែកឯផ្នែកទីពីរនៃជំពូកនេះនិយាយពីគោលការណ៍រៀបការដោយបង្ខំរបស់ខ្មែរក្រហម ។ ស្ត្រី និងបុរសដែលមិនបានស្រឡាញ់គ្នាត្រូវបានបង្ខំឲ្យរស់នៅជាមួយគ្នាក្នុងទិដ្ឋភាពប្រែក្លាយការរៀបការដែលកើតចេញពីសេចក្តីស្រឡាញ់ស្មោះស្ម័គ្ររបស់បុគ្គលឲ្យទៅជាស្ថាប័នមួយដែលបម្រើតែប្រយោជន៍របស់រដ្ឋ ។

ក្រុមចុងក្រោយគេបានបកស្រាយពីមូលហេតុនៃការអនុវត្តគោលការណ៍សមូហភាព និងការធ្វើពលិកម្មជាសហករណ៍ដែលគោលការណ៍នេះគឺជាមធ្យោបាយមួយប្រើប្រាស់ដើម្បីកម្ចាត់កម្មសិទ្ធិបុគ្គល ហើយប្រែក្លាយមនុស្សមកជាម៉ាស៊ីន ។

ក្រោយពីការឡើងធ្វើបទបង្ហាញរបស់អ្នកចូលរួម សាយ្យាណា បានសួរថាតើមានអ្នកចូលរួមណាម្នាក់មានចម្ងល់អ្វីចង់សួរដែរឬទេ ។ ក្រោយពីគ្មានសំណួរ សាយ្យាណា សូមអរគុណដល់អ្នកចូលរួមទាំងអស់ ហើយបានចែកជូនការស្ទាបស្ទង់មតិក្រោយពីវេទិកាអប់រំនេះបានបញ្ចប់ផុតទៅ ។ អាហារថ្ងៃត្រង់ និងនំចំណីបានរៀបចំឲ្យអ្នកចូលរួមទាំងអស់ ហើយអ្នកទាំងនោះបានជជែកពិភាក្សាគ្នាពីនេះពីនោះ ចំណែកអ្នកខ្លះក៏បាននាំគ្នាអាន និងបើកមើលទស្សនាវដ្តីស្វែងរកការពិត ។ ក្រោយពេលដែលអ្នកចូលរួមទាំងអស់បានបំពេញមតិស្ទាបស្ទង់ចប់សព្វគ្រប់ហើយ សិស្សានុសិស្សបាននាំគ្នាជួយមូរកន្ទេលទុក និងជញ្ជូនសៀវភៅដែលនៅសល់ដាក់ក្នុងរថយន្តរបស់ក្រុមការងារវិញ ។

ក្រោយពីបរិភោគអាហារថ្ងៃត្រង់ លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបសំណេះសំណាលជាមួយនឹងលោកមេឃុំ ចំណែកឯ សាយ្យាណា បានចំណាយ



អ្នកភូមិកំពុងសួរសំណួរទៅកាន់ សាយ្យាណា

ពេលសម្ភាសជាមួយនឹងគ្រូបង្រៀន និងសិស្សានុសិស្សមួយចំនួន។ រីឯពួកយើង (ហ្សាវ៉ែន និង តាឆាណា) បានសម្ភាសគ្រូថ្នាក់មធ្យមសិក្សាពីរនាក់ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែរ ។

**ម៉ម ឌីណា ភេទប្រុស ថ្នាក់ទី១២ កើតឆ្នាំ១៩៩៣ នៅខេត្តកំពត**

ឌីណា មានទីកន្លែងកំណើតនៅភូមិពងទឹក ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត ។ បច្ចុប្បន្ន ឌីណា កំពុងតែសិក្សានៅវិទ្យាល័យហ៊ុនសែនសាលាក្រៅ និងរស់នៅឃុំអូរអណ្តូង ស្រុកសាលាក្រៅ ។

ឌីណា ធ្លាប់បានឮប្រវត្តិខ្មែរក្រហមតាមរយៈឪពុកម្តាយ ។ ឌីណា បានបាត់បង់ជីដូនជីតា និង ពូម្នាក់នៅរបបខ្មែរក្រហម ។ ជីដូនម្នាក់របស់ ឌីណា ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារតែគាត់បានលួចអាហារដើម្បីបញ្ចុកកូនរបស់គាត់ ។ ចំណែកឯពូរបស់ ឌីណា វិញបានបាត់ខ្លួនសូន្យឈឹង ។ ឌីណា បាននិយាយថាការនិយាយពីខ្មែរក្រហមវិញធ្វើឲ្យគាត់ស្រក់ទឹកភ្នែក ពីព្រោះ វារំឭកដល់ជីដូនជីតាដែលគាត់មិនដែលបានឃើញមុខ ឬស្គាល់អ្នកទាំងពីរទាល់តែសោះ ។

យ៉ាងណាមិញ ឌីណា បានប្រាប់ក្រុមការងារថាខ្លួនចូលចិត្តនិយាយពីប្រវត្តិសាស្ត្រខ្មែរក្រហម ពីព្រោះគាត់ចង់ឲ្យអ្នកគ្រប់គ្នាដឹងថាប្រវត្តិនេះគឺជាប្រវត្តិសាស្ត្រពិតដែលបានកើតមានឡើង ហើយថា ការយល់ដឹងពីប្រវត្តិសាស្ត្រនេះជួយឲ្យអ្នកគ្រប់គ្នាគេចឲ្យផុតពីអំពើប្រល័យពូជសាសន៍កុំឲ្យវាកើតឡើងម្តងទៀត ។ ឌីណា ក៏បានរៀបរាប់ពីជំនឿរបស់ខ្លួនថា ការបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមនឹងជួយឲ្យប្រជាជនខ្មែរទាំងអស់អត់ឱនឲ្យគ្នាតាមរយៈការស្វែងយល់ពីអតីតកាលនៃរបបខ្មែរក្រហម ។ ដូច្នេះ នៅពេលដែលប្រឈមមុខនឹងបញ្ហា អ្នកទាំងអស់គ្នានឹងចេះដោះស្រាយបញ្ហាតាមនីតិវិធី ។

ឌីណា សូមកោតសរសើរចំពោះកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយល់ឃើញថាវេទិកាអប់រំបែបនេះគឺពិតជាមានសារសំខាន់ ពីព្រោះវាជួយលើកកម្ពស់ការយល់ដឹងរបស់យុវជន អ្នកភូមិ និងគ្រូបង្រៀន ។ ឌីណា ជឿថាកម្មវិធីបែបនេះមានសារសំខាន់ក្នុងការការពារអំពើប្រល័យពូជសាសន៍ ជំរុញឲ្យមានការផ្សះផ្សាជាតិ និងការយល់ដឹងពីប្រវត្តិអតីតកាលនៅក្នុងសហគមន៍ ។

សម្រាប់ ឌីណា ពាក្យ «ការផ្សះផ្សា» គឺជាមានន័យប្រហាក់ប្រហែលនឹងពាក្យរួបរួមគ្នា ។ ដូច្នេះ ការយល់ដឹងពីមូលហេតុនៃជម្លោះក៏ជាកត្តាសំខាន់សម្រាប់ការដើរឆ្ពោះទៅមុខ និងផ្សះផ្សាគ្នា ។ ឌីណា ជឿថាប្រទេសកម្ពុជានឹងមាន «សន្តិភាព» នៅពេលដែលប្រទេសកម្ពុជាទទួលបានសេចក្តីសុខក្សេមក្សាន្ត គ្មានជម្លោះ និងសង្គ្រាម ។

**សាន់ ភា ថ្នាក់ទី១២នៃវិទ្យាល័យសាលាក្រៅ កើតនៅឆ្នាំ១៩៩២**

ភា រស់នៅជាមួយនឹងជីដូនជីតានៅក្នុងឃុំសាលាក្រៅ ។



ម៉ម ឌីណា



សាន់ ភា

ភា ដឹងពីប្រវត្តិខ្មែរក្រហមតាមរយៈជីដូនជីតានិយាយប្រាប់ ។ ហើយ ភា ជឿថាខ្មែរក្រហមជាមនុស្សសាហាវឃោរឃៅ ។ ប្រជាជនកម្ពុជាភាគច្រើនអត់មានអាហារហូបគ្រប់គ្រាន់ ហើយភ័យខ្លាចខ្មែរក្រហម ។ ជីដូនជីតារបស់ ភា បានលួចលាក់ម្ហូបអាហារដែលគាត់ទាំងពីររកបានមិនឲ្យអង្គការឃើញ ។

ភា បាននិយាយថារឿងរ៉ាវដែលគាត់បានដឹងគឺតាមរយៈជីដូនជីតារបស់គាត់ដែលត្រូវបានរំឭកឡើងវិញនៅក្នុងវេទិកាអប់រំនេះ ។ ជីតារបស់ ភា រិះតែនឹងស្លាប់ នៅពេលដែលខ្មែរក្រហមបានចាប់ខ្លួនគាត់ ។ ក្នុងឱកាសចូលរួមក្នុងវេទិកាអប់រំសាធារណៈនេះ ភា បានដឹងថាប្រជាជនកម្ពុជាជាច្រើនត្រូវបានខ្មែរក្រហមសម្លាប់ ។ បើនិយាយពីសកម្មភាពដែល ភា ពេញចិត្តនៅក្នុងអំឡុងពេលវេទិកាអប់រំនេះវិញ ភា ចូលចិត្តសកម្មភាពពិភាក្សាជាក្រុម និងការចែករំលែកខ្លឹមសារនៃផ្នែកនីមួយៗរបស់ក្រុមទៅកាន់ក្រុមធំមួយផ្សេងទៀត ។

ភា ជឿជាក់ថាដើម្បីការពារអំពើប្រល័យពូជសាសន៍ ការលើកកម្ពស់ការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាមានសារសំខាន់ណាស់ ។ ការលើកកម្ពស់ការយល់ដឹងអាចធ្វើឲ្យមនុស្សគ្រប់រូបទទួលបានអនុសាសន៍វិភាគលើគោលការណ៍របស់របបដឹកនាំ ហើយប្រៀបធៀបគោលការណ៍នោះជាមួយនឹងគោលការណ៍របស់រដ្ឋាភិបាលបរទេសផ្សេងទៀត ។ ភា បាននិយាយថាអ្នកដែលចូលរួមទាំងអស់គ្នានៅទីនេះបានយល់ដឹងពីព័ត៌មានសំខាន់ៗនៃការប្រតិបត្តិនៃរបបខ្មែរក្រហម និងទទួលបានចំណេះដឹងជ្រៅពីរបបវាលពិឃាតនេះ ។

ភា មានសេចក្តីអាណិតអាសូរចំពោះប្រជាជនជំនាន់មុនដែលបានឆ្លងកាត់បទពិសោធន៍ជូរចត់ និងភាពលំបាកលំបិននៅក្រោមរបបខ្មែរក្រហម ។ ប៉ុន្តែ ភា នឹងមិនស្អប់ខ្ពើម ឬរើសអើងអតីតកូនជនដៃដល់ដែលរៀននៅក្នុងថ្នាក់មួយគ្នាទេ ។ វាមិនមែនមានន័យថា ឲ្យតែឪពុកម្តាយធ្លាប់ជាអតីតកម្មាភិបាលនោះកូនក៏ក្លាយជាជនដៃដល់ដែលនោះទេ ។ ភា បាននិយាយថាយើងទាំងអស់គ្នាគួរតែខំប្រឹងប្រែងរៀនសូត្រ ដើម្បីទប់ស្កាត់កុំឲ្យរបបបែបនេះកើតឡើង ឬបន្លាចដល់ប្រទេសកម្ពុជាទៀត ។

**គាឆាណា សៃណាធី, ហ្សារ៉ែន គីម និង សើ សាយ្យណា**



ព្រះសង្ឃកំពុងអានសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម

# ស្វាយចេកក្នុងសម័យសង្គ្រាម

ទោះបីជាកងទ័ពវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានផ្តួលរំលំរដ្ឋាភិបាលខ្មែរក្រហមចេញពីក្រុងភ្នំពេញទៅហើយក៏ដោយ ក៏អតីតយោធាខ្មែរក្រហម និងប្រជាជនស៊ីវិលមួយចំនួនមិនទុកចិត្តនឹងរបបថ្មីនេះដែរ ហើយបានប្រមូលផ្តុំគ្នាតាមបណ្តោយព្រំដែនខ្មែរ-ថៃ ភាគខាងលិចដើម្បីបង្កើតចលនាតស៊ូម្តងទៀត ។ ក្នុងចំណោមតំបន់ទាំងនោះ ក៏មានស្រុកស្វាយចេក (អតីតស្រុកថ្មពួក) ដែលជាតំបន់ប្រទាញប្រទង់មួយរវាងរដ្ឋាភិបាលកម្ពុជា និងចលនាឧទ្ទាមមិនមែនកុម្មុយនីស្ត ។

**ឈុំ ភួត** អាយុ៥៣ឆ្នាំ កើតនៅឃុំផ្កាំ ស្រុកស្វាយចេក ភួតរៀននៅសាលាបឋមសិក្សាផ្កាំបានត្រឹមថ្នាក់ទី៨សង្គមចាស់ក៏ឈប់រៀន ។ ក្រោយមក នៅខែមីនា ឆ្នាំ១៩៧៥ ភួត បានចូលបម្រើយោធាខ្មែរក្រហម ។ អង្គការបានចាត់តាំងគាត់ឲ្យទៅប្រចាំការនៅប្រាសាទតាមាន់ក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានផ្លាស់ ភួត ឲ្យទៅការពារព្រំដែនខាងលិចក្នុងស្រុកសំឡូត និងនៅចក្រីខេត្តបាត់ដំបង ។

នៅទីនោះ ភួត បានដឹងថាមានប្រជាជនខ្មែរជាច្រើនបានរត់ឆ្លងដែនចូលទៅប្រទេសថៃដើម្បីគេចពីការអត់ឃ្លាន និងការងារធ្ងន់ធ្ងរ ប៉ុន្តែអ្នកខ្លះត្រូវយោធាខ្មែរក្រហមប្រចាំការនៅព្រំដែនចាប់ខ្លួនបាន រួចបញ្ជូនត្រឡប់មកវិញ ។ ភួត មិនដឹងថាអ្នករត់ឆ្លងដែនទាំងនោះត្រូវទទួលទោសយ៉ាងណាទេ រហូតដល់ក្រោយមកទើបគាត់ដឹងថា ខ្មែរក្រហមបានយកអ្នកទាំងនោះទៅសម្លាប់ចោលទាំងអស់ ។

នៅឆ្នាំ១៩៧៧-១៩៧៨ នៅពេលដែលកម្មាភិបាលមកពីភូមិភាគនិរតីចូលមកគ្រប់គ្រង ក៏មានការចាប់ខ្លួនកម្មាភិបាលចាប់ពីប្រធានកងពលរហូតដល់កម្មាភិបាលថ្នាក់តូចនៅភូមិភាគពាយព្យ ។ ភួត មិនត្រូវបានចាប់ខ្លួនទេ តែគាត់និងយុទ្ធជនឯទៀតត្រូវបានបញ្ជូនឲ្យទៅច្បាំងជាមួយទាហានវៀតណាម ។ នៅឆ្នាំ១៩៧៩ ភួត និងយោធាខ្មែរក្រហមដែលបាក់ទ័ពរួមជាមួយនឹងប្រជាជនជាច្រើនបាននាំគ្នារត់ភៀសខ្លួនទៅព្រំដែនខ្មែរ-ថៃ ។ នៅតាមផ្លូវ ភួត ឃើញក្មេងនៅបៅដោះម្តាយដែលស្លាប់ទៅហើយ និងមនុស្សស្លាប់ជាច្រើននាក់ទៀត ។

នៅឆ្នាំ១៩៨០ ភួត បានចូលធ្វើជាយោធាខ្មែរក្រហមម្តងទៀតនៅអន្លង់វែងគ្រប់គ្រងដោយ តាម៉ុក ។ ប៉ុន្តែ ដោយសារ


ឈុំ ភួត

ភួត សង្កេតឃើញថាក្នុងកងរបស់គាត់មិនទុកចិត្តគ្នា និងឈ្លោះប្រកែកគ្នា គាត់ក៏សម្រេចចិត្តមកចូលបម្រើកងទ័ពរបស់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នៅស្រុកថ្មពួក និងស្វាយចេកវិញ ។

ភួត បានច្បាំងទល់នឹងកងទ័ពវៀតណាមដែលចល័តចូលតំបន់របស់គាត់ ។ ការប្រយុទ្ធនេះមិនមែនត្រឹមតែបណ្តាលឲ្យភាគីទាំងសងខាងស្លាប់នោះទេ ប៉ុន្តែក៏បណ្តាលឲ្យប្រជាជនដែលរស់នៅតំបន់ស្វាយចេកស្លាប់ និងខូចខាតផ្ទះសម្បែងអស់រាប់សិបខ្នងទៀត ។

**ម៉ៅ សារុន** អាយុ៥៩ឆ្នាំ កើតនៅឃុំបន្ទាយឆ្មារ ដូច ភួត ដែរ សារុន បានរៀនត្រឹមថ្នាក់ទី៩ (សង្គមចាស់) នៅសាលាបឋមសិក្សាបន្ទាយឆ្មារខាងជើង ។ នៅជំនាន់ខ្មែរក្រហម សារុន

បានចូលធ្វើការនៅកងចល័តឃុំ ។ រហូតដល់ឆ្នាំ១៩៧៦ អង្គការបានរៀបចំពិធីរៀបការចំនួន៧៩គូ ហើយ សារុន បានប្តីធ្វើជាកងឈ្លបឃុំ ។

ទោះបី សារុន មានប្តីជាកងឈ្លបឃុំក៏ដោយ ក៏ជីវភាពរស់នៅជួបការលំបាកដូចជាប្រជាជនផ្សេងទៀតដែរ ។ សារុន បានដឹងព័ត៌មានតាមរយៈប្តីរបស់គាត់ថា អង្គការបានសម្លាប់ប្រជាជនថ្មីមកពីភ្នំពេញអស់រាប់ពាន់នាក់ ព្រោះប្តីរបស់គាត់តែងតែទទួលបញ្ជាឲ្យចាប់ខ្លួនអ្នកទាំងនោះ ។ សារុន ក៏បានដឹងដែរថា កុមារតូចៗចំនួនប្រហែលជា៤០នាក់ដែលអង្គការយកទៅដាក់ក្នុងមណ្ឌលកុមារឲ្យយាយៗមើលថែទាំនៅរស់តែកូនរបស់គាត់ម្នាក់ប៉ុណ្ណោះ ក្រៅពីនោះបានស្លាប់ដោយសារតែគ្មានអាហារហូបគ្រប់គ្រាន់និងជំងឺ ។ ចំណែកឪពុកម្តាយខ្លះមិនបានដឹងដំណឹងពីកូនរបស់ខ្លួនទេ ព្រោះត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការងារធ្ងន់ធ្ងរនៅតំបន់ឆ្ងាយៗ ។ ហេតុដូច្នេះហើយបានជាមានប្រជាជនថ្មីជាច្រើនមានបំណងរត់ទៅប្រទេសថៃ ទោះបីជាដឹងថា មានសំណាងតិចតួចដើម្បីរួចរស់ជីវិតក៏ដោយ ។

នៅដើមឆ្នាំ១៩៧៨ កម្មាភិបាលភូមិភាគនិរតីបានចូលមកគ្រប់គ្រងតំបន់៥ បន្ទាប់មកបានចាប់គណៈភូមិភាគ គណៈតំបន់រហូតដល់ថ្នាក់ក្រោមៗមួយចំនួនទៀតដោយចោទថាក្បត់អង្គការ ។ ប៉ុន្តែ សំណាងល្អ ប្តី សារុន បានដឹងសភាពការណ៍នេះ គាត់ក៏ឈប់ធ្វើជាកងឈ្លប រួចត្រឡប់មកធ្វើស្រែចម្ការនិងរស់នៅជាមួយប្រជាជនវិញ ។ កម្មាភិបាលភូមិភាគនិរតីបានជ្រើសរើសយកកងឈ្លបក្មេងៗ និងបញ្ជាឲ្យចាប់មនុស្សយកទៅសម្លាប់ចោលកាន់តែច្រើនឡើងជាពិសេសប្រជាជន១៧មេសា ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ មានប្រជាជនតិចតួចប៉ុណ្ណោះដែលបានវិលត្រឡប់ទៅស្រុកកំណើតវិញ ។

នៅឆ្នាំ១៩៧៩ សារុន រត់ទៅទល់ដែនថៃ ក្រោយមកគាត់ក៏ត្រឡប់មករស់នៅភូមិកំណើតវិញ ដោយគាត់សង្ឃឹមថាលែងមានការសម្លាប់ និងសង្គ្រាមទៀតហើយ ។ ប៉ុន្តែក្តីសង្ឃឹមទាំងនេះបាត់ទៅវិញព្រោះសង្គ្រាមបានផ្ទុះឡើងម្តងទៀតរវាងយោធាខ្មែរក្រហម ទាហានប៉ារ៉ា និងកងទ័ពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅពេលយោធាខ្មែរក្រហមនិងទាហានប៉ារ៉ាវាយចូលមកដល់ក្នុងភូមិគាត់ មានយោធាខ្លះដើរចាប់គោ ក្របី និងជំរិតទារលុយពីអ្នកភូមិ ហើយប្រសិនបើអ្នកភូមិមិនព្រមប្រគល់ឲ្យទេ គេនឹងដុតផ្ទះអ្នកភូមិចោលតែម្តង ។ សារុន និងប្រជាជនរស់នៅតាមបណ្តោយព្រំដែនបានក្លាយទៅជាជនរងគ្រោះនិងរស់នៅក្នុងភាពភ័យខ្លាចរយៈពេលជាងដប់ឆ្នាំបន្តទៀតដោយសារឥទ្ធិពលនៃសង្គ្រាមនោះ ។


ឆាយ ម៉ឺន

**ឆាយ ម៉ឺន** អាយុ៥១ឆ្នាំមានស្រុកកំណើតនៅឃុំរាក់ជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ម៉ឺន មានឪពុកឈ្មោះ ឆាយ អ៊ិញ ម្តាយឈ្មោះ ទុយម៉ន និងមានបងប្អូន៧នាក់ ។ សព្វថ្ងៃ ម៉ឺន មានប្រពន្ធឈ្មោះ ឃួន អច និងកូន៧នាក់ នៅឃុំផ្គាំ ស្រុកស្វាយចេក ។

កាលពីកុមារ ម៉ឺន រៀនដល់ថ្នាក់ទី១០ (សង្គមចាស់) ក៏ឈប់រៀនដើម្បីមកជួយធ្វើការងារស្រែចម្ការឪពុកម្តាយវិញ ។ អាយុបាន១៥ឆ្នាំ ម៉ឺន និងបងប្អូនបង្កើតចំនួនពីរនាក់ទៀតបានសម្រេចចិត្តចូលបម្រើ

បដិវត្តន៍ (តែបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ) ។ ដំបូង ម៉ឺន ធ្វើកង ឈ្លបប្រចាំឃុំរាក់ជ័យ រយៈពេលប្រាំមួយខែក្រោយមក អង្គការចាត់តាំងគាត់ឲ្យទៅធ្វើយោធាស្រុកបាភ្នំ និងជាយោធាប្រចាំភូមិភាគបូព៌ា ។

នៅពេលច្បាំងជាមួយទាហាន លន់ នល់ មេបញ្ជាការរបស់ ម៉ឺន តែងតែប្រកាសថា ក្នុងមួយថ្ងៃកងទ័ពត្រូវរំកិលទៅមុខឲ្យបានពី១០ទៅ២០គីឡូម៉ែត្រ ហើយបើស្លាប់១០នាក់ ត្រូវបូលថែម២០នាក់ទៀត ។ ការឃោសនានេះបានធ្វើឲ្យ ម៉ឺន និងកងទ័ពទាំងអស់កាន់តែមានទឹកចិត្តក្លាហាន និងហ៊ានលះបង់ជីវិតដើម្បីប្រទេសជាតិ ។ ម៉ឺន មិនបានចូលប្រយុទ្ធនៅទីក្រុងភ្នំពេញទេ ព្រោះគាត់ត្រូវរបួស ហើយត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ ក្រោយពីជាសះស្បើយពីជំងឺ អង្គការចាត់តាំង ម៉ឺន ឲ្យទៅធ្វើការនៅអង្គភាពពេទ្យយោធាដែលគាត់គ្មានជំនាញខាងផ្នែកនេះពីមុនមកទេ ។ រហូតដល់ឆ្នាំ១៩៧៧ អង្គការបានចាត់តាំង ម៉ឺន ឲ្យទៅច្បាំងជាមួយកងទ័ពវៀតណាមតាមព្រំដែនខាងកើតជាប់ខេត្តតាយនិញ និងដុងថាប់ ។ រយៈពេលពីរឆ្នាំនៅព្រំដែន ម៉ឺន សង្កេតឃើញថា កងទ័ពខ្មែរក្រហមមិនមានទឹកចិត្តប្រយុទ្ធដូចពេលវាយជាមួយទាហាន លន់ នល់ ទេព្រោះគេដឹងថាអង្គការបានចាប់មេរបស់ខ្លួនអស់ហើយ ។ យោធាមួយចំនួនបាក់ស្មារតីជាបន្តបន្ទាប់ រហូតដល់កងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ។

ម៉ឺន បានត្រឡប់មកនៅស្រុកកំណើតបានមួយឆ្នាំ គាត់ក៏ចេញទៅរកស៊ីនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ។ នៅទីនោះ ម៉ឺន បានជួបមិត្តភក្តិនៅក្នុងកងជាមួយគាត់ ហើយគាត់ក៏សម្រេចចិត្តចូលធ្វើយោធាខ្មែរក្រហមម្តងទៀតនៅភ្នំឆត្រ ដែលមានប្រធានកងពលឈ្មោះ ឌុល សារឿន, ប៉ែន វ៉ូយ, ព្រាំ ស៊ូ និង ឡុង ថែម ។

នៅឆ្នាំ១៩៩១ មានកងកម្លាំងគ្រប់ភាគីបានរស់នៅចម្រុះគ្នាក្នុងស្រុកស្វាយចេក ។ នៅពេលនោះ គ្រួសារ កាំង ហ្កេកអ៊ាវ ហៅ ឌុច ក៏មករស់នៅភូមិផ្គាំ ហើយគាត់បានធ្វើជាគ្រូបង្រៀននៅអនុវិទ្យាល័យផ្គាំ ។ នៅពេលនោះ ឌុច បានក្លាយទៅជាមនុស្សដែលគួរឲ្យគោរពក្នុងចំណោមសិស្សនិងអ្នកភូមិដោយសារតែគាត់មានចរិតស្លូតបូត និងម៉ឺងម៉ាត់ក្នុងការងារ ។

នៅឆ្នាំ១៩៩៥ មានអំពើឃាតកម្មបួន់សម្លាប់ទៅលើគ្រួសារ ឌុច ។ ម៉ឺន និងអ្នកភូមិបាននាំ ឌុច និងប្រពន្ធទៅកាន់មន្ទីរពេទ្យ ប៉ុន្តែដោយសារមានរបួសធ្ងន់ធ្ងរ ទើបបណ្តាលឲ្យប្រពន្ធរបស់គាត់ស្លាប់ ។ ដោយសារភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួន ឌុច បានចាកចេញពីភូមិផ្គាំមករស់នៅជិតសាលាស្រុកស្វាយចេក ក្រោយមកក៏ផ្លាស់ទៅស្រុកសំឡូតរហូតដល់ទាហានរដ្ឋាភិបាលចាប់ខ្លួន ។

អ្នកភូមិផ្គាំមិនដែលស្គាល់ឈ្មោះ ឌុច ទេ គឺស្គាល់តែឈ្មោះគ្រូតា និង ហង់ ពិន ប៉ុណ្ណោះ ។ ប្រជាជននៅភូមិផ្គាំទើបតែស្គាល់ឈ្មោះ ឌុច នៅពេលតុលាការបើកសវនាការកាត់ទោសគាត់ប៉ុណ្ណោះ ហើយអ្នកភូមិក៏មិនដែលនឹកស្មានថា ឌុច ជាប្រធានគុកទួលស្លែងដូច្នេះដែរ ។

សព្វថ្ងៃនេះ ប្រជាជនរស់នៅតាមជាយដែនមិនចង់ឲ្យកើតមានសង្គ្រាមបន្តទេ ព្រោះបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស កូនចៅមិនបានទៅសាលារៀននិងធ្វើឲ្យជីវភាពរបស់គាត់មានការលំបាក ។ **សុខ វណ្ណៈ**

# ដំណឹងស្វែងរកសាច់ញាតិ

នាងខ្ញុំឈ្មោះ កង យិន អាយុ ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិអន្លង់ជ្រៃ ឃុំអំពើន ស្រុកបន្ទាយមាស ខេត្តកំពត ។ សូមប្រកាសស្វែងរកកូននិងប្តីដែលបាត់ខ្លួនកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ។ កូនរបស់ខ្ញុំឈ្មោះ ហួម ហើយប្តីឈ្មោះ ពីន ។ អ្នកទាំងពីរត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើស្រែអំបិលនៅកែប ហើយមិនឃើញត្រឡប់មកវិញរហូតដល់សព្វថ្ងៃ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ***

# អតីតជនបដិវត្តន៍ជនជាតិភាគតិចកាវ៉ែត

ហ៊ូ ជា អាយុ៥៣ឆ្នាំ ជាជនភាគតិចកាវ៉ែត។ ជា ចូលបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៦៨។ ក្រោយមក ជា ត្រូវអង្គការជ្រើសរើសឲ្យធ្វើជាកងការពារមន្ទីររបស់ អៀង សារី គ្រប់គ្រងផ្នែកពាណិជ្ជកម្ម គ្រឿងចក្រ សារទូរលេខ និងគ្រប់គ្រងកុមារ។

ហ៊ូ ជា កើតនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។ ជា មានបងប្អូនទាំងអស់ប្រាំពីរនាក់។ ក្រោយពី ជា ឈប់រៀនត្រឹមថ្នាក់ទី៩ (សង្គមចាស់) គាត់ក៏បានរៀបការជាមួយប្រពន្ធជាជនជាតិកាវ៉ែតដូចគាត់ដែរ។ ជា បានចូលរួមជាមួយចលនាបដិវត្តន៍ ខ្មែរក្រហមតាមរយៈការឃោសនារបស់ សុង ដាំ និង វង់ (នៅស្រុកឈូក ខេត្តកំពត) ដើម្បីឲ្យប្រទេសទទួលបានសន្តិភាព និងរីកចម្រើន។

បន្ទាប់មក ជា បានចាកចេញពីផ្ទះទៅរស់នៅព្រៃក្នុងខេត្តស្ទឹងត្រែងជាមួយ អៀង សារី, សុន សេន និងកម្មាភិបាលខ្មែរក្រហមផ្សេងទៀតដែលមានប្រជាជនជួយឧបត្ថម្ភស្បៀងអាហារ។ នៅទីនោះ ជា មានតួនាទីជាយុវជនការពារមន្ទីរ។ ក្រៅពីការងារការពារប្រចាំថ្ងៃ អង្គការបានបំពាក់បំប៉ន ជា អំពីស្មារតីការពារអង្គការនិងការពារមន្ទីរ។

នៅឆ្នាំ១៩៧០ នៅពេលដែល ជា ត្រឡប់មកផ្ទះវិញ គាត់បានឃើញជនជាតិភាគតិចកាវ៉ែត និងជនជាតិភាគតិចផ្សេងៗដែលរស់នៅតំបន់ភ្នំចាកចេញពីស្រុកកំណើតមកចូលរួមជាមួយចលនាបដិវត្តន៍កាន់តែច្រើននៅតំបន់ទំនាបតាមការអំពាវនាវរបស់សម្តេច សីហនុ។

ក្រោយពីត្រឡប់ទៅមន្ទីរវិញ អង្គការបានចាត់តាំង ជា ឲ្យនៅខាងផ្នែកពាណិជ្ជកម្មរដ្ឋដោយគាត់គ្រប់គ្រងលើការដោះដូរអំបិល ឬប្រហុក ទៅឲ្យប្រជាជន ដោយគិតជាលុយ អង្ករ ជ្រូក មាន់ ឬ ទា ជាដើម។ ជា បានប្រមូលលុយ និងស្បៀងទាំងអស់ដែលលក់បានទៅប្រគល់ឲ្យ ណៃ សារ៉ាន់ ហៅ យ៉ា ជាលេខាភូមិភាគឦសាន។

ក្រោយទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ អង្គការបានហៅ ជា ពីស្រុកកំណើតមកធ្វើការនៅក្រុងស្ទឹងត្រែងវិញដោយមានតួនាទីជាអ្នកត្រួតពិនិត្យមើលឡាន និងត្រាក់ទ័រ។ មួយឆ្នាំក្រោយមក អង្គការបានផ្លាស់ ជា ឲ្យទៅនៅស្រុកអូរជុំ ខេត្តរតនគិរី ដោយឲ្យកាន់តំណែងជាអ្នកគ្រប់គ្រងខាងផ្នែកសារទូរលេខ។ រាល់ពេលផ្ញើឯកសារទៅថ្នាក់ដឹកនាំផ្សេងៗ បុគ្គលិកផ្នែកសារទូរលេខត្រូវរាយការណ៍ប្រាប់ ជា ដែលភាគច្រើនរៀបរាប់ពីសភាពការណ៍ខ្មាំង និងសកម្មភាពរបស់ប្រជាជន។

នៅឆ្នាំ១៩៧៧ អង្គការបានផ្លាស់ ជា ពីផ្នែកសារទូរលេខឲ្យទៅគ្រប់គ្រងកុមារចំនួន៧០នាក់ជាកូនរបស់កម្មាភិបាលខ្មែរក្រហមធ្វើការនៅតាមមន្ទីរនិងធ្វើការនៅចម្ការកៅស៊ូ។ នៅទីនោះ ជា មានតួនាទីមើលខុសត្រូវលើការផ្តល់អាហារឲ្យកុមារនិងដឹកនាំកុមាររៀនសូត្រ។

ពេលកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជាឆ្នាំ១៩៧៩ ជា បានដឹកនាំកុមារមួយចំនួនរត់ទៅនៅខេត្តព្រះវិហារ។ ក្រោយមក កងទ័ពវៀតណាមចាប់ ជា និងកម្មាភិបាលខ្មែរក្រហម៤០នាក់ផ្សេងទៀតឃុំឃាំងអស់រយៈពេលប្រាំខែទើបដោះលែងវិញ។

ក្រោយពីរបបនេះដួលរលំទៅ ជា បានបាត់បងប្អូនស្រីម្នាក់ និងឪពុកដែលគាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយចោទថាមានផែនការរត់ទៅប្រទេសឡាវ។ បច្ចុប្បន្ននេះ ជា មានតួនាទីជាប្រធានភូមិ ហើយគាត់និងប្រពន្ធជាគ្រួសារមួយដែលមានដើមកំណើតជាជនជាតិកាវ៉ែតរស់នៅលាយឡំជាមួយជនជាតិខ្មែរ និងជនជាតិភាគតិចផ្សេងៗទៀតនៅក្នុងស្រុកកូនមុំ ខេត្តរតនគិរី។ ក្រៅពីធ្វើការងារភូមិ ជា បានប្រកបមុខរបរដាំដំឡូង និងធ្វើស្រែបន្ថែមទៀត។

ជា បន្តថា ចាប់តាំងពីគាត់ចាកចេញពីផ្ទះដំបូង គាត់កម្រនឹងបានទៅលេងបងប្អូន និងស្រុកកំណើតណាស់ ព្រោះផ្លូវឆ្ងាយម្យ៉ាងទៀតគាត់ត្រូវចំណាយថវិកាច្រើនថែមទៀត។

**ស៊ើ សាយញាណា**

“បងស្រី និងឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់ ដោយ
ចោទថា គាត់មានផែនការរត់ទៅប្រទេសឡាវ” ហ៊ូ ជា



# អតីតកុមារ ធី រៀបរាប់ពីរបបខ្មែរក្រហម

ម៉ែន ធី មានស្រុកកំណើតនៅភូមិព្រៃគុយ ឃុំកំពង់ធំ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ធី ធ្វើជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យារយៈពេលជាងដប់ឆ្នាំមកហើយ ហើយបច្ចុប្បន្ន ធី ជានាយករងវិទ្យាល័យមួយនៅខេត្តកំពង់ធំ ។



ម៉ែន ធី

នៅក្នុងរបបខ្មែរក្រហម ធី មានអាយុប្រហែល១០ឆ្នាំ ប៉ុន្តែ ធី នៅចងចាំថា គាត់មានបងប្អូនចំនួនប្រាំនាក់ និងមានឪពុកជាអតីតទាហានបារាំង និងម្តាយជាកសិករ ។ ថ្ងៃមួយ ធី និងម្តាយរួមជាមួយប្រជាជនប្រមាណជាង១០គ្រួសារទៀត បានសម្រេចចិត្តរត់ភៀសខ្លួនចេញពីផ្ទះ ដោយសារតែមានចលាចលក្នុងភូមិ ។ ធី និងម្តាយបររទេះមកដល់សាលាសំណាក់ភូមិជ័យ ក៏បានឃើញយោធាខ្មែរក្រហមវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ដើម្បីកៀរយកគ្រួសារគាត់ និងប្រជាជនភៀសខ្លួនទាំងនេះ ។ ការវាយប្រយុទ្ធគ្នានេះបណ្តាលឲ្យប្រជាជនរស់នៅភូមិត្នោតទាប និងភូមិក្បែរៗនោះបានរត់គេចចេញពីផ្ទះដែរ ។

នៅពេលនោះ ឪពុក ធី បានទៅដល់ទីនោះ រួចហើយក៏នាំប្រពន្ធនិងកូនៗមកនៅភូមិទាមចាស់ ដោយទុកចោលរទេះ និងអីវ៉ាន់មួយចំនួនទៀត ។ រហូតដល់សភាពការណ៍បាញ់គ្នាបានស្ងប់ស្ងាត់ ទើប ម្តាយ ធី ត្រឡប់ទៅផ្ទះប្រមូលយកសម្ភារប្រើប្រាស់ និងស្រូវបន្តិចបន្តួចសម្រាប់ហូប ។

ធី បានរស់នៅភូមិទាមចាស់រហូតដល់ខ្មែរក្រហមទទួលជ័យជម្នះ ទើបគ្រួសារគាត់រៀបចំរទេះត្រឡប់ទៅរស់នៅភូមិកំណើតវិញ ។ ប៉ុន្តែប្រធានភូមិឈ្មោះ លៀម (ត្រូវជាសាច់ញាតិរបស់ ធី) បានប្រាប់ឪពុកម្តាយ ធី ឲ្យស្នាក់នៅភូមិនេះបន្តទៀត ព្រោះគាត់ដឹងថាអង្គការនឹងធ្វើការស្រាវជ្រាវប្រវត្តិរូបអ្នកធ្វើការពីរបបមុន ។

ក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជននៅភ្នំពេញ និងនៅតំបន់ផ្សេងៗមករស់នៅភូមិទាមចាស់កាន់តែច្រើន ហើយប្រជាជនទាំងនោះតែងទទួលការធ្វើបាប និងមាក់ងាយពីសំណាក់ប្រជាជនមូលដ្ឋាន ដោយហៅថា «ពួក១៧មេសា» ។ នៅទីនោះ ខ្មែរក្រហមបានចាប់បង្ខំឲ្យក្មេងៗជនជាតិចាមហូបសាច់ជ្រូក បណ្តាលឲ្យក្មេងទាំងនោះស្រែកយំទ្រហឹងក្នុងកងកុមារ ។ ចំណែកចាស់ៗបានយករបបសាច់ជ្រូករបស់គាត់ទៅដូរជាមួយអំបិល ហូបជំនួសវិញ ។

នៅទីនោះ ដំបូងអង្គការចាត់តាំងឪពុករបស់ ធី លើកប្រឡាយ និងភ្ជួររាស់ស្រែ ចំណែកអ្នកដែលចេះធ្វើរទេះ ខ្មែរក្រហមចាត់តាំងឲ្យទៅនៅខាងសិប្បកម្មធ្វើរទេះនៅវត្តក្តីចារ ។ ក្រោយមក បានប្តូរឲ្យគាត់ទៅលើកទំនប់អូរវ៉ា (ស្ថិតនៅតាមបណ្តោយស្ទឹងសែន) ប៉ុន្តែដោយសារឪពុក ធី មិនមានអាហារហូបគ្រប់គ្រាន់ និងធ្វើការងារហួសកម្លាំង ទើបបណ្តាលឲ្យគាត់ធ្លាក់ខ្លួនឈឺ ។ ឃើញដូច្នេះ ខ្មែរក្រហមបានអនុញ្ញាតឲ្យគាត់ត្រឡប់មកផ្ទះវិញ ។ រាល់ថ្ងៃឪពុក ធី មិនអាចឡើងលើផ្ទះដោយខ្លួនឯងបានទេ ដោយសារតែគាត់គ្មានកម្លាំងកំហែង ចំណែកម្តាយគាត់ដែលដកស្ទូងនៅក្នុងភូមិបានលះបង់របបបបររបស់គាត់ពាក់កណ្តាលឲ្យប្តីហូប ។ នៅពេលយប់ ម្តាយ ធី បានលួចដើរចាប់កង្កែបមកធ្វើម្ហូបឲ្យឪពុកគាត់ហូបរហូតបានធូរស្បើយ ។ នៅរដូវប្រញឹកស្ទូង ខ្មែរក្រហមបានបង្ខំឲ្យម្តាយ ធី និងកងចល័តទាំងអស់ស្ទូងទាំងយប់ ។ ការប្រើដូច្នេះ អ្នកដែលអស់កម្លាំង និងអត់ងងុយខ្លាំងបានជាន់ពន្លិចសំណាបចោលក្នុងទឹកតែម្តង ប៉ុន្តែប្រសិនបើប្រធាន

កងជីង នឹងដាក់ទណ្ឌកម្មអ្នកទាំងនោះមិនខាន ។

ក្រោយពេលឪពុក ធី មានកម្លាំងឡើងវិញ អង្គការបានចាត់តាំងគាត់ឲ្យទៅភ្ជួរដីនៅក្នុងកងចល័តភូមិ ចំណែកបងប្រុស ធី ឈ្មោះ យុត វ៉ែន (យកត្រកូលតាមជីតា) អង្គការចាត់ឲ្យចូលយោធា និង បងប្រុសម្នាក់ទៀត យុត រា នៅក្នុងកងចល័ត និង ធី នៅក្នុងកងកុមារ ។ ចំណែកប្អូនស្រីឈ្មោះ យុត នាង និងប្អូនប្រុសម្នាក់ទៀតត្រូវម្តាយគាត់យកទៅផ្ញើនៅកងយាយៗ ដែលមានយាយ ជូ (យាយរបស់ ធី) ជាប្រធាន។ ក្រៅពីមើលក្មេងៗ យាយ ជូ បានដឹកនាំយាយៗត្បាញក្រមា និងធ្វើកន្ទេល ហើយគាត់តែងស្តីបន្ទោសចំពោះយាយៗណាដែលមិនធ្វើការងារទៅតាមការបង្គាប់បញ្ជារបស់គាត់ ។

ធី រស់នៅក្នុងភូមិជាមួយកុមារផ្សេងទៀតប្រមាណជាង ៣០នាក់ ។ ប្រធានកងកុមារនៅពេលនោះ ឈ្មោះ ណឹម ។ រៀងរាល់ព្រឹក ធី តែងតែមកឈរតម្រង់ជួរនៅរោងបាយ រួចហើយចេញទៅធ្វើការងាររៀងៗខ្លួន ។ ប្រសិនបើកុមារណាមិនមកធ្វើការងារទេ នៅម៉ោង១០ព្រឹក ប្រធានកងនឹងដើរកត់ឈ្មោះ


គ្រូថ្នាក់មូលដ្ឋានឡើងមានយោបល់

រួចហើយប្រគល់ឲ្យចុងភៅ ។ នៅពេលហូបអាហារថ្ងៃត្រង់ ចុងភៅមិនចែករបបអាហារដល់អ្នកដែលមិនមានឈ្មោះក្នុងបញ្ជីទេ ដែលក្នុងនោះ ក៏មានឈ្មោះ ធី និងមិត្តភក្តិរបស់គាត់ម្នាក់ឈ្មោះ ឌុម ដែរដោយសារតែគាត់ទាំងពីរដើរលេង ។

នៅខែស្រូវទុំ អង្គការបានចាត់តាំង ធី និងកងកុមារឲ្យទៅចាំចាប ដោយអង្គការបានដាំបង្គោលកំណត់ទីតាំងស្រែ រួចហើយចងកុមារម្នាក់ៗភ្ជាប់ទៅនឹងបង្គោល ដើម្បីកុំឲ្យកុមារទាំងនោះរត់លេង ។ រយៈពេលមួយឆ្នាំ ធី បានហូបបាយតែបីខែ គឺខែច្រូតស្រូវ បន្ទាប់មកគាត់ត្រូវហូបបបររាវរហូត ។

រៀងរាល់យប់ ម្តាយ ធី តែងតែហាមកូនមិនឲ្យនិយាយប្ញជដែកគ្នាទេ ព្រោះតែងតែមានកងឈ្លបតាមដាន និងលបស្តាប់អ្នកដែលនិយាយរិះគន់អង្គការដូចជា ហូបមិនឆ្អែត និងធ្វើការងារធ្ងន់ជាដើម ។ មួយរយៈក្រោយមក ឈ្លបខ្មែរក្រហមមកសួរប្រវត្តិរូបឪពុក ធី ជាញឹកញាប់ ប៉ុន្តែម្តាយ ធី កុហកថាប្តីធ្វើស្រែ ហើយម្យ៉ាងទៀតប្រធានភូមិឈ្មោះ លៀម ជួយលាក់ទៀតទើបបានរួចពីការចោទប្រកាន់ ។ ចំណែកអ្នកជម្លៀសមកពីភ្នំពេញដែលជាប់ទាក់ទងនឹងរបបចាស់ត្រូវឈ្លបដឹកតាមរទេះយកទៅសម្លាប់តែម្តង ដោយកុហកថា អង្គការឲ្យទៅរស់នៅភូមិថ្មី ប៉ុន្តែរយៈពេលពីរម៉ោងក្រោយមក ឃើញអ្នកបររទេះដឹកជញ្ជូនរបស់របរនិងសម្លៀកបំពាក់អ្នកទាំងនោះត្រឡប់ចូលក្នុងភូមិវិញ ។

បន្ទាប់មកទៀត ខ្មែរក្រហមប្រមូលប្រជាជនមកពីភូមិភាគបូព៌ា រួចបញ្ជូនឲ្យទៅរស់នៅវាលខ្ទ័រ វាលក្រសាំងឯម ដែលជាតំបន់ខ្វះខាតម្ហូបអាហារ និងទឹក ។ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងនោះដឹកអណ្តូងនៅលើទួលក្បែរខ្ទម ទោះបីដឹងថា នៅទីនោះមិនមានទឹកក៏ដោយ ។ ចាប់តាំងពីពេលនោះមកប្រជាជននៅទីនោះធ្លាក់ខ្លួនឈឺ និងស្លាប់បន្តបន្ទាប់ ។ ចំណែកនៅកន្លែងផ្សេងដូចជានៅឃុំព្រៃគុយ ខ្មែរក្រហមបានទៅឃោសនាឲ្យប្រជាជនជីកស្រះធំមួយដើម្បីស្តុកអំបិល រហូតដល់កងទ័ពវៀតណាមវាយចូលមក ។

ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ធី ឃើញផ្លូវនៅសេសសល់ពាសវាលពាសកាល ។ ចំណែកគ្រួសារគាត់នៅមានការភ័យខ្លាចដែរ ដោយរាល់ពេលហូបបាយគ្រួសារគាត់

តែងតែហូបលួចលាក់ ព្រោះកងទ័ពខ្មែរក្រហមវាយឆ្មក់ចូលមកភូមិជាញឹកញាប់ ។

នៅឆ្នាំ១៩៨៤ ធី បានចូលរៀន និងក្រោយមកប្រលងជាប់គ្រូនៅខេត្តកំពង់ចាម ។ ធី បានចេញបង្រៀនដំបូងនៅអនុវិទ្យាល័យវិស័យ (ក្រោយមកទើបប្តូរទៅជាវិទ្យាល័យបល្ល័ង្ក) ក្នុងស្រុកប្រាសាទបល្ល័ង្ក ដែលពីមុនមានសាលាតែមួយខ្នងហ៊ុមព័ទ្ធដោយព្រៃ ។ ធី បានស្នាក់នៅសាលា ក្រោយមកដោយសារតំបន់នោះនៅអសន្តិសុខ និងនៅមានចលនាខ្មែរក្រហម ទើប ធី ចេញទៅស្នាក់នៅវត្តវិញ ។

បច្ចុប្បន្នទោះបី ធី មិនបានបង្រៀនផ្នែកប្រវត្តិវិទ្យា ដោយសារគាត់មានតួនាទីជានាយករង និងទទួលការងារបច្ចេកទេស និងរដ្ឋបាលក៏ដោយ តែគាត់នៅតែឆ្លៀតពេលអានសៀវភៅណែនាំគ្រូបង្រៀន និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលគាត់បានទទួលការបណ្តុះបណ្តាលពីអ្នកជំនាញមកពីក្រសួងអប់រំ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ធី រៀបរាប់ថា កាលពីមុននៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា មិនបានសរសេរពីរបបខ្មែរក្រហមបានស៊ីជម្រៅទេ ។ រហូតមកដល់ពេលនេះ ដោយសារក្រសួងបានផ្លាស់ប្តូរកម្មវិធីអប់រំថ្មី ទើបសិស្សយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម ។

ធី ប្រាប់ថា នៅក្នុងសាលារបស់គាត់សិស្សពាក់កណ្តាលជាកូនរបស់អតីតប្រជាជនរស់នៅមូលដ្ឋាន និងកម្មាភិបាលខ្មែរក្រហម ហើយពាក់កណ្តាលទៀតកូនរបស់អ្នកដែលមករស់នៅថ្មីៗ ដែលធ្វើឲ្យគាត់មានការលំបាកក្នុងការនិយាយពីរបបខ្មែរក្រហម ព្រោះនៅមានឈ្លបខ្មែរក្រហមបច្ចុប្បន្ននៅរស់ក្នុងភូមិរបស់គាត់អាចជាឪពុកម្តាយ ជីតាឬសាច់ញាតិរបស់សិស្ស ដែលធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍សិស្ស ។ ដូច្នេះដើម្បីចៀសវាងការស្អប់ និងគុំគួន ធី បានជំរុញឲ្យសិស្សសាកសួរឪពុកម្តាយនិងចាស់ៗនៅក្នុងភូមិដែលឆ្លងកាត់របបខ្មែរក្រហមបន្ថែមទៀត ។

**សោម ប៊ុនថន**



លោកគ្រូ ម៉ែន ធី ឡើងពន្យល់មេរៀនដល់គ្រូថ្នាក់មូលដ្ឋាន

# ស្រុកវាលវែង ពីមុន និងបច្ចុប្បន្ន

វាលវែងជាស្រុកមួយរបស់ខេត្តពោធិ៍សាត់ ដែលទើបតែបង្កើតឡើងបន្ទាប់ពីកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៦ ។ កាលពីមុនតំបន់វាលវែង ស្ថិតនៅក្នុងស្រុកក្រវាញប៉ែកខាងលិច ។ សព្វថ្ងៃទីរួមស្រុកវាលវែងមានចម្ងាយប្រមាណ១២០គីឡូម៉ែត្រពីទីរួមខេត្តពោធិ៍សាត់ដោយធ្វើដំណើរតាមផ្លូវលេខ៥៦ដែលឆ្លងកាត់តាមស្រុកភ្នំក្រវាញ ។ ផ្លូវនេះមានសភាពតូចចង្អៀត និងក្រាលកៅស៊ូបានតែមួយកំណាត់ពីទីរួមខេត្តពោធិ៍សាត់ទៅស្រុកភ្នំក្រវាញប៉ុណ្ណោះ ។ ផ្លូវពីស្រុកភ្នំក្រវាញទៅស្រុកវាលវែងគឺជាផ្លូវក្រាលក្រួសក្រហម ក្រហ៊ុងក្រហូង ហើយស្ពានមួយចំនួនមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ដោយសាររថយន្តធុនធ្ងន់បើកបរឆ្លងកាត់ ។

ទីរួមស្រុកវាលវែងស្ថិតនៅចម្ងាយ៧៥គីឡូម៉ែត្រពីព្រំប្រទល់ដែនប្រទេសថៃត្រង់ខេត្តត្រាត ។ ចំណុចព្រំប្រទល់ដែននោះត្រូវបានហៅថាច្រកទ្វារព្រំដែនថ្មដាស្ថិតនៅក្នុងឃុំថ្មដា ។ បច្ចុប្បន្ននេះ អាជ្ញាធរនៃប្រទេសទាំងពីរបានអនុញ្ញាតឲ្យប្រជាជនរបស់ខ្លួនចេញដោយសេរីគឺមួយថ្ងៃក្នុងមួយសប្តាហ៍ គឺនៅថ្ងៃសៅរ៍ ។ បើសិនជាយើងធ្វើដំណើរតាមផ្លូវខាងឆ្វេងដៃពីរង្វង់មូលទីរួមស្រុកទៅប៉ែកខាងត្បូង ប្រមាណ៦០គីឡូម៉ែត្រនោះយើងនឹងទៅដល់ទីតាំងឃុំអូរសោម ជាទីកន្លែងដែលក្រុមហ៊ុនចិនកំពុងសាងសង់ទំនប់វារីអគ្គិសនី ។ បើធ្វើដំណើរបន្តពីអូរសោមប្រហែលជា៤០គីឡូម៉ែត្រទៀតនោះនឹងទៅដល់ទីរួមខេត្តកោះកុង ។

ស្រុកវាលវែងមានឃុំចំនួនប្រាំគឺឃុំប្រម៉ោយ ឃុំអន្លង់រាប ឃុំអូរសោម ឃុំក្រពើពីរ និងឃុំថ្មដា ។ តាមស្ថិតិឆ្នាំ២០១១នេះ ស្រុកវាលវែងមានប្រជាជនសរុបចំនួន១៣.៨២៣នាក់ ស្មើនឹង៣.១៩៧គ្រួសារ ។ នៅក្នុងឆ្នាំ២០១១-២០១២នេះ រាជរដ្ឋាភិបាលបានកំពុងរៀបចំអនុក្រឹត្យដើម្បីបង្កើតឃុំ និងភូមិមួយ



ផ្លូវទៅកាន់ស្រុកវាលវែង

ចំនួនបន្ថែមទៀតដោយសារស្រុកវាលវែងនៅមានផ្ទៃដីធំទូលាយនៅឡើយ ។ បើតាមលោក ជិន លី ប្រធានផ្នែករដ្ឋបាលនៃសាលាស្រុកវាលវែងបានមានប្រសាសន៍ថា ស្រុកវាលវែងមានប្រជាជនដែលជាអតីតកម្មាភិបាលខ្មែរក្រហមប្រមាណជា៤០ទៅ៥០ភាគរយកំពុងរស់នៅ ។ ក្រៅពីនេះគឺជាប្រជាជនថ្មីដែលបានធ្វើចំណាក់ស្រុកមកពីបណ្តាខេត្តផ្សេងៗ ដើម្បីប្រកបមុខរបរចិញ្ចឹមជីវិត ពីព្រោះនៅតំបន់នេះនៅមានផ្ទៃដីធំទូលាយងាយស្រួលក្នុងការប្រកបមុខរបរធ្វើស្រែចម្ការ ។ ម្យ៉ាងទៀត ស្រុកវាលវែងមានផ្ទៃដីព្រៃឈើដ៏មានតម្លៃរាប់ម៉ឺនហិកតាដែលសម្បូរទៅដោយជួរភ្នំ និងសត្វព្រៃដូចជា ដំរី ខ្លា ទន្សោង ខ្ទីង ប្រើស ឈ្លូស ជ្រូកព្រៃ ។ល ។

នៅឆ្នាំ១៩៧៩ បន្ទាប់ពីកងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជា ថ្នាក់ដឹកនាំខ្មែរក្រហម រួមទាំងមេបញ្ជាការយោធា កម្មាភិបាលថ្នាក់ក្រោម និងកម្មាភិបាលនៅតាមបណ្តាភូមិភាគនានាបានរត់គេចខ្លួនមកដល់ព្រំប្រទល់ដែនខ្មែរ-ថៃ ។ វាលវែងគឺជាអតីតតំបន់លាក់ខ្លួនរបស់កងទ័ពខ្មែរក្រហមដើម្បីធ្វើសង្គ្រាមវាយឆ្មក់មកលើកងទ័ពវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ តែទោះជាយ៉ាងក៏ដោយ ក៏តំបន់នេះមិនមានកងកម្លាំងខ្មែរក្រហមរស់នៅច្រើនដូចតំបន់លាក់ខ្លួនរបស់ខ្មែរក្រហមផ្សេងៗទៀតទេ ។

នៅតាមព្រំប្រទល់ដែនកម្ពុជា-ថៃចាប់ពីខេត្តកោះកុងមកដល់តំបន់ថ្មដានៃស្រុកវាលវែងមានកងពលរបស់ខ្មែរក្រហមចំនួនពីរបានឈរជើងប្រចាំការ គឺកងពលទី២ និងកងពលទី៣ ។ កងពលទី២ ដឹកនាំដោយមេបញ្ជាការឈ្មោះ វ៉ែន ។ បើតាមអតីតកងទ័ពខ្មែរក្រហមដែលរស់នៅស្រុកវាលវែងបានឲ្យដឹងថា វ៉ែន គឺជាកូនប្រសាររបស់ តាម៉ុក ។ កងពលទី៣ដឹកនាំដោយឈ្មោះ សេង ដែលជាអតីតអនុប្រធានកងពល១៦៤ប្រចាំនៅទីក្រុងកំពង់សោម ក្នុងអំឡុងឆ្នាំ១៩៧៥ និង១៩៧៩ ។ ចំណែក មាស មុត ដែលជាអតីតប្រធានកងពល១៦៤ និងជាអតីតកូនប្រសាររបស់តាម៉ុកម្នាក់ដែរនោះ បានទទួលតួនាទីជាគណៈសមរភូមិទិសនៅជួរព្រំដែនចាប់ពីខេត្តកោះកុង ថ្មដា និងស្រុកសំឡូត ។

អតីតកម្មាភិបាលខ្មែរក្រហមនៅស្រុកវាលវែងបានឲ្យដឹងថា វ៉ែន ប្រធានកងពលទី២បានស្លាប់នៅឆ្នាំ១៩៨៧ ដោយសារតែជំងឺក្រោយពីបាញ់សម្លាប់សត្វពស់វែក និងយកស៊ុតរបស់ពស់វែកនោះមកស្ងោរហូបបានមួយរយៈ ។ ចំណែកឈ្មោះ សេង ប្រធានកងពលទី៣ ត្រូវជាបងប្អូនបង្កើតរបស់ (វ៉ែន) បានស្លាប់ដោយសារជាន់មីនរបស់វៀតណាមនៅចុងឆ្នាំ១៩៨០ ។

នៅពេលដែលកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ ខ្មែរក្រហមបានចាប់ផ្តើមបញ្ជូនកងទ័ពនិងគ្រួសារកងទ័ពមករស់នៅតំបន់វាលវែងបន្ថែមក្នុងបំណងដើម្បីពង្រីកទីតាំងរបស់ខ្លួន ។ ជាពិសេសចាប់ពីឆ្នាំ១៩៩៣ ខ្មែរក្រហមបានចាប់ផ្តើមសាងសង់ផ្ទះសម្បែង និងបែងចែកដីធ្លីឲ្យប្រជាជនធ្វើស្រែចម្ការជាបណ្តើរៗ ។


ទីប្រជុំជនស្រុកវាលវែង

នៅអំឡុងចុងទសវត្សរ៍៨០ និងដើម៩០ មេដឹកនាំខ្មែរក្រហមបង្កើតកងពលឯករាជ្យតូចៗចំនួនបីបន្ថែមទៀតនៅតំបន់វាលវែង និងខេត្តពោធិ៍សាត់ ។ កងពលតូចឯករាជ្យមួយដឹកនាំដោយ អួន យ៉ង ដែលធ្វើសកម្មភាពចាប់ពីវាលវែងទៅស្រុកភ្នំក្រវាញទៅពោធិ៍សាត់ និងទៅស្រុកមោងឫស្សីក្នុងខេត្តបាត់ដំបង ជាពិសេសនៅតាមដងផ្លូវលេខ៥៦ ។ កងពលឯករាជ្យមួយដឹកនាំដោយ

អៀង ផាន ធ្វើសកម្មភាពនៅតាមផ្លូវដែកចាប់ពីខេត្តពោធិ៍សាត់ទៅខេត្តបាត់ដំបង ជាពិសេសនៅវ៉ាតាណក់ក្នុងស្រុកក្រគរ ។ ចំណែកកងពលតូចឯករាជ្យចុងក្រោយដឹកនាំដោយ គីម ពៅ បានធ្វើសកម្មភាពនិងការពារនៅក្នុងតំបន់វាលវែង ។

ក្រោយពេលធ្វើសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៦ អួន យ៉ង់ បានទទួលតួនាទីជាអភិបាលស្រុកវាលវែងនិងបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាស្រុកវាលវែងចាប់ពីឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន ។ អៀង ផាន បានទទួលតួនាទីជាមេបញ្ជាការរងនៃយុទ្ធភូមិភាគទី៥ នៃកងយោធពលខេមរភូមិន្ទ ។ ចំណែក គីម



ពៅ បានទទួលងារជាមេបញ្ជាការរងកងពលតូចលេខ១១៨នៃកងយោធពលខេមរភូមិន្ទ ។

នៅពេលធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យអតីតកងទ័ពខ្មែរក្រហមមានសិទ្ធិសេរីភាពក្នុងការប្រកបមុខរបររកស៊ី ហើយអតីតខ្មែរក្រហម បានរកស៊ីកាប់ឈើលក់ឲ្យប្រទេសថៃ ។ ការកាប់ឈើលក់ឲ្យទៅប្រទេសថៃមានតាំងពីមុនពេលធ្វើសមាហរណកម្មទៅទៀត ក៏ប៉ុន្តែមិនទាន់ជាទ្រង់ទ្រាយធំពីព្រោះកាលនោះប្រទេសចិនបានផ្តាច់ជំនួយ ដូច្នេះកងទ័ពខ្មែរក្រហមត្រូវតែដោះស្រាយផ្គត់ផ្គង់ដោយខ្លួនឯង ។

ផ្ទៃដីស្រុកវាលវែងនៅមានសេសសល់ផ្ទៃដីព្រៃឈើច្រើននៅឡើយ គឺមានស្ថានភាពខុសពីតំបន់អតីតខ្មែរក្រហមផ្សេងៗទៀត ដូចជា ស្រុកសំឡូត ម៉ាឡៃ ភ្នំព្រឹក សំពៅលូន កំរៀង និងអន្លង់វែង ដែលភាគច្រើនផ្ទៃដីព្រៃឈើបានក្លាយទៅវាលចម្ការ ដូចជា ពោត ល្ង សណ្តែក ជាពិសេសដំឡូងមី ។ ប្រជាជនមួយចំនួនធំបានពេញចិត្តនឹងការដឹកនាំត្រឹមត្រូវរបស់រាជរដ្ឋាភិបាលដែលបានកសាងនិងអភិវឌ្ឍនៅតាមភូមិឃុំ ដូចជា ការកសាងផ្លូវថ្នល់ ការដោះមីន និងការកសាងសង់ទំនប់វារីអគ្គិសនីជាដើម ។ ការកសាងនិងអភិវឌ្ឍន៍ទាំងនេះបានធ្វើឲ្យប្រជាជនមានភាពងាយស្រួលក្នុងការរស់នៅ ។ ក៏ប៉ុន្តែមានប្រជាជនមួយចំនួនបានកំពុងតែព្រួយបារម្ភចំពោះក្រុមហ៊ុនមួយចំនួនដែលបានចុះមកធ្វើការអភិវឌ្ឍន៍ ដោយបានប៉ះពាល់ដល់ដីចម្ការដែលប្រជាជនបានកាប់ឆ្ការជាយូរមកហើយដីទាំងនោះនឹងត្រូវបានក្រុមហ៊ុនរឹបអូសយកដោយមិនមានសំណងអ្វីទាំងអស់ ទោះបីជាប្រជាជនមានប្លង់កម្មសិទ្ធិពីអាជ្ញាធរភូមិឃុំក៏ដោយ (យោងតាមការរាយការណ៍របស់អ្នកភូមិ) ។ ចាប់តាំងពីមានក្រុមហ៊ុនអភិវឌ្ឍន៍ចូលមកស្រុកវាលវែង បានធ្វើឲ្យមានការប៉ះពាល់ដល់ព្រៃឈើ និងសត្វព្រៃកាន់តែច្រើនថែមទៀត ពីព្រោះក្រុមហ៊ុនភាគច្រើនបានកាប់ព្រៃឈើដើម្បីយកដីទៅអភិវឌ្ឍ ដូចជាដាំកៅស៊ូ និងដំណាំផ្សេងៗ ។

**សុខ ខណ្ណៈ និង ឡុង ដានី**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ *http://www.voanews.com/ khmer/democratic-kampuchea.cfm* របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការវិភាគទៅលើវិធានឃុំខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការគ្រប់គ្រងមន្ទីរឃុំខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានរចនាសម្ព័ន្ធខុសពីរចនាសម្ព័ន្ធនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ។ ខណៈពេលដែលតុលាការនេះបានផ្តល់ការទទួលខុសត្រូវផ្នែកនេះទៅឲ្យអង្គភាពរដ្ឋបាល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់ការទទួលខុសត្រូវយ៉ាងតិចតួចទៅឲ្យមន្ត្រីចុះបញ្ជីដែលនៅអង្គភាពរដ្ឋបាលដ៏សំខាន់ ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យដែលទទួលបន្ទុកលើសេចក្តីសម្រេចរដ្ឋបាលភាគច្រើនទាក់ទងនឹងលក្ខខណ្ឌឃុំខ្លួនគឺជាបន្ទុករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ នេះគឺជាបញ្ហាមួយ ដោយសារតែសហចៅក្រមស៊ើបអង្កេតមានតួនាទីដឹកនាំការស៊ើបអង្កេតអ្នកជាប់ឃុំ ។ ការដែលថាការិយាល័យសហចៅក្រមស៊ើបអង្កេតដែលជាអង្គភាពស៊ើបអង្កេតមានអំណាចគ្រប់គ្រងការងាររដ្ឋបាល បានចោទជាបញ្ហាទាក់ទងនឹងលទ្ធភាពរបស់អង្គភាព នោះក្នុងការរក្សាមុខងារស៊ើបអង្កេតមិនឲ្យលម្អៀង ។

ដំណើរការសម្រេចដោយប្រើឆន្ទានុសិទ្ធិដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងលក្ខខណ្ឌឃុំខ្លួនអាចឆ្លុះបញ្ចាំងពីបញ្ហានេះ ។ ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានយន្តការត្រួតពិនិត្យតាមផ្លូវច្បាប់ក៏ដោយ ក៏ចំណុចនេះនៅតែមានភាពខុសប្លែកពីតុលាការផ្សេងទៀតដែរ ។ នៅពេលថ្មីៗនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញគោលការណ៍មួយដែលទូលាយជាងគោលការណ៍ពិនិត្យមើលទៅលើសេចក្តីសម្រេចរដ្ឋបាលរបស់តុលាការផ្សេងទៀត ។ គោលការណ៍នេះអាចនាំឲ្យមានការពិនិត្យមើលយ៉ាងល្អិតល្អន់ទៅលើសេចក្តីសម្រេច គឺវាអនុញ្ញាតឲ្យមានការត្រួតពិនិត្យដោយតុលាការច្រើនជាងមុន ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់បទដ្ឋានត្រួតពិនិត្យលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតខ្ពស់ជាងនៅក្នុងតុលាការផ្សេងទៀតនិងមិនអនុញ្ញាតឲ្យមានការប្តឹងឧទ្ធរណ៍ឡើយ ។ ការធ្វើបែបនេះបានផ្តល់ការលំបាកដល់អ្នកជាប់ឃុំដើម្បីទទួលការដោះលែង ។ ដោយគិតពីចំណុចទាំងនេះ វាមានភាពមិនច្បាស់លាស់ថាតើភាពខុសប្លែកគ្នាទាំងនេះផ្តល់ជាផលល្អ ឬអាក្រក់ចំពោះអ្នកជាប់ឃុំទេ ។

មានការលើកឡើងតែបន្តិចបន្តួចទៅលើកិច្ចការងារច្បាប់នៃដំណើរការនីតិវិធីត្រួតពិនិត្យទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មានការលើកឡើងពីការត្រួតពិនិត្យទៅលើវិធានមន្ទីរឃុំឃាំងថាដោះស្រាយតែទៅលើការគ្រប់គ្រងប្រព័ន្ធទូរស័ព្ទ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសេចក្តីសម្រេចជាសាធារណៈកន្លងមក អង្គបុរេជំនុំជម្រះបានរកឃើញថាខ្លួនមានអំណាចពេញលេញក្នុងការត្រួតពិនិត្យទៅលើសេចក្តីសម្រេចដែលទាក់ទងនឹងបញ្ហាឃុំខ្លួនផ្សេងៗ និងប្រើប្រាស់ពាក្យដូចជាវិធានមន្ទីរឃុំឃាំងនិងវិធានផ្ទៃក្នុងសម្រាប់ធ្វើជាមូលដ្ឋានត្រួតពិនិត្យ ។ ប៉ុន្តែ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានប្រព័ន្ធត្រួតពិនិត្យនិងបទដ្ឋានត្រួតពិនិត្យផ្សេងខុសពីតុលាការអន្តរជាតិផ្សេងទៀត ។

ទោះបីជាតុលាការអន្តរជាតិបានអនុញ្ញាតឲ្យមានការត្រួតពិនិត្យតាមផ្លូវច្បាប់ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏មូលដ្ឋាននៃការត្រួតពិនិត្យបែបនេះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីជួបប្រទះនឹងបញ្ហាក្នុងការផ្តល់ការកាត់ក្តីដ៏យុត្តិធម៌ដែរ ។ ប្រព័ន្ធផ្សេងទៀតបានអនុញ្ញាតឲ្យមានប្រធានត្រួតពិនិត្យផ្នែករដ្ឋបាល រីឯនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវាហាក់ដូចជាមានតែអង្គបុរេជំនុំជម្រះមានអំណាចត្រួតពិនិត្យទៅលើសេចក្តីសម្រេចបែបនេះដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ។ ការខ្វះខាតការត្រួតពិនិត្យផ្នែករដ្ឋបាលទំនងជាអាចពន្យឺតដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីព្រោះរាល់ការពិនិត្យត្រូវឆ្លងកាត់អង្គជំនុំជម្រះដែលជាប់រវល់ដោះស្រាយបញ្ហាយុត្តិធម៌ផ្សេងៗ ។ ដោយខុសពីនៅតុលាការអន្តរជាតិដទៃទៀត នៅអង្គ

ជនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានភាគីណាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពិនិត្យមើលរបស់អង្គបុរេជំនុំជម្រះទៅលើសេក្តីសម្រេចរដ្ឋបាលបានឡើយ ។

ភាពខុសគ្នាផ្សេងទៀតរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការអន្តរជាតិគឺបទដ្ឋានត្រួតពិនិត្យទៅសេចក្តីសម្រេចរដ្ឋបាល ។ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់បទដ្ឋានពិនិត្យទៅលើសេចក្តីសម្រេចរដ្ឋបាលរបស់សហចៅក្រមស៊ើបអង្កេតខ្ពស់ជាងនៅតុលាការអន្តរជាតិ ។ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់បទដ្ឋានស្រដៀងនឹងសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ ជាលទ្ធផល សហចៅក្រមស៊ើបអង្កេតមិនត្រូវបានគេចាត់ទុកជាអង្គភាពរដ្ឋបាល ដូចជាមន្ត្រីចុះបញ្ជីនៅតុលាការផ្សេងទៀតទេ ប៉ុន្តែបែរជាត្រូវបានគេចាត់ទុកថាជាអង្គភាពពិនិត្យលើកដំបូងទៅវិញ ។ មានការប្រើប្រាស់បទដ្ឋានខ្ពស់ចំពោះសេចក្តីសម្រេចដែលធ្វើឲ្យមានការពិនិត្យទៅលើការបកស្រាយតាមផ្លូវច្បាប់ និងទៅលើអង្គហេតុនៅពេលដែលមានការរកឃើញថាអង្គហេតុនោះពិតជាខុសមែន ។ នៅតុលាការផ្សេងទៀត បទដ្ឋានពិនិត្យជាបឋមទៅលើសេចក្តីសម្រេចរដ្ឋបាលគឺនៅកម្រិតទាប ដែលជាឧទាហរណ៍ធ្វើឲ្យមានការពិនិត្យនៅពេលដែលមានការពិចារណាទៅលើករណីដែលមិនមានការជាប់ពាក់ព័ន្ធ ឬការខកខានមិនបានពិចារណាទៅលើករណីដែលជាប់ពាក់ព័ន្ធ ។ អាស្រ័យហេតុនេះ ការពិនិត្យលើកដំបូងទៅលើសេចក្តីសម្រេចឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានចាត់ទុកថាដូចនឹងការត្រួតពិនិត្យលើកទីពីរនៅតុលាការអន្តរជាតិ ។ ការធ្វើបែបនេះបានរួមបញ្ចូលតួនាទីស្វែងរកយុត្តិធម៌របស់តុលាការនិងរដ្ឋបាលរបស់សហចៅក្រមស៊ើបអង្កេតគឺថា សហចៅក្រមស៊ើបអង្កេតត្រូវបានចាត់ទុកជាអង្គភាពយុត្តិធម៌មួយសម្រាប់ធ្វើសេចក្តីសម្រេចទៅលើករណីទាំងនេះ ទោះបីជាសហចៅក្រមស៊ើបអង្កេតកំពុងតែអនុវត្តន៍ការងាររដ្ឋបាលដែលស្រដៀងនឹងមន្ត្រីចុះបញ្ជីក៏ដោយ ។

ជាសរុប វាហាក់ដូចជាមានភាពខុសគ្នាសំខាន់បីផ្នែករចនាសម្ព័ន្ធរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការអន្តរជាតិដែលទាក់ទងនឹងរបៀបដែលតុលាការទាំងពីរនេះដោះស្រាយនឹងការពិនិត្យទៅលើបញ្ហាឃុំខ្លួន ។ ទីមួយ អង្គបុរេជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានមូលដ្ឋានដ៏ទូលាយសម្រាប់ពិនិត្យទៅលើសេចក្តីសម្រេចដែលធ្វើឡើងដោយសហចៅក្រុហមស៊ើបអង្កេតដោយប្រើប្រាស់អំណាចរដ្ឋបាលពីព្រោះវាមិនមានដែនកំណត់ចំពោះការពិចារណាទៅលើបញ្ហាការកាត់ទោសដោយយុត្តិធម៌ទេ ។ ទីពីរ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពិនិត្យដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះនៃអង្គជំនុំម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ប៉ុន្តែតុលាការអន្តរជាតិបានអនុញ្ញាតឲ្យមានការពិនិត្យលើកទីពីរដែលអាចជះឥទ្ធពលដល់សិទ្ធិទទួលបានការកាត់ទោសដ៏យុត្តិធម៌ ។ និងទីបី សេចក្តីសម្រេចរដ្ឋបាលរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានត្រួតពិនិត្យដោយប្រើប្រាស់បទដ្ឋានមួយដែលជាទូទៅបទដ្ឋាននោះត្រូវបានយកទៅប្រើប្រាស់នៅក្នុងអង្គភាពយុត្តិធម៌គឺមិនមែនអង្គភាពរដ្ឋបាលទេ ។

ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានរចនាសម្ព័ន្ធពិសេសខុសប្លែកពីគេក៏ដោយ ក៏ដំណើរការនីតិវិធីដែលត្រូវបានបង្កើតឡើងនៅក្នុងវិធានមន្ទីរឃុំឃាំងភាគច្រើនស្រដៀងទៅនឹងវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅលើពិភពលោកដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ មានចំណុចបីដែលវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខុសពីវិធានដែលអនុវត្តនៅក្នុងតុលាការអន្តរជាតិ ហើយនៅក្នុងករណីខ្លះបានធ្វើឲ្យសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចខ្លាំងជាងការិយាល័យរដ្ឋបាលនៅក្នុងប្រព័ន្ធផ្សេងទៀត ។

ផ្នែកទីមួយដែលខុសគ្នានោះគឺការគ្រប់គ្រងទៅលើកញ្ចប់អីវ៉ាន់នៅមន្ទីរឃុំឃាំង ។ ជាទូទៅ តុលាការព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឲ្យប្រធានមន្ត្រីមន្ទីរឃុំឃាំងមើលការខុសត្រូវតែទៅលើការត្រួតពិនិត្យទៅលើកញ្ចប់អីវ៉ាន់ទាំងនោះដោយមិនចាំបាច់ជូនដំណឹងទៅមន្ត្រីចុះបញ្ជី ឬមន្ត្រីដទៃទៀតឡើយ ។ បទបញ្ញត្តិរបស់

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចងាកចេញឆ្ងាយពីតុលាការអន្តរជាតិទាក់ទងនឹងលក្ខខណ្ឌដាក់កំហិតទូទៅទៅលើការបើកកញ្ចប់អ៊ីវ៉ាន់ទេ ពោលគឺទាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងតុលាការអន្តរជាតិនានាអនុញ្ញាតឲ្យមន្ត្រីការងារមានសេរីភាពបើកមើលនូវការឆ្លើយឆ្លងតាមរយៈសំបុត្ររបស់អ្នកជាប់ឃុំ ។ ខុសប្លែកពីតុលាការអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់នូវបទបញ្ជាដែលប្រកាសដោយសហចៅក្រមស៊ើបអង្កេតណែនាំប្រធានមន្ទីរឃុំឃាំងនូវការបើកកញ្ចប់អ៊ីវ៉ាន់ទាំងនោះ ។ តុលាការដទៃទៀតគ្រាន់តែផ្តល់អំណាចដល់ប្រធានមន្ទីរឃុំឃាំងចំពោះការសន្មតបែបនោះតែប៉ុណ្ណោះ ។ ការខ្វះខាតការទទួលបានព័ត៌មានជាសាធារណៈនៃបទបញ្ញត្តិដែលបានដាក់ចេញពីខាងដើមដោយសហចៅក្រមស៊ើបអង្កេតធ្វើឲ្យមានការពិបាកក្នុងការប្រៀបធៀបនឹងតុលាការអន្តរជាតិ ទោះបីអ្នកទាំងនោះបានផ្តល់ឆន្ទានុសិទ្ធិដ៏ពេញលេញដល់មន្ត្រីទាំងអស់ ហើយដែលជាទូទៅបានដាក់កំហិតដល់លទ្ធភាពរបស់អ្នកទាំងនោះក្នុងការស្រាវជ្រាវរកបញ្ហាសន្តិសុខ ។

ផ្នែកទីពីរពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទូរស័ព្ទ ។ វិធានក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហាក់ដូចជាស្របនឹងវិធានរបស់តុលាការអន្តរជាតិចំពោះចំណុចនេះ ហើយស្ទើរតែឈានទៅដល់បទដ្ឋានដែលតម្រូវដោយតុលាការសិទ្ធិមនុស្សនៅអឺរ៉ុបឲ្យមានការទទួលបាន ឬដឹងមុននូវដីកាដែលពាក់ព័ន្ធជាមួយការត្រួតពិនិត្យ ។ ប៉ុន្តែ នេះក៏ជាចំណុចដែលធ្វើឲ្យមុខងារពីររបស់សហចៅក្រមស៊ើបអង្កេតគឺ ការស៊ើបអង្កេតនិងការងាររដ្ឋបាលក្លាយជាមានទំនាស់ផលប្រយោជន៍នឹងគ្នា ។ ខុសប្លែកពីតុលាការអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានរដ្ឋបាលកណ្តាលច្បាស់លាស់សម្រាប់ស្តាប់ទូរស័ព្ទ ឬពិនិត្យឡើងវិញទៅលើទូរស័ព្ទទេ ។ បន្ថែមពីលើចំណុចនេះទៀត ទូរស័ព្ទសម្ងាត់ ឬមិនសម្ងាត់អាចត្រូវបានត្រួតពិនិត្យ ។ ហេតុដូច្នេះហើយ សហចៅក្រមស៊ើបអង្កេត (ហើយនៅក្នុងករណីខ្លះអង្គជំនុំជម្រះ) ដោយស្ថិតនៅក្រោមកាលៈទេសៈជាក់លាក់ណាមួយអាចស្តាប់នូវព័ត៌មានដែលមានអត្ថប្រយោជន៍ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ទោះបីជាខ្លួនមិនមានតួនាទីបឋមខាងផ្នែករដ្ឋបាលក៏ដោយ ប៉ុន្តែ គឺមានតួនាទីខាងផ្នែកយុត្តិធម៌គឺៈដឹកនាំការស៊ើបអង្កេត និងការចងក្រងភស្តុតាង ។

ផ្នែកទី៣ដែលខុសគ្នានៅក្នុងវិធាននិងរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាបញ្ហាទាក់ទងនឹងកំណត់ត្រារបស់អ្នកជាប់ឃុំ ។ បើប្រៀបធៀបទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តល់ឲ្យអ្នកជាប់ឃុំឃាំងនូវឱកាសត្រួតពិនិត្យទៅលើកំណត់ហេតុរបស់ខ្លួនយ៉ាងតិចតួច ហើយអនុញ្ញាតឲ្យបុគ្គលជាច្រើនអាចទទួលបាននូវកំណត់ហេតុទាំងនោះ ដែលរួមទាំងកំណត់ហេតុសម្ងាត់ផ្ទាល់ខ្លួន ។ ខុសពីមន្ត្រីចុះបញ្ជីនៅតុលាការអន្តរជាតិ សហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏មានអំណាចរារាំងអ្នកជាប់ឃុំឃាំងមិនឲ្យមើលកំណត់ហេតុរបស់ខ្លួនដែរ ។ បន្ថែមពីនេះទៀត សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចយកដោយស្វ័យប្រវត្តិនូវសៀវភៅ និងកំណត់ហេតុនៅមន្ទីរឃុំឃាំង ហើយមានអំណាចកំណត់ថានរណាអាចទទួលបានកំណត់ហេតុពិនិត្យរបស់គ្រូពេទ្យច្រើនជាងមន្ត្រីចុះបញ្ជីភាគច្រើន ។ តុលាការអន្តរជាតិបានប្រុងប្រយ័ត្នចំពោះការរក្សាទុកនូវកំណត់ហេតុ ជាពិសេសចំពោះកំណត់ហេតុសម្ងាត់នៃការពិនិត្យរបស់គ្រូពេទ្យ គឺមានតែនៅក្នុងដៃរបស់មន្ត្រីរដ្ឋបាល និងមន្ត្រីសុខាភិបាលតែប៉ុណ្ណោះ ។ មិនមានតុលាការព្រហ្មទណ្ឌអន្តរជាតិណាមួយអនុញ្ញាតឲ្យការិយាល័យស៊ើបអង្កេត ឬស្ថាប័នវិនិច្ឆ័យទទួលបានដោយស្វ័យប្រវត្តិនូវកំណត់ហេតុទាំងនោះទេ ។ អាស្រ័យហេតុនេះ វិធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទំនងជាបង្កើតទំនាស់រវាងតួនាទីជារដ្ឋបាលនិងតួនាទីស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។ យើងអាចគិតបានថា សហចៅក្រហមស៊ើបអង្កេតអាចប្រើប្រាស់ព័ត៌មានទាំងនោះដោយមិនត្រឹមត្រូវនៅក្នុងអំឡុងពេលស៊ើបអង្កេត ។ ការផ្តល់កំណត់ហេតុអំពីព័ត៌មានសំខាន់ខ្លះទៅឲ្យមន្ត្រីស៊ើបអង្កេតអាចបង្កើតជាបញ្ហាមួយ ។ ទោះបីជាអាចមានហេតុផលជាច្រើនសម្រាប់ឲ្យស្ថាប័នរដ្ឋបាលតែមួយដឹងពីព័ត៌មានទាំងនោះក៏ដោយ វានៅតែមានការពិបាកក្នុងការអះអាងថាមន្ត្រីដែលមានមុខងារផ្សេងនៅក្នុងស្ថាប័ននោះអាចទទួលបាននូវ

ឯកសារផ្ទាល់ខ្លួនបែបនេះបាន ។ ដោយផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតនូវការទទួលខុសត្រូវរដ្ឋបាលជាបឋមទាក់ទងនឹងការឃុំខ្លួន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបែងចែកតួនាទីរដ្ឋបាល និងតួនាទីវិនិច្ឆ័យយុត្តិធម៌ដែលមិនអាចដើរជាមួយគ្នាបាន ។

វិធាននៃមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតនូវតួនាទីដ៏សំខាន់នៅក្នុងមន្ទីរឃុំឃាំង ។ ទោះបីជាសហចៅក្រហមស៊ើបអង្កេតមិនមែនជាអ្នកគ្រប់គ្រងមន្ទីរឃុំឃាំងតែម្នាក់ក៏ដោយ ក៏អ្នកទាំងនោះនៅតែមានឆន្ទានុសិទ្ធិធ្វើសេចក្តីសម្រេចភាគច្រើនទៅលើសេចក្តីសម្រេចរដ្ឋបាលមួយដែរ ។ នៅក្នុងឯកសារស្នូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានតែងតាំងឲ្យដំណើរការការិយាល័យរដ្ឋបាល ទេ គឺតែងតាំងឲ្យដឹកនាំការិយាល័យស៊ើបអង្កេត ។ ជាលទ្ធផល វាមានភាពស្រពេចស្រពិលខ្លះចំពោះព្រំដែនរវាងតួនាទីទាំងពីររបស់សហចៅក្រមស៊ើបអង្កេត ។

ភាពស្រពេចស្រពិលនោះត្រូវបានរកឃើញនៅក្នុងនីតិវិធីនៃការត្រួតពិនិត្យទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។ អង្គបុរេជំនុំជម្រះប្រើប្រាស់នូវបទដ្ឋាននៃការពិនិត្យទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទោះបីជាសហចៅក្រមស៊ើបអង្កេតគឺជាអង្គភាពស៊ើបអង្កេតច្បាប់ក៏ដោយ គឺមានការពិនិត្យឡើងវិញសូម្បីតែនៅពេលដែលសហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសម្រេចរដ្ឋបាលដែលពាក់ពន្ធ័ទៅនឹងការឃុំខ្លួនក៏ដោយ ។ ការខ្វះខាតការត្រួតពិនិត្យដោយមន្ត្រីរដ្ឋបាលដូចជា ប្រធានត្រួតពិនិត្យទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត មានន័យថា ការត្រួតពិនិត្យណាក៏ដោយ ក៏ត្រូវតែឆ្លងកាត់ដំណើរនីតិវិធីដ៏យឺត ទោះបីជានៅពេលដែលសេចក្តីសម្រេចនោះមិនពាក់ព័ន្ធនឹងសិទ្ធិទទួលបានការកាត់សេចក្តីដ៏យុត្តិធម៌ក៏ដោយ ។

បន្ថែមពីនេះទៀត ការពិតដែលថាភារកិច្ចរដ្ឋបាលរបស់សហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឲ្យអ្នកទាំងនោះអាចទទួលបាននូវរាល់ឯកសាររបស់អ្នកជាប់ឃុំឃាំង ការសន្ទនាតាមទូរស័ព្ទ និងសំបុត្រអាចបង្កើតជាទំនាស់ផលប្រយោជន៍នឹងតួនាទីស៊ើបអង្កេត ។ ទោះបីជាមិនមានបញ្ហាជម្លោះណាមួយត្រូវបានយកមកផ្សព្វផ្សាយជាសាធារណៈក៏ដោយ ភាពត្រួតគ្នានៃតួនាទីរបស់សហចៅក្រមស៊ើបអង្កេតបានបង្កើតជាបញ្ហាទាក់ទងនឹងលទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តការងារដោយមិនលម្អៀង និងគូសព្រំដែនយ៉ាងច្បាស់មួយរវាងមុខងាររដ្ឋបាល និងកាតព្វកិច្ចជាបឋមក្នុងការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។ **ស្ទីហ្វីនី ខ៉ាង**



# ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់តុលាការ៖ សវនាការបឋមនៃសំណុំរឿង០០២

នៅក្នុងអំឡុងអង្គសវនាការបឋមនៃសំណុំរឿង០០២ ដែលប្រព្រឹត្តឡើងចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ កន្លងទៅនេះ សេង ចុន ដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តព្រៃវែង បាននិយាយថា «នួន ជា គឺជាឧក្រិដ្ឋជន ។ គាត់បានសម្លាប់មនុស្ស ហើយឥឡូវនេះគាត់មិនគោរពតុលាការទៀត» ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី សយ សែន មកពីខេត្តតាកែវ បានត្អូញត្អែរចំពោះការស្នើសុំរបស់ នួន ជា ពាក់វ៉ែនតាការពារកម្តៅថ្ងៃដើម្បីការពារភ្នែកពីពន្លឺ និងពាក់មួករដូវរងាដើម្បីការពារខ្យល់ត្រជាក់នៃម៉ាស៊ីនត្រជាក់នៅក្នុងបន្ទប់អង្គសវនាការ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះខកចិត្តយ៉ាងខ្លាំង នៅពេលដែលឃើញជនជាប់ចោទទាំងបួនដែលជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមជិតាស់តតាំង និងចាកចេញពីបន្ទប់សវនាការស្ទើរតែរាល់ពេលដោយផ្អែកលើមូលហេតុផ្សេងៗ ។ ចាន់ កិ ដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តព្រៃវែងក៏បាននិយាយថា «ជនជាប់ចោទផ្សេងទៀតបានចាកចេញពីបន្ទប់សវនាការ លើកលែងតែ ខៀវ សំផន។ នៅថ្ងៃចុងបញ្ចប់នៃអង្គសវនាការបឋមនេះ យើងសង្កេតឃើញមានតែជនរងគ្រោះទេដែលមានវត្តមាននៅក្នុងបន្ទប់សវនាការតែប៉ុណ្ណោះ» ។ ចាន់ កិ ក៏បានបញ្ចេញអារម្មណ៍មិនពេញចិត្តចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងបន្ទប់សវនាការដែលជនជាប់ចោទភាគច្រើនសុទ្ធតែអវត្តមាននៅថ្ងៃដំបូងៗនៃដំណើរការអង្គសវនាការបឋមនេះ ។

ថ្ងៃទី២៧ ខែមិថុនា គឺជាថ្ងៃដំបូងនៃអង្គសវនាការដ៏មានសារសំខាន់ និងជាលក្ខណៈប្រវត្តិសាស្ត្ររបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដំណើរការនីតិវិធីចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា មានលក្ខណៈជាអង្គនីតិវិធីតាមផ្លូវច្បាប់សុទ្ធសាធ ដូច្នេះគ្មានអង្គហេតុណាមួយត្រូវបានលើកឡើងឡើយ បើទោះបីជាភាគីទាំងអស់ដែលចូលរួមនៅក្នុងអង្គសវនាការនេះបានពិភាក្សាពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទូទៅរបស់ប្រទេសកម្ពុជា ជាពិសេសគឺនៅក្នុងអំឡុងពេលក្រោយរបបខ្មែរក្រហមក៏ដោយ ។

យ៉ាងណាមិញ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យបណ្តឹង និងសាធារណជនទាំងមូលបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើអង្គសវនាការបឋមនេះ ពីព្រោះថាអ្នកទាំងអស់នេះបានឃើញមុខជនជាប់ចោទផ្ទាល់ដែលជនជាប់ចោទទាំងអស់នេះមានមុខ


សយ សែន

តំណែងខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងឱកាសនេះ គម្រោងគាំទ្រការចូលរួមរបស់ជនរងគ្រោះ និង គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២ចំនួនដប់ប្រាំនាក់ និងសកម្មជនតាមសហគមន៍ចំនួនម្ភៃប្រាំនាក់ឲ្យចូលរួមតាមដានដំណើរការនីតិវិធីដ៏សំខាន់បំផុតនេះនៅតុលាការខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះបានមកជួបជុំគ្នានៅថ្ងៃទី២៦ ខែមិថុនា ហើយបានជួបពិភាក្សាជាមួយនឹងមេធាវីរបស់ខ្លួនមុននឹងដំណើរការនីតិវិធីរបស់តុលាការចាប់ផ្តើម ។ នៅថ្ងៃទី៣០ ខែមិថុនា ដែលជាថ្ងៃចុងបញ្ចប់នៃអង្គសវនាការបឋមនេះ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះក៏បានជួបជាមួយនឹងមេធាវីរបស់ខ្លួនម្តងទៀតដែរ ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបរាប់ពីសារ

សំខាន់នៃអង្គជំនុំជម្រះក្តីរបស់មេដឹកនាំជាន់ខ្ពស់ដែលនឹងរំពឹងថា ដំណើរការនាពេលខាងមុខនេះ និងពីជាប្រធានបទដែលនឹងត្រូវយកមកជជែកដេញដោលដោយចៅក្រម មេធាវីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជូនដល់អ្នកដាក់ពាក្យប្តឹងទាំងអស់គ្នាបានដឹង ។

អង្គសវនាការនេះត្រូវបានចាត់ទុកថាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជា ។ ប្រទេសជាច្រើនដូចជាសហរដ្ឋអាមេរិក និងប្រទេសបារាំងដែលជាម្ចាស់មូលនិធិ និងជាដៃគូរបស់តុលាការខ្មែរក្រហមបានអបអរសាទរចំពោះការចាប់ផ្តើមដំណើរការនីតិវិធីនេះ ។ ជាក់ស្តែង លោក ស៊ីហ៊ិន រ៉ាហ្ អគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិកសម្រាប់ខក្រិដ្ឋកម្មសង្គ្រាមបានចាត់ទុកអង្គសវនាការនេះថាជា «អង្គសវនាការដ៏មានសារសំខាន់បំផុតនៅក្នុងពិភពលោក» ។ ដោយឡែក សំណួរជាច្រើនដែលត្រូវបានលើកឡើងយកមកពិភាក្សាក្នុងអង្គសវនាការនេះរួមមានសុពលភាពរបស់តុលាការប្រជាជនបដិវត្តន៍ ព្រះរាជទានទោស និងការលើកលែងទោសរបស់ អៀង សារី និងបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ ។

## ជនជាប់ចោទបដិសេធមិនចូលរួមអង្គសវនាការបឋម

នៅថ្ងៃទី២៧ ខែមិថុនា ថ្ងៃដំបូងនៃអង្គសវនាការបឋមនេះ នួន ជា បាននិយាយថា «ខ្ញុំមិនសប្បាយចិត្តនឹងអង្គសវនាការនេះទេ» ។ ការថ្លែងរបស់ នួន ជា គឺជាការប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនឲ្យមានការបដិសេធបឋមដែលត្រូវបានស្នើសុំឲ្យធ្វើឡើងនៅក្នុងរបៀបវារៈនៃអង្គសវនាការបឋមនេះ ។ មុននេះ នួន ជា និងមេធាវីការពារក្តីរបស់ខ្លួនបានស្នើសុំឲ្យដាក់បញ្ចូលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ក្នុងអំឡុងពេលមុនការឡើងកាន់អំណាចរបស់ខ្មែរក្រហមដែលក្នុងនោះរួមមានការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិកនៅលើទឹកដីប្រទេសកម្ពុជា និងការមកដល់របស់កងយោធាវៀតណាមនៅក្នុងប្រទេសកម្ពុជាក្រោយពីការដួលរលំនៃរបបខ្មែរក្រហមចូលទៅក្នុងរបៀបវារៈនៃអង្គសវនាការនេះ ។ ជាមួយគ្នានេះ ក្រុមមេធាវីការពារក្តីរបស់ នួន ជា ក៏បានស្នើសុំឲ្យមានការពិភាក្សាជាសាធារណៈចំពោះរឿងបញ្ជីរាយនាមសាក្សី ។ នេះឆ្លុះបញ្ចាំងឲ្យ



លោក ស៊ីហ៊ិន រ៉ាហ្ និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខារ៉ូល រ៉ដលី ចូលរួមស្តាប់សវនាការបឋមនៅសាលាក្តីខ្មែរក្រហមនៅថ្ងៃទី២៧ ខែមិថុនា

ឃើញយ៉ាងច្បាស់ថា គោលបំណងរបស់ក្រុមមេធាវីការពារក្តី នួន ជា គឺនាំយកបញ្ហារសើបផ្នែកនយោបាយដែលឋិតនៅក្រៅយុត្តាធិការអាជ្ញាយុកាលរបស់តុលាការខ្មែរក្រហមមកជជែកដេញដោលនៅក្នុងអង្គសវនាការបឋមនេះ ។ បន្ថែមលើនេះ ក្រុមមេធាវីការពារក្តីរបស់ នួន ជា ក៏មានបំណងចង់ពិភាក្សាពីអ្នកនយោបាយមួយចំនួនដែលមានមុខតំណែងនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន និងសាក្សីដែលក្រុមមេធាវីនេះជឿថាបានដឹងឮពីព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងគោលនយោបាយ និងបញ្ហារដ្ឋាបាលរបស់ខ្មែរក្រហម ។ ជាក់ស្តែង ការិយាល័យសហចៅក្រមស៊ើបអង្កេតបានកោះហៅអ្នកនយោបាយចំនួនប្រាំមួយនាក់ ដែលមានមុខតំណែងនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នឲ្យចូលខ្លួនផ្តល់ភស្តុតាងនៅចំពោះមុខតុលាការខ្មែរក្រហមរួចហើយ ប៉ុន្តែកិច្ចខិតប្រឹងប្រែងនេះមិនទទួលបានការសហការពីអ្នកនយោបាយទាំងប្រាំមួយនាក់នោះទេ ។ វាទំនងជាថា យុត្តិសាស្ត្ររបស់ក្រុមមេធាវីការពារក្តី នួន ជា គឺដើម្បីបង្ហាញថា តុលាការខ្មែរក្រហមកំពុងទទួលការជ្រៀតជ្រែកផ្នែកបញ្ហានយោបាយពីសំណាក់ប្រទេសកម្ពុជា ហេតុដូច្នេះ នួន ជា មិនអាចទទួលបានអង្គជំនុំជម្រះក្តីដែលប្រកបដោយយុត្តិធម៌ទេ ។

ការស្នើសុំរបស់ នួន ជា និងក្រុមមេធាវីរបស់ខ្លួនត្រូវបានបដិសេធមិនទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង ដោយសាររបៀបវារៈនៃអង្គសវនាការបឋមនេះត្រូវបានសម្រេចរួចរាល់ហើយ ដូច្នេះ ការជជែកពិភាក្សានៅក្នុងអង្គសវនាការនេះត្រូវតែទាក់ទងនឹងប្រធានបទដែលមានចែងនៅក្នុងរបៀបវារៈនោះ ។ ជាការជំទាស់នឹងសេចក្តីសម្រេចនេះ នួន ជា បានស្នើសុំវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញជារៀងរាល់ព្រឹកនៃដំណើរការទាំងមូលរបស់អង្គសវនាការបឋមនេះ ដោយអះអាងថា របៀបវារៈដែលរៀបចំដោយអង្គជំនុំជម្រះសាលាដំបូងមានជាប់ពាក់ព័ន្ធនឹងតែរឿងក្តីរបស់ អៀង សារី មិនមែនរឿងក្តីរបស់គាត់ទេ ។ ដូច្នេះ នួន ជា ក៏បានជម្រាបចៅក្រមថាខ្លួននឹងមានវត្តមាននៅក្នុងបន្ទប់សវនាការនេះ លុះត្រាតែរបៀបវារៈនៃអង្គសវនាការបឋមនេះមានជាប់ពាក់ព័ន្ធនឹងបញ្ហារឿងក្តីរបស់គាត់ ។ មិនមែនមានតែជនជាប់ចោទ នួន ជា ម្នាក់ទេដែលបានស្នើសុំចៅក្រមវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញ ក្នុងនោះក៏មានជនជាប់ចោទ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ដែរ ។ ខុសពីជនជាប់ចោទ នួន ជា ដែលបានបដិសេធយ៉ាងដាច់ខាតនោះ ជនជាប់ចោទបីរូបផ្សេងទៀតគ្រាន់តែលើកយកសិទ្ធិបដិសេធមិនចូលរួមអង្គសវនាការមកប្រើប្រាស់តែប៉ុណ្ណោះ ។ ការអវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការបានជំរុញឲ្យចៅក្រមបដិសេធមិនអនុញ្ញាតឲ្យជនជាប់ចោទវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញឡើយ ។ សេចក្តីសម្រេចបែបនេះបានធ្វើឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទជំទាស់ដោយអះអាងថា នេះគឺជាសិទ្ធិ និងសេចក្តីសម្រេចរបស់ជនជាប់ចោទក្នុងការបដិសេធមិនចូលរួមក្នុងអង្គសវនាការ ។ បន្ទាប់មកទៀត ចៅក្រមបានសម្រេចថា ជនជាប់ចោទទាំងអស់ត្រូវតែមានវត្តមាននៅក្នុងអង្គសវនាការ ហើយអាចវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញបានលុះត្រាតែជនជាប់ចោទមានហេតុផលសមរម្យបំផុត ។ យ៉ាងណាមិញ ពីមួយថ្ងៃទៅមួយថ្ងៃ ការស្នើសុំរបស់ នួន ជា ដើម្បីវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញកាន់តែមានសភាពទន់ភ្លន់ទៅៗ ។ លោក និល ណុន ប្រធានចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោះស្រាយបញ្ហាស្នើសុំរបស់ជនជាប់ចោទដើម្បីវិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ខ្លួនវិញ ។

ជាពិសេសទាក់ទងនឹងរឿងក្តីរបស់ នួន ជា តុលាការខ្មែរក្រហមបានព្យាយាមស្វែងរកឯកសារដែលសរសេរឡើងដោយអ្នកសារព័ត៌មានម្នាក់គឺលោក ថេត សម្បត្តិ ។ នៅក្នុងភាពយន្តឯកសារដែលមានចំណងជើងថា «សត្រូវរបស់ប្រជាជន» មានផ្ទុកនូវចម្លើយសារភាពរបស់ នួន ជា ពីការដឹងឮរបស់ នួន ជា ទាក់ទងនឹងការសម្លាប់ និងការព្យាបាទលើជនក្បត់នៃរបបខ្មែរក្រហម ។ គោលបំណងរបស់តុលាការខ្មែរក្រហម មិនទទួលបានជោគជ័យទេ ដោយសារតែអ្នកសារព័ត៌មាន ថេត សម្បត្តិ បានបដិសេធមិនប្រគល់ជូនខ្សែភាពយន្តឯកសារនោះទេ ដោយអះអាងថាលោកបានសន្យាថានឹងមិនបោកប្រាស់ជំនឿទុកចិត្តរបស់ នួន ជា ដែលមានចំពោះរូបលោកជាដាច់ខាត ។ លោក ថេត សម្បត្តិ បាននិយាយនៅក្នុងវិទ្យុសំឡេងសហរដ្ឋអាមេរិកកាលពីថ្ងៃទី២៨ ខែមិថុនា ថា «ប្រសិនបើខ្ញុំប្រគល់ខ្សែភាពយន្តឯកសារនេះទៅឲ្យ

តុលាការ នោះមានន័យថាខ្ញុំបានបោកប្រាស» នួន ជា និង កម្មាភិបាលខ្មែរក្រហមដទៃទៀតដែលបានយល់ព្រមផ្តល់ចម្លើយ សារភាពនៅក្នុងខ្សែភាពយន្តឯកសារនេះ ។

## តុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩

នៅក្នុងអង្គជំនុំជម្រះក្តីដ៏ក្តៅគគុកកាលពីខែសីហា ឆ្នាំ ១៩៧៩ អៀង សារី និង ប៉ុល ពត ត្រូវបានចោទប្រកាន់ពី បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយត្រូវបានកាត់ទោស ប្រហារជីវិត និងរឹបអូសយកទ្រព្យសម្បត្តិទាំងអស់ ។ ជាក់ស្តែង សមាសធាតុទាំងអស់នៃសាលក្រមនោះមិនត្រូវបានអនុវត្តទាល់ តែសោះ ។ ផ្ទុយទៅវិញ អៀង សារី និង ប៉ុល ពត បែរជា បានធ្វើសង្គ្រាមស៊ីវិលជាមួយនឹងរដ្ឋាភិបាលថ្មី ស្របពេលដែល សាលក្រមត្រូវបានប្រកាស ហើយថែមទាំងបានកេងប្រវ័ញ្ច កាប់ព្រៃក្រាស់ និងជីកត្បូងមានតម្លៃនៅក្នុងប្រទេសកម្ពុជារហូត មកដល់ទសវត្សរ៍៩០ ។ អៀង សារី បានកើបប្រមូលទ្រព្យសម្បត្តិ នៅតាមព្រំដែនថៃទៅវិញ ជំនួសឲ្យការកាត់ទោសប្រហារជីវិត និងការរឹបអូសយកទ្រព្យសម្បត្តិដោយតុលាការប្រជាជនបដិវត្តន៍ នេះ ។

តុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩ បានចាប់ផ្តើម អង្គជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ដែលត្រូវ បានបង្កើតឡើងមុនដំបូងគេបង្អស់នៅក្នុងពិភពលោកដែលមាន អាណត្តិរយៈពេលសរុបចំនួនប្រាំថ្ងៃតែប៉ុណ្ណោះ ។ យោងតាម ការបកស្រាយរបស់លោកសហព្រះរាជអាជ្ញា អេនឌ្រូ ខេលី នៅ ឯតុលាការខ្មែរក្រហមបានឲ្យដឹងថា អង្គជំនុំជម្រះរបស់តុលាការ ប្រជាជនបដិវត្តន៍មិនបានអនុវត្តទៅតាមបទដ្ឋានមូលដ្ឋានយុត្តិធម៌ ឡើយ ។ តុលាការនេះត្រូវបានបង្កើតឡើងដោយក្រឹត្យច្បាប់ ដែលចេញដោយអំណាចនីតិប្រតិបត្តិ ។ លើសពីនេះ សមាជិក បីរូបរបស់តុលាការនេះដែលរួមទាំងប្រធានចៅក្រមគឺសុទ្ធតែ ជាសមាជិករបស់រដ្ឋាភិបាលថ្មី ។ តុលាការនេះបានឈានដល់ ដំណាក់កាលចេញសាលក្រមកាត់ទោសដោយចំណាយពេល ត្រឹមតែម្ភៃថ្ងៃប៉ុណ្ណោះ ដែលរយៈពេលម្ភៃថ្ងៃនោះរាប់បញ្ចូលទាំង រយៈពេលសម្រាប់ដំណើរការស៊ើបអង្កេតដែរ ។ ពិបាកជាងនេះ មេធាវីការពារក្តីជនជាប់ចោទបែរជាឡើងមានមតិគាំទ្រអំណះ អំណាងរបស់ព្រះរាជអាជ្ញា ជួសឲ្យការការពារក្តីរបស់ជនជាប់ ចោទទៅវិញ ។ ចុងក្រោយបង្អស់នោះគឺថាសាលក្រមនេះត្រូវ បានសម្រេចទុកជាមុនយូរមកហើយ ។ យោងតាមហេតុផលទាំង អស់នេះ សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានអះអាងថា ការនាំយក អៀង សារី មកកាត់ទោសនៅចំពោះមុខតុលាការ ខ្មែរក្រហម ពិតជាត្រឹមត្រូវតាមផ្លូវច្បាប់ ដោយសារតែភាពមិន ជឿទុកចិត្តទាំងឡាយដែលកើតមាននៅក្នុងដំណើរការកាត់ទោស របស់តុលាការប្រជាជនបដិវត្តន៍ ។ យ៉ាងណាមិញ មេធាវីការពារក្តី របស់ អៀង សារី បានជំទាស់ថា អៀង សារី ត្រូវបានកាត់ទោស រួចម្តងហើយ ដូច្នេះ អៀង សារី មិនអាចត្រូវកាត់ទោសម្តងទៀត សម្រាប់ឧក្រិដ្ឋកម្មដូចគ្នាទាំងអស់នេះទេ ។ បន្ថែមលើនោះ មេធាវី ការពារក្តីជាតិរបស់ អៀង ធីរិទ្ធ បាននិយាយថា តុលាការ ប្រជាជនបដិវត្តន៍បានបំពេញកិច្ចការដ៏ល្អបំផុតដែលតុលាការ អាចសម្រេចបាននៅអំឡុងពេលនោះ ពីព្រោះនាអំឡុងពេល នោះប្រទេសកម្ពុជាកំពុងទទួលរងការបំផ្លិចបំផ្លាញដ៏ធ្ងន់ធ្ងរលើ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងធនធានផ្សេងៗ ។

## ព្រះរាជទានទោស និងការលើកលែងទោសឆ្នាំ១៩៩៦

ជាការឆ្លើយតបនឹងការស្នើសុំរបស់សហនាយករដ្ឋមន្ត្រី នាអំឡុងពេលនោះ សម្តេច នរោត្តម សីហនុ បានឡាយព្រះហស្ត លេខាលើព្រះរាជក្រឹត្យមួយដែលបានប្រទានព្រះរាជទានទោស និងការលើកលែងទោសដល់ អៀង សារី ។ ប្រធានបទស្តីពី ព្រះរាជទានទោស និងការលើកលែងទោសនេះត្រូវបានលើកយក មកជជែកដេញដោលយ៉ាងក្តៅគគុកនៅក្នុងអំឡុងថ្ងៃទីពីរនៃអង្គ សវនាការបឋមនេះ ។ យោងតាមសម្តីរបស់មេធាវីការពារក្តី ព្រះរាជក្រឹត្យឆ្នាំ១៩៩៦នេះបានលើកលែងទោសឲ្យ អៀង សារី ពីការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៧៩ ហើយព្រះរាជទានទោសឲ្យ អៀង សារី រួចផុតពីការ កាត់ទោសបន្ថែមផ្សេងៗទៀត ។ អៀង សារី មិនអាចត្រូវបាន កាត់ទោសដោយផ្អែកលើអង្គហេតុដែលថា អៀង សារី គឺជា សមាជិករបស់អង្គភាពខ្មែរក្រហម និងការចោទប្រកាន់ទាំងឡាយ របស់តុលាការខ្មែរក្រហមបានដែរ ។ មេធាវីការពារក្តីបាន អះអាងថា នៅពេលដែល អៀង សារី បានចុះចូលជាមួយនឹង

រដ្ឋាភិបាលកម្ពុជាថ្មីកាលពីឆ្នាំ១៩៩៦ កិច្ចសន្យាមួយត្រូវបានសម្រេចរួចមុនទៅហើយ ។ កិច្ចសន្យាមួយនោះចែងថា អៀង សារី នឹងមិនត្រូវបានកាត់ទោសពីបទរំលោភច្បាប់ឆ្នាំ១៩៩៤ ដែលបានចាត់ទុករបបខ្មែរក្រហមជារបបដែលរំលោភបំពានផ្លូវច្បាប់ និងពីបទចោទប្រកាន់ផ្សេងៗទៀតឡើយ ។ មេធាវីការពារក្តីបានបន្តអះអាងថា ការចុះចូលរបស់ អៀង សារី ជាមួយនឹងរដ្ឋាភិបាលថ្មី បាននាំមកនូវការដួលរលំនៃរបបខ្មែរក្រហម ហើយនាំមកនូវសន្តិភាពដល់ប្រទេសកម្ពុជា ។ ប្រសិនបើ អៀង សារី មិនចុះចូលជាមួយនឹងរដ្ឋាភិបាលទេ នោះប្រទេសកម្ពុជាប្រហែលជានៅតែវក់វីជាមួយនឹងសង្គ្រាមស៊ីវិលជាពុំខាន ។ ជាចុងក្រោយ មេធាវីការពារក្តីរបស់ អៀង សារី បាននិយាយថាព្រះរាជក្រឹត្យឆ្នាំ១៩៩៦មានសុពលភាព ហើយថាតុលាការខ្មែរក្រហមគ្មានយុត្តាធិការផ្ទាល់ដើម្បីកាត់ទោស អៀង សារី ឡើយ ។ នេះមានន័យថា អៀង សារី ត្រូវតែដោះលែងឲ្យមានសេរីភាព ។

សហព្រះរាជអាជ្ញាបានជំទាស់ថា ព្រះរាជទានទោសត្រូវបានធ្វើឡើងដើម្បីការពារ អៀង សារី ពីការចោទប្រកាន់ឆ្នាំ១៩៧៩ ហើយការលើកលែងទោសគឺដើម្បីការពារ អៀង សារី ឲ្យរួចផុតពីការកាត់ទោសសម្រាប់តែការរំលោភបំពានរបស់ អៀង សារី លើច្បាប់ឆ្នាំ១៩៩៤តែប៉ុណ្ណោះ ។ ច្បាប់ឆ្នាំ១៩៩៤ ចែងថាខ្មែរក្រហមដែលចុះចូលជាមួយនឹងរដ្ឋាភិបាលថ្មីអាចនឹងមិនត្រូវបានកាត់ទោសសម្រាប់ការធ្លាប់ចូលរួមបម្រើឲ្យរបបខ្មែរក្រហមក្នុងរយៈពេលកំណត់ប្រាំមួយខែ ។ យោងតាមសហព្រះរាជអាជ្ញា ការលើកលែងទោសគឺធ្វើការអត់ឱនទោស អៀង សារី សម្រាប់ការរំលោភបំពានរបស់ អៀង សារី ទៅលើច្បាប់ឆ្នាំ១៩៩៤ មិនមែនលើកលែងទោសឲ្យសកម្មភាពរបស់ អៀង សារី នៅក្នុងអំឡុងរបបខ្មែរក្រហមឡើយ ។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងសម្រេចថាទោះបីជាការលើកលែងទោសពិតជាការពារ អៀង សារី ពីការកាត់ទោសក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែមានឆន្ទានុសិទ្ធិក្នុងការស៊ើបអង្កេតលើការលើកលែងទោសនោះដែរ ។ យោងតាមសហព្រះរាជអាជ្ញា តុលាការខ្មែរក្រហមគឺជា «តុលាការមានបទដ្ឋានអន្តរជាតិ» ហើយក៏គ្មានការលើកលែងទោសណាអាចគេចផុតពីការកាត់ទោសពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រអំណះអំណាងរបស់សហព្រះរាជអាជ្ញាដោយអះអាងបន្ថែមទៀតថា ប្រសិនបើជនជាប់ចោទ អៀង សារី ត្រូវបានដោះលែងឲ្យមានសេរីភាព នោះសិទ្ធិក្នុងការស្វែងរកការពិត និងសិទ្ធិទទួលបានសំណងដ៏មានប្រសិទ្ធភាពមួយរបស់ជនរងគ្រោះដែលមានចែងនៅក្នុងច្បាប់អន្តរជាតិនឹងត្រូវបានរំលោភបំពាន ។ បញ្ហានេះឆ្លុះបញ្ចាំងពីស្ថានភាពកាលពីឆ្នាំ១៩៩៦ជាពេលដែល អៀង សារី បានគ្រប់គ្រងតំបន់ប៉ៃលិន ។ ក្នុងអំឡុងឆ្នាំនោះ អៀង សារី និងខ្មែរក្រហមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អៀង សារី កំពុងតែវាយប្រយុទ្ធជាមួយនឹងរដ្ឋាភិបាល ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អៀង សារី «ទទួលបាន» ការលើកលែងទោសនៅឆ្នាំ១៩៩៦ ជាថ្នូរដោះដូរសម្រាប់ការចុះចូលរបស់ អៀង សារី ជាមួយនឹងរដ្ឋាភិបាលតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត នាពេលនោះរដ្ឋាភិបាលត្រូវបានបង្ខំឲ្យផ្តល់ការលើកលែងទោសឲ្យ អៀង សារី ដើម្បីជាការដោះដូរយកសន្តិភាពដែលត្រូវការយ៉ាងចាំបាច់នាពេលនោះ ។ ចាន់ កិ បាននិយាយថា


ដូនជី និងអ្នកភូមិកំពុងដើរចូលក្នុងបន្ទប់សវនាការ

«ខ្ញុំយល់ថាវាពិតជាមានសារសំខាន់ដើម្បីបញ្ចប់សង្គ្រាម...ហើយស្ថានភាពបែបនោះជំរុញឲ្យរដ្ឋាភិបាលផ្តល់ការលើកលែងទោសឲ្យ អៀង សារី បែបនោះទៅ»។ ប្រសិនបើយើងក្រឡេកមកមើលអំឡុងពេលនៃកិច្ចចរចាវិញយើងឃើញថា នៅពេលដែលកិច្ចសន្យាត្រូវបានព្រមព្រៀងកាលពីឆ្នាំ១៩៩៦នោះ គ្មាននរណាម្នាក់រួមទាំង អៀង សារី អាចនឹកស្មានដល់ថាតុលាការខ្មែរក្រហមនេះអាចនឹងត្រូវបានបង្កើតឡើងនោះទេ។

ព្រះរាជក្រឹត្យដែលចុះនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ «បានដោះលែង អៀង សារី...ឲ្យរួចផុតពីទណ្ឌកម្មប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិស្របតាមសាលក្រម...ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ និងរួចផុតពីទណ្ឌកម្មដែលមានចែងនៅក្នុងច្បាប់ដែលដាក់សមាជិកនៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់...ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤»។ ខ្លឹមសារនៃព្រះរាជក្រឹត្យនេះមានន័យថា អៀង សារី មិនអាចត្រូវបានដាក់ទណ្ឌកម្មសម្រាប់កាលដែលថា អៀង សារី គឺជាសមាជិករបស់ក្រុមដែលត្រូវបានដាក់ឲ្យនៅក្រៅច្បាប់ដែលបានប្រយុទ្ធប្រឆាំងជាមួយនឹងរដ្ឋាភិបាលបានទេ។ ច្បាប់ឆ្នាំ១៩៩៤ដោះស្រាយបញ្ហាទាំងអស់ដែលមានជាប់ទាក់ទងនឹងសកម្មភាពប្រយុទ្ធប្រឆាំងរបស់ខ្មែរក្រហមជាមួយនឹងរដ្ឋាភិបាលថ្មីដែលខ្មែរក្រហមបានអូសបន្លាយការតស៊ូប្រដាប់អាវុធរបស់ខ្លួនជាមួយនឹងរដ្ឋាភិបាលរហូតដល់ពេលដែល អៀង សារី បានយល់ព្រមចុះចូលជាមួយរដ្ឋាភិបាល។ ច្បាប់នេះគ្មានចែងពីការកាត់ទោសម្រាប់បទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមឡើយ។ ដូច្នេះ វាគួរឲ្យកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងគួរតែធ្វើការពិចារណាលើការពិតដែលថា ការកាត់ទោសរបស់ អៀង សារី កាលពីឆ្នាំ១៩៧៩មិនបានបំពេញទៅតាមបទដ្ឋានមូលដ្ឋានយុត្តិធម៌ និងដំណើរការសមស្របនៃច្បាប់ទេ ហេតុដូចនេះ ព្រះរាជក្រឹត្យនេះមិនអាចការពារ អៀង សារី ឲ្យរួចផុតពីការកាត់ទោសនៅចំពោះមុខតុលាការខ្មែរក្រហមដែលអ្នករាល់គ្នាមិននឹកស្មានថាតុលាការនេះអាចនឹងត្រូវបានបង្កើតឡើងនោះ។

ជាការគាំទ្រដល់អំណះអំណាងរបស់ព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យចៅក្រមសម្រេចថាព្រះរាជក្រឹត្យឆ្នាំ១៩៩៦មិនការពារ អៀង សារី ឲ្យរួចផុតពីការកាត់ទោសនៅចំពោះមុខតុលាការខ្មែរក្រហមបានឡើយ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថាជនរងគ្រោះអាចនឹងត្រូវបានរំលោភបំពានសិទ្ធិក្នុងការទទួលបានយុត្តិធម៌ សិទ្ធិក្នុងការស្វែងរកសំណងជំងឺសមរម្យមួយ និង សិទ្ធិស្វែងរកការពិត ប្រសិនបើ អៀង សារី មិនត្រូវបាននាំមកកាត់ទោសនៅចំពោះមុខតុលាការខ្មែរក្រហម។

ជាក់ស្តែង បញ្ហាព្រះរាជទានទោស និងការលើកលែងទោសសម្រាប់ អៀង សារី ត្រូវបានលើកឡើងនៅក្នុងអំឡុងពេលកិច្ចចចារវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិរួចម្តងហើយ។ ប៉ុន្តែគ្មានដំណោះស្រាយណាមួយត្រូវបានសម្រេចដើម្បីដោះស្រាយបញ្ហាការលើកលែងទោសរបស់ អៀង សារី ទេ។ ហើយបញ្ហានេះត្រូវបានទុកឲ្យតុលាការខ្មែរក្រហមជាអ្នកសម្រេចដោះស្រាយ ក្រោយពីកិច្ចចរចាដ៏វែងអន្លាយនេះត្រូវបានបញ្ចប់ទៅ។ ដោយឡែក អង្គបុរេជំនុំជម្រះបានសម្រេចថាការលើកលែងទោសនេះមិនបានជួយការពារ អៀង សារី ឲ្យរួចផុតពីការកាត់ទោសបានទេ ហើយបញ្ហាដដែលនេះត្រូវបានលើកយកមកពិភាក្សាសារជាថ្មីម្តងទៀតនៅចំពោះអង្គជំនុំជម្រះសាលាដំបូង។ មានការរំពឹងទុកថា បញ្ហាដដែលនេះអាចនឹងត្រូវលើកយកមកជជែកដេញដោលម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ បញ្ហានេះត្រូវបានជឿថាជាការបរាជ័យមួយរបស់ប្រព័ន្ធច្បាប់ស៊ីវិលក្នុងការដោះស្រាយបទឧក្រិដ្ឋកម្មធ្ងន់បែបនេះ។ ដំណើរការនីតិវិធីបានប្រឈមមុខនឹងបញ្ហាដូចគ្នាដដែលៗ ដែលត្រូវតែដោះស្រាយតាមដំណាក់កាលនីមួយៗរបស់អង្គនីតិវិធី ហើយដែលត្រូវបានដោះស្រាយតាំងពីមុនពេលដែលតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងទៅទៀត។ ដំណើរការនេះទាមទារពេលវេលាយូរ ដែលតុលាការខ្មែរក្រហមមិនមានធនធានគ្រប់គ្រាន់សម្រាប់បន្តដំណើរការវែងបែបនេះទេ។

## ការចូលរួមរបស់ជនរងគ្រោះ

កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានទទួលយកអ្នកដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៧៨២នាក់បន្ថែមទៀតដែលធ្វើឲ្យចំនួនដើម

បណ្តឹងរដ្ឋប្បវេណីសរុបនៅក្នុងសំណុំរឿង០០២នេះកើនឡើងដល់ ៣៨៥០នាក់ ។ នេះគឺជាជោគជ័យមួយសម្រាប់ជនរងគ្រោះ និង សម្រាប់អ្នកដែលធ្វើកិច្ចការជួយជនរងគ្រោះ ។ ស្របពេលដែល មតិខ្លះបានចាត់ទុកការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីបន្ថែម ទៀតនេះជាជោគជ័យសម្រាប់ជនរងគ្រោះក៏ដោយ ក៏មានមតិ មួយចំនួននៅតែបង្ហាញពីការព្រួយបារម្ភដដែល ។ អ្នកអត្ថាធិប្បាយខ្លះបានជឿថាអង្គបុរេជំនុំជម្រះបានធ្វើការបកស្រាយ ពាក្យ «ជនរងគ្រោះ» ក្នុងន័យទូលំទូលាយពេក ។ ដូច្នេះ ការ ព្រួយបារម្ភខាងលើគឺទាក់ទងទៅនឹងការគាំពារដើមបណ្តឹងរដ្ឋប្បវេណីដ៏ច្រើន និងគុណភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ ។ ស្របពេលដែលមូលនិធិឧបត្ថម្ភរបស់ អង្គការក្រៅរដ្ឋាភិបាលដែលបំពេញកិច្ចការជួយជនរងគ្រោះកាន់ តែខ្វះខាតទៅ ផ្នែកគាំពារជនរងគ្រោះរបស់តុលាការក៏កំពុង ប្រឈមមុខនឹងបញ្ហាថវិកា និងមូលនិធិឧបត្ថម្ភដូចគ្នាដែរ ។ ដោយ សារតែបញ្ហាពេលវេលា និងបញ្ហាធនធាន មេធាវីដើមបណ្តឹង រដ្ឋប្បវេណីមិនអាចផ្តល់ប្រឹក្សាដល់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ បានទេ ។ ហេតុដូចនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជ្រើសយក ការជួបប្រជុំជាក្រុមជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីជំនួសវិញ ។ ការផ្តល់ប្រឹក្សាក្នុងសណ្ឋានបែបនេះគឺជាការព្រួយបារម្ភមួយនៅ ក្នុងដំណើរការនីតិវិធីនៃសំណុំរឿង០០២ ។

សហប្រធានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជា អនុសាសន៍ខ្លះជាសំណើបឋមទាក់ទងនឹងសំណងសម្រាប់ជនរង គ្រោះ ។ សំណើទាំងអស់នោះរួមមាន ៖ ថ្ងៃនៃការចងចាំ បូជនីយដ្ឋានតម្កល់អដ្ឋិធាតុ សេវាកម្មថែទាំសុខភាពផ្លូវកាយ និងផ្លូវ ចិត្តឲ្យជនរងគ្រោះដោយឥតគិតថ្លៃ ការចងក្រងឈ្មោះជនរង គ្រោះ មូលនិធិឧបត្ថម្ភជនរងគ្រោះ និងការចែកចាយសាលក្រម នៃសំណុំរឿង០០២ ។ ទាំងនេះគឺជាព័ត៌មានបឋមស្តីពីសំណើ សម្រាប់សំណងរបស់ជនរងគ្រោះ ។ បន្ថែមលើនេះ សហប្រធាន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏បានជម្រាបអង្គជំនុំជម្រះសាលាដំបូងថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពេលវេលាបន្ថែម ទៀតដើម្បីប្រឹក្សាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបាន ទទួលស្គាល់ថ្មីៗនេះ មុននឹងសំណើចុងក្រោយទាក់ទងនឹងសំណង របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ជូនឲ្យអង្គជំនុំជម្រះ សាលាដំបូងនាពេលខាងមុខនៃដំណើរការនីតិវិធីរបស់តុលាការ ។

អង្គសវនាការបឋមនេះគឺជាការពិសោធន៍នៃយន្តការថ្មី មួយដែលត្រូវបានដាក់តែងឡើង ដើម្បីសម្រួលដល់ដំណើរការ ដ៏ស្មុគស្មាញនៃការចូលរួមរបស់ជនរងគ្រោះនៅឯតុលាការខ្មែរ ក្រហមនៅក្នុងអំឡុងអង្គជំនុំជម្រះសំណុំរឿង០០២ ។ សហ ប្រធានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតែងតាំងឡើង ដើម្បីធ្វើជាតំណាងបម្រើឲ្យប្រយោជន៍របស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណីទាំងអស់នៅចំពោះមុខតុលាការខ្មែរក្រហម ។ កិច្ចការ របស់សហប្រធានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺធ្វើជាតំណាងឲ្យ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ យន្តការថ្មីនេះត្រូវបាន តាក់តែងឡើងដើម្បីបង្កើនល្បឿនអង្គនីតិវិធីរបស់តុលាការ និង ចៀសវាងការលើកឡើងអំណះអំណាងដដែលៗពីសំណាក់មេធាវី ដើមបណ្តឹងរដ្ឋប្បវេណីដូចដែលបានកើតឡើងនៅក្នុងសំណុំរឿង ០០១ ។ យ៉ាងណាមិញ វាហាក់បីដូចជាថាមានមេធាវីដើម បណ្តឹងរដ្ឋប្បវេណីតិចតួចណាស់ដែលអាចឡើងបង្ហាញនូវអំណះ អំណាងរបស់ខ្លួនលើបញ្ហានានានៃអង្គសវនាការបឋមនេះ ។ ទិដ្ឋភាពបែបនេះបានបង្កើតជាចម្ងល់មួយថាតើយន្តការថ្មីមួយនេះ អាចនឹងដោះស្រាយបញ្ហាដែលធ្លាប់កើតមាននៅក្នុងអំឡុង ដំណើរការនីតិវិធីនៃសំណុំរឿង០០១បានដែរឬយ៉ាងណា ។ ទាំង សហប្រធានមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹង រដ្ឋប្បវេណីកំពុងតាក់តែងវិធានមួយចំនួនសម្រាប់ការធ្វើទំនាក់ទំនង និងការសហការរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ យ៉ាងណាមិញ យើងកំពុងទន្ទឹងរង់ចាំមើលថាតើវិធានទាំងអស់នេះ អាចនឹងត្រូវតាក់តែងឡើងជាស្ថាពរ និងថាតើវិធានទាំងអស់នេះ អាចនឹងជួយដោះស្រាយបញ្ហាដែលកើតមានពីមុនមកបានដែរ ឬទេ ។ យើងក៏មានចម្ងល់មួយទៀតទាក់ទងនឹងការចូលរួមរបស់ ជនរងគ្រោះថាតើវិធីសាស្ត្រនៃការអនុញ្ញាតឲ្យមានការចូលរួមពី ជនរងគ្រោះដែលត្រូវបានអនុវត្តដោយតុលាការខ្មែរក្រហមនេះ អាចនឹងធ្វើជាគំរូ និងយកទៅអនុវត្តនៅក្នុងតុលាការផ្សេងទៀត ដែរឬយ៉ាងណា ។

## បញ្ហាផ្សេងៗ

បញ្ហាបច្ចេកទេសមួយចំនួនផ្សេងទៀតក៏បានកើតមានឡើងនៅក្នុងអង្គសវនាការបឋមនេះដែរ ដែលក្នុងនោះរួមមានបញ្ហាអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មជាតិ អាជ្ញាយុកាលសម្រាប់ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបញ្ជីរាយនាមសាក្សីដែលត្រូវបានស្នើសុំ ។ ជាអកុសល បញ្ហាទាំងអស់នេះមិនត្រូវបានសម្រេចដោះស្រាយនៅក្នុងអំឡុងអង្គសវនាការបឋមនេះទេ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែដោះស្រាយបញ្ហាទាំងអស់នេះនៅក្នុងអង្គសវនាការខាងមុខ បើទោះបីជាវាអាចនិយាយបានថាបញ្ហាទាំងអស់នេះអាចនឹងកើតមានឡើងម្តងទៀតនៅក្នុងអង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានសម្រេចធ្វើការចោទប្រកាន់ណាមួយលើជនត្រូវចោទ ។

អាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មជាតិ ៖ មេធាវីការពារក្តីបានអះអាងថាតុលាការខ្មែរក្រហមមិនអាចអនុវត្តការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មជាតិស្តីពីអំពើមនុស្សឃាតការធ្វើទារុណកម្ម និងការធ្វើបុកទុក្ខម្នេញផ្នែកសាសនាដែលត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦នៅចំពោះមុខតុលាការខ្មែរក្រហមបានទេ ពីព្រោះអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋកម្មជាតិនេះបានហួសកាលបរិច្ឆេទកំណត់ទៅហើយ ។ មេធាវីការពារក្តីបានកត់សម្គាល់ថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦មានរយៈពេលដប់ឆ្នាំ ក្រោយពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ។ វាមានន័យថា ជនសង្ស័យដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មជាតិទាំងនេះអាចនឹងត្រូវនាំមកកាត់ទោសនៅក្នុងអំឡុងពេលដប់ឆ្នាំនៃការប្រព្រឹត្តបទឧក្រិដ្ឋរបស់ខ្លួន ។ ដូច្នេះ សម្រាប់សំណុំរឿងដែលមាននៅចំពោះមុខតុលាការខ្មែរក្រហមវិញ មេធាវីការពារក្តីបានអះអាងថាការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មក្នុងស្រុកបែបនេះមិនអាចយកមកអនុវត្តក្រោយពីឆ្នាំ១៩៨៩បានទេ ។ ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានតបតនឹងអំណះអំណាងនេះទៅវិញថាអាជ្ញាយុកាលនេះត្រូវបានពន្យារពេលក្រោយពីរបបខ្មែរក្រហមត្រូវបានដួលរលំទៅ ដោយសារតែរបបខ្មែរក្រហមបានបំផ្លិចបំផ្លាញប្រព័ន្ធតុលាការ និងធនធានចាំបាច់សម្រាប់ប្រព័ន្ធដំណើរការរបស់តុលាការ ហេតុដូច្នេះប្រព័ន្ធតុលាការក៏ត្រូវបានស្តាបនាឡើងវិញក្រោយពីការចុះកិច្ចព្រមព្រៀងសន្តិសញ្ញាសន្តិភាពទីក្រុងប៉ារីស កាលពីដើមទសវត្សរ៍៩០ ។ ជាក់ស្តែង ខ្មែរក្រហមបានបន្តវាយប្រយុទ្ធក្នុងសង្គ្រាមស៊ីវិលរហូតដល់ចុងទសវត្សរ៍៩០ ។

អាជ្ញាយុកាលសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ៖ មេធាវីការពារក្តីក៏បានអះអាងថាមាត្រា៦នៃច្បាប់បង្កើតតុលាការខ្មែរក្រហមមិនអាចយកមកអនុវត្តចំពោះជនជាប់ចោទបានទេ ពីព្រោះប្រទេសកម្ពុជាមិនទាន់ក្លាយជាហត្ថលេខីនៃអនុសញ្ញានេះនៅឡើយទេ នៅអំឡុងពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ។ ព្រះរាជអាជ្ញាបានជំទាស់វិញថា បើទោះបីជាប្រទេសកម្ពុជាមិនទាន់ក្លាយជាហត្ថលេខីនៃអនុសញ្ញាក្នុងអំឡុងពេលនោះក៏ដោយ ក៏ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនេះបានឈានដល់កម្រិតច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហេតុដូច្នេះ អនុសញ្ញានេះអាចនឹងយកមកអនុវត្តនៅចំពោះមុខតុលាការខ្មែរក្រហមបាន ។

**បញ្ជីរាយនាមសាក្សី** ៖ នៅក្នុងអង្គសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចកំណត់ចំនួនសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវកោះហៅឲ្យចូលរួមនៅក្នុងអំឡុងអង្គជំនុំជម្រះក្តីនៃសំណុំរឿង០០២នៅឡើយទេ ។ ចៅក្រមបានជម្រាបដល់ភាគីទាំងអស់ថាបញ្ជីរាយនាមសាក្សីអាចនឹងត្រូវបានសម្រេចនៅក្នុងដំណាក់កាលដំបូងនៃដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសំណុំរឿង០០២ នាពេលខាងមុខ ។ លើសពីនេះ ដើម្បីការពារអត្តសញ្ញាណរបស់សាក្សី អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យភាគីទាំងអស់ប្រើប្រាស់រហស្សនាម នៅពេលដែលសំដៅលើសាក្សីណាម្នាក់ ។ ភាគីទាំងអស់ក៏ត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីជំទាស់មិនទទួលស្គាល់ និងយល់ព្រមទទួលស្គាល់សាក្សីបាន ។ ជាក់ស្តែង មេធាវីការពារក្តីរបស់ នួន ជា ត្រូវបានចៅក្រមបញ្ឈប់បទអត្ថាធិប្បាយរបស់ខ្លួននៅក្នុងអំឡុងអង្គសវនាការបឋមនេះ ដោយសារតែបានរៀបរាប់ពីព័ត៌មានលម្អិតរបស់សាក្សីម្នាក់ បើទោះបីជាលោកមេធាវីបានប្រើប្រាស់រហស្សនាមដើម្បីសម្គាល់សាក្សីរូបនោះក៏ដោយ ។ នេះគឺជាសេចក្តីសម្រេចដ៏ត្រឹមត្រូវមួយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ឈប់មេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា មិនឲ្យរៀបរាប់ពីព័ត៌មានលម្អិត

របស់សាក្សី X នោះ ។ ជាក់ស្តែង ព័ត៌មានដែលមេធាវីការពារក្តីបានរៀបរាប់ទាក់ទងនឹងសាក្សីរូបនោះបានធ្វើឲ្យសាធារណជនដឹងយ៉ាងច្បាស់ថា សាក្សីរូបនោះគឺសំដៅទៅលើលោក ប៉ែន សុវណ្ណ ដែលជាអតីតនាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ដើម្បីការពារសុវត្ថិភាពរបស់សាក្សី ភាគីទាំងអស់ចាំបាច់ត្រូវរក្សាអត្តសញ្ញាណរបស់សាក្សីជាការសម្ងាត់មុននឹងសាក្សីឡើងមកធ្វើសក្ខីកម្ម ។

## សេចក្តីសន្និដ្ឋាន

បញ្ហាសុខភាពរបស់ជនជាប់ចោទគឺជាកត្តាប្រឈមមួយដែលតុលាការខ្មែរក្រហមត្រូវតែដោះស្រាយ នៅក្នុងដំណើរការអង្គជំនុំជម្រះក្តីរបស់ជនជាប់ចោទទាំងអស់ បើយើងពិនិត្យលើបញ្ហាសុខភាពដ៏ទ្រុឌទ្រោមនាពេលបច្ចុប្បន្នរបស់ជនជាប់ចោទ ។ សាធារណជនទាំងមូលកំពុងតែព្រួយបារម្ភយ៉ាងខ្លាំងពីបញ្ហាសុខភាព និងស្ថានភាពទ្រុឌទ្រោមរបស់ជនជាប់ចោទនៅក្នុងអង្គសវនាការបឋមនេះ ។ ដើមបណ្តឹងរដ្ឋប្បវេណី សេង ចុន និង ចាន់ កិ បានទទួលស្គាល់ថាជនជាប់ចោទទាំងអស់មានវ័យចាស់ជរា និងទ្រុឌទ្រោមខ្លាំង ប៉ុន្តែអ្នកទាំងពីរនៅតែប្រកាន់នូវគោលជំហរមួយថា ឲ្យតែជនជាប់ចោទទាំងអស់នេះនៅរស់អ្នកទាំងអស់នេះត្រូវតែកាត់ទោស «ដើម្បីទុកជាមេរៀនសម្រាប់ក្មេងជំនាន់ក្រោយ» ។ ចំណែកឯ ចាន់ កិ ជឿជាក់ថាជនជាប់ចោទទាំងអស់មានរឿងរ៉ាវច្រើនណាស់ដែលត្រូវប្រាប់ប្រជាជនកម្ពុជាទាំងអស់ថាតើមានរឿងអ្វីខ្លះបានកើតឡើងនៅក្នុងអំឡុងរបបខ្មែរក្រហម ហើយថាតើរឿងទាំងអស់នោះកើតឡើងដោយមូលហេតុអ្វី និងដោយរបៀបណា ។

អង្គជំនុំជម្រះសាលាដំបូងនឹងដោះស្រាយបញ្ហាទាំងអស់ខាងលើនេះ ហើយនឹងចេញជាសេចក្តីសម្រេចនាពេលខាងមុខ ។ បញ្ហាភាគច្រើនត្រូវបានសម្រេចដោះស្រាយដោយអង្គបុរេជំនុំជម្រះរួចម្តងហើយ ប៉ុន្តែបញ្ហាទាំងអស់នេះអាចនឹងកើតមានឡើងម្តងទៀតនៅចំពោះអង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើជនជាប់ចោទមានជីវិតរស់នៅរហូតដល់ថ្ងៃចេញសាលក្រម ។ នេះគឺជាឧបសគ្គដ៏ធំមួយរបស់តុលាការខ្មែរក្រហម ដោយសារតែតុលាការនេះអនុញ្ញាតឲ្យមានការលើកឡើងរាល់បញ្ហាដែលមាន ហើយសម្រេចដោះស្រាយបញ្ហានោះតាមដំណាក់កាល និងកម្រិតនៃដំណើរការអង្គនីតិវិធី ។ ការធ្វើបែបនេះទាមទារពេលវេលាច្រើនដែលតុលាការខ្មែរក្រហមខ្លួនឯងមិនមានធនធានគ្រប់គ្រាន់សម្រាប់ដំណើរការនីតិវិធីដែលមានរយៈពេលយូរបែបនេះទេ ។ ដោយឡែក ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏នៅតែកត្តាប្រឈមមួយរបស់តុលាការខ្មែរក្រហមដែលត្រូវដោះស្រាយ ប្រសិនបើតុលាការខ្មែរក្រហមមានគោលបំណងផ្តល់ជាបទពិសោធន៍ដ៏មានន័យមួយដល់ជនរងគ្រោះ ។ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនរហូតដល់៣៨៥០ នាក់ ហើយធនធានសម្រាប់សកម្មជនដែលបំពេញកិច្ចការជំរុញឲ្យមានការចូលរួមពីជនរងគ្រោះនៅមានកម្រិតនោះ ការប្រាថ្នាចង់បាននូវការចូលរួមដ៏មានន័យសម្រាប់ជនរងគ្រោះបានក្លាយជាបញ្ហាដែលមិនអាចសម្រេចបានផ្អែកលើទិដ្ឋភាពជាក់ស្តែង ។

**ឌី ឆេរិទ្ធិ**



មន្ត្រីកិច្ចការសាធារណៈរបស់សាលាក្តីខ្មែរក្រហម ហ៊ុយ វណ្ណៈ និយាយទៅកាន់សាស្ត្រាចារ្យ អាឡិច ហ៊ីនតុន

# ការសង្គ្រោះយកយុត្តិធម៌មកវិញក្នុងករណីជនជាប់ចោទណាម្នាក់បានស្លាប់ ៖ ករណី០០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែធ្វើការដើម្បីប្រដែងជាមួយពេលវេលា ។ មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅរស់រានមានជីវិតទាំងបួននាក់កំពុងរង់ចាំសវនាការរួមគ្នាមួយនៅក្នុងករណី០០២ដោយកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងបទល្មើសនានាក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ។ អតីតអនុលេខាបក្ស នួន ជា និងអតីតរដ្ឋមន្ត្រីក្រសួងការបរទេស អៀង សារី មានវ័យ៨០ឆ្នាំ ចំណែកឯអតីតប្រធានរដ្ឋ ខៀវ សំផន និងអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អៀង ធីរិទ្ធ ក៏មានវ័យប្រហាក់ប្រហែលគ្នាដែរ ។ ដោយសារតែជនជាប់ចោទមានវ័យចំណាស់បែបនេះ ទំនងជាមានជនជាប់ចោទណាម្នាក់ បើសិនជាមិនទាំងអស់ អាចនឹងស្លាប់មុននឹងសាលាក្តីខ្មែរក្រហមបញ្ចប់កិច្ចការងាររបស់ខ្លួន ។

មានក្តីបារម្ភថា ជនជាប់ចោទម្នាក់ឬច្រើននាក់អាចស្លាប់មុននឹងតុលាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់រឿងក្តីរបស់ខ្លួន ហើយបើសិនជាមានករណីនេះកើតឡើងមែននោះ តុលាការខ្មែរក្រហមនឹងត្រូវមើលឃើញថាបរាជ័យទាំងស្រុង ។ ជាភ័ព្វសំណាងដែរ ទោះបីជាសេចក្តីវិនិច្ឆ័យទោសចុងក្រោយជាកិច្ចការដ៏សំខាន់របស់តុលាការក៏ដោយ ក៏សេចក្តីវិនិច្ឆ័យនេះមិនមែនគ្រាន់តែសមាសភាពតែមួយគត់ដែលនឹងទទួលបានពីសាលាក្តីខ្មែរក្រហមនោះទេ ។ ករណី០០២ ដែលជាប់ពាក់ព័ន្ធនឹងការកាត់ទោសជនជាប់ចោទបួនរូបអាចនឹងចំណាយពេលជាច្រើនឆ្នាំទៅមុខទៀតដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនរហូតដល់ ៣.៨៥០នាក់ ជនរងគ្រោះដាក់ពាក្យបណ្តឹងមានចំនួន៤.១៥១នាក់ ហើយឯកសារដែលនឹងត្រូវប្រើប្រាស់មានចំនួនជាង ៣៥០.០០០ទំព័រ ។ ទាំងអស់នេះសុទ្ធតែមានប្រយោជន៍យ៉ាងខ្លាំងដល់ការអប់រំនិងការអភិវឌ្ឍន៍ប្រទេសកម្ពុជាទៅថ្ងៃមុខ ។ អត្ថបទនេះនឹងជាអត្ថបទស្រាវជ្រាវដំបូងមួយដែលពិនិត្យទៅលើផលប៉ះពាល់ផ្លូវច្បាប់អំពីមរណភាពរបស់ជនជាប់ចោទណាម្នាក់ដែលនិងប៉ះពាល់ដល់សវនាការ ។ អត្ថបទស្រាវជ្រាវនេះនឹងបង្ហាញឱកាសដែលនឹងអាចបាត់បង់ដល់ភ័ស្តុតាង គំហើញនានា និងសក្ខីកម្មនៃករណី០០២ បើសិនជាតុលាការត្រូវបានបញ្ឈប់នៅពេលដែលជនជាប់ចោទណាម្នាក់បានស្លាប់មុននិងសេចក្តីវិនិច្ឆ័យទោសចុងក្រោយ ។

**១) ករណីដែលជនជាប់ចោទទទួលមរណភាព ៖ ផលប៉ះពាល់ផ្នែកច្បាប់**

**ក) ពេលវេលា**

ខណៈពេលដែលមិនមានវិធានច្បាស់លាស់ណាមួយចែងនៅក្នុងឯកសាររបស់តុលាការអន្តរជាតិនានា សេចក្តីសម្រេចរបស់តុលាការអន្តរជាតិបង្ហាញថា កិច្ចដំណើរការកាត់ទោសអាចនឹងត្រូវបានបញ្ឈប់ បើសិនជាជនជាប់ចោទបានស្លាប់មុននឹងការប្រកាសសេចក្តីសម្រេចទោសចុងក្រោយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការផ្សេងទៀតដែលត្រូវបានបង្កើតឡើងដើម្បីកាត់ទោសបទឧក្រិដ្ឋធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងដោយអតីតប្រទេសយូហ្គោស្លាវីបានបញ្ឈប់រឿងរ៉ាវចំនួនប្រាំមួយករណីដោយសារតែមរណភាពរបស់ជនជាប់ចោទម្នាក់ ។ ករណីដ៏សំខាន់បំផុតប្រហែលជាសវនាការរបស់ជនជាប់ចោទ ស្លូបូដាន់ មីឡូសូវីក ដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ស្លូបូដាន់ មីឡូសូវីក គឺជាជនជាប់ចោទដំបូងបង្អស់ដែលជាអតីតប្រមុខរដ្ឋនៃប្រទេសដែលត្រូវកាត់ទោសនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយបានស្លាប់ក្នុងបន្ទប់ឃុំឃាំងរបស់អង្គការសហប្រជាជាតិកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៦ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីត្រូវបានបញ្ឈប់ប៉ុន្មានថ្ងៃក្រោយមក ហើយមរណភាព

នេះបានធ្វើឲ្យ ស្លូបូដាន់ មីឡូសូវីក គេចផុតពីសេចក្តីវិនិច្ឆ័យទោសចុងក្រោយបន្ទាប់ពីដំណើរការកាត់ទោសបានដំណើរការបួនឆ្នាំមកហើយ ។

ក្នុងករណីកាត់ទោសជនជាប់ចោទ ណ័រមែន និងគូកន តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានបង្ហាញថា មរណភាពរបស់ជនជាប់ចោទបានបញ្ឈប់ដល់ដំណើរការកាត់ទោសទាំងមូល ។ ហេតុដូច្នេះ បើទោះបីជាជនជាប់ចោទបានទទួលនូវការជំនុំជម្រះពេញលេញ ហើយបានទទួលនូវការការពារក្តីពេញលេញក៏ដោយ ក៏តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនមិនអាចនឹងអនុវត្តយុត្តាធិការច្បាប់របស់ខ្លួនក្នុងការចេញសេចក្តីសម្រេចចុងក្រោយបានដែរ ។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានបង្ហាញថា គោលការណ៍នៃការទទួលខុសត្រូវលើបទឧក្រិដ្ឋជាលក្ខណៈបុគ្គលអាចនឹងរំលោភលើកិច្ចដំណើរការដែលបន្តក្រោយពីជនជាប់ចោទបានស្លាប់ បើទោះជាជនជាប់ចោទត្រូវបានកាត់ទោសរួចរាល់ក្តី ។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនក៏បានគូសបញ្ជាក់ឲ្យច្បាស់អំពីការពិតដែលសេចក្តីវិនិច្ឆ័យទោសនៅក្នុងតុលាការព្រហ្មទណ្ឌគឺជា «អភ័យឯកសិទ្ធិ និងឋានៈសត្តមផ្លូវច្បាប់ដ៏ពិសេស» នៃជនដែលត្រូវចោទប្រកាន់ពីបទប្រព្រឹត្តបទឧក្រិដ្ឋ ហើយការចោទប្រកាន់មិនអាចកាត់ទោសអ្នកផ្សេងបានទេ ។

ច្បាប់ដែលបង្កើតសាលាក្តីខ្មែរក្រហមធានាចំពោះជនជាប់ចោទនូវសិទ្ធិស្រដៀងគ្នាដូចទៅនឹងករណីការកាត់ទោស ណ័រមេន និងគូកនក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែរ ។ សិទ្ធិទាំងអស់នេះដើម្បីធានាថា ការវិនិច្ឆ័យទោសចុងក្រោយនៅសាលាក្តីខ្មែរក្រហមមិនអាចធ្វើបានទេបើសិនជាជនជាប់ចោទមិនមានជីវិត ទោះបីជាដំណើរការកាត់ទោសចប់សព្វគ្រប់ហើយក៏ដោយ ។ តាមមាត្រា៣៥ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឲ្យដឹងថា ជនជាប់ចោទត្រូវចាត់ទុកថាជាជនគ្មានទោស លុះត្រាណាតុលាការរកឃើញថាមានទោស ។ ហេតុដូច្នេះ បើសិនជាជនជាប់ចោទណាម្នាក់ក្នុងចំណោមជនជាប់ចោទទាំងបួនក្នុងករណី០០២ស្លាប់ ដំណើរការរបស់តុលាការខ្មែរក្រហមនឹងត្រូវបញ្ឈប់សម្រាប់ជនជាប់ចោទដែលបានស្លាប់នោះ ហើយជនជាប់ចោទនោះនឹងស្លាប់ទៅដោយនាំយកនូវភាពគ្មានទោសតាមផ្លូវច្បាប់ ។

ក្នុងអង្គសវនាការជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ករណីជនជាប់ចោទ ដឺលីក បានស្លាប់ក្រោយពីតុលាការបានចេញសេចក្តីសម្រេចចុងក្រោយរួច ប៉ុន្តែ ដឺលីក បានស្លាប់មុនតុលាការប្រកាសការវិនិច្ឆ័យទោសបញ្ចប់រឿង ។ ក្រោយពីមរណភាពរបស់ ដឺលីក តុលាការបានអាក់ខានដំណើរការទាំងមូល ។ ហេតុដូច្នេះ អង្គសវនាការជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានពិចារណាទៅលើភាពនៃការវិនិច្ឆ័យទោសចុងក្រោយដែលមាននៅក្នុងអង្គសវនាការ ។ ដោយមិនមានច្បាប់ណាមួយដែលអាចប្រើប្រាស់បានចំពោះករណីនេះ អង្គសវនាការជំនុំជម្រះអះអាងថា ការបន្តនូវការវិនិច្ឆ័យរបស់តុលាការនៅពេលដែលភាគីប្តឹងឧទ្ធរណ៍ស្លាប់ ដោយដើរតាមស្មារតីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ដូច្នេះ «គ្មានអ្វីអាចកំណត់ពីភាពបញ្ចប់របស់ការវិនិច្ឆ័យរបស់តុលាការបានទេ» ។

**១) ការកាត់ទោសជនជាប់ចោទរួមគ្នា**

បើសិនជាជនជាប់ចោទម្នាក់ឬច្រើននាក់ស្លាប់ក្នុងអំឡុងពេលដំណើរការកាត់ទោស ដំណើរការកាត់ក្តីនឹងនៅតែបន្តទៀតសម្រាប់អ្នកផ្សេងទៀតដែលនៅរស់ ។ បើសិនជាដំណើរការកាត់ក្តីបានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នៅក្នុងសវនាការរួមរួចហើយ ប៉ុន្តែអង្គសវនាការមិនទាន់ប្រកាសអំពីសេចក្តីសម្រេចបញ្ចប់រឿងនៅឡើយ ការប្រកាសសាលក្រមធ្វើឡើងចំពោះតែនរណាដែលនៅរស់ប៉ុណ្ណោះ ។ ប៉ុន្តែតុលាការអាចនឹងធ្វើការពិចារណារាល់ភស្តុតាងទាំងអស់ដែលបានដាក់ជូនតុលាការក្នុងការផ្តល់នូវសេចក្តីវិនិច្ឆ័យ រួមទាំងភស្តុតាងទាំងឡាយដែលទាក់ទងនិងជនជាប់ចោទដែលបានស្លាប់ទៅហើយ ។ នៅក្នុងសវនាការរួមគ្នារបស់ជនជាប់ចោទ ណ័រមេន និងគូកន នៅឯតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ការវិនិច្ឆ័យទោសសម្រាប់ជនជាប់ចោទដែលនៅរស់ផ្អែកលើ «ភស្តុតាងដែលនៅសល់ទាំងស្រុង» ដែលដាក់ជូនដើម្បីប្រឆាំងនឹងជនជាប់ចោទដែលបានស្លាប់ហើយ ។ បើសិនជាជនជាប់ចោទម្នាក់ឬច្រើននាក់នៅក្នុងករណី០០២របស់

សាលាក្តីខ្មែរក្រហមបានស្លាប់មុនពេលជំនុំជម្រះទោស តុលាការខ្មែរក្រហមនឹងធ្វើកិច្ចការដូចករណីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែរ ។

## ២) ការជួយសង្គ្រោះភស្តុតាង គំហើញផ្សេងៗ និងសក្ខីកម្ម

### ក) តម្លៃនៃការអប់រំ ៖ ដើម្បីចងចាំនិងទប់ស្កាត់

### ១) ភាពយន្តឯកសារ

បើសិនជាជនជាប់ចោទម្នាក់ឬច្រើននាក់ស្លាប់មុននឹងទទួលបាននូវការជំនុំជម្រះទោសនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ្នកផលិតខ្សែភាពយន្តអាចប្រើប្រាស់ភស្តុតាងសក្ខីកម្ម និងការតាំងពិព័រណ៍នានាទាក់ទងនឹងករណី០០២ដាក់បញ្ចូលទៅក្នុងភាពយន្តឯកសារដើម្បីអប់រំដល់សាធារណជន ។ ខ្សែភាពយន្តឯកសារអាចផ្តល់ព័ត៌មានទាក់ទងទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបង្ហាញពីទិន្នន័យលម្អិតនៃដំណើរការរបស់តុលាការ រួមទាំងសក្ខីកម្មអ្នកដែលនៅរស់ ការសារភាពនៅក្នុងអង្គសវនាការ និងព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងបន្ទប់សវនាការ ។ ខ្សែវីដេអូខ្លីៗរបស់មេដឹកនាំទាំងបួននាក់ដែលបានបង្ហាញនៅក្នុងបន្ទប់សវនាការអាចប្រាប់ប្រជាជនកម្ពុជាថាយុត្តិធម៌កំពុងតែស្វែងរក ទោះបីជាគ្មានការវិនិច្ឆ័យទោសបញ្ចប់រឿងក៏ដោយ ។ លើសពីនេះទៅទៀត សក្ខីកម្មរបស់ជនរងគ្រោះនិងសាក្សីដែលមាននៅក្នុងខ្សែភាពយន្តអាចបញ្ជាក់ថា ប្រជាជនកម្ពុជាត្រូវបានផ្តល់ឱកាសឲ្យអ្នកផ្សេងដឹងពូទាក់ទងនឹងសវនាការនេះដែរ ។ ដោយសារតែខ្សែវីដេអូរបស់ជនរងគ្រោះមានលក្ខណៈផ្ទាល់ខ្លួន សារដែលផ្ញើទៅអ្នកទស្សនាអាចមានលក្ខណៈប្រសើរជាងពាក្យដែលបានរៀបរាប់នៅលើក្រដាសទៅទៀត ។

ក្រោយពីជំនុំជម្រះទោសរយៈពេលបួនឆ្នាំ រឿងក្តីរបស់ស្លូបូដាន់ មីឡូសូវីក នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបង្កើតឲ្យមានទិន្នន័យយ៉ាងលម្អិតជាច្រើនអំពីអំពើឃោឃៅដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនបូស្នៀ ។ ខ្សែភាពយន្តឯកសារដ៏ឃោឃៅមួយឈ្មោះថា «ខ្សែវីដេអូក្អែប» ដែលរៀបរាប់អំពីការសម្លាប់ដ៏ព្រៃផ្សៃដែលប្រព្រឹត្តឡើងដោយនគរបាលរបស់ជនជាតិស៊ែប ហើយខ្សែវីដេអូនេះបានចាក់ផ្សាយជាសាធារណៈក្រោយពីប្រើប្រាស់នៅក្នុងតុលាការរួច ។ នៅពេលដែលស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកទូទាំងប្រទេសស៊ែបផ្សព្វផ្សាយពីខ្សែវីដេអូនេះ មនុស្សម្នាទូទៅបានប្រឈមមុខនឹងហេតុការណ៍ជាច្រើនដែលអ្នកទាំងអស់នោះធ្លាប់មិនទទួលស្គាល់និងធ្លាប់បដិសេធ ហើយមនុស្សម្នាទូទៅបានទទួលស្គាល់ថា ជនជាតិស៊ែបបានប្រព្រឹត្តអំពើឃោរឃៅបែបនោះមែន ។ ប្រទេសស៊ែបទទួលរងនូវការរិះគន់យ៉ាងខ្លាំងក្លា ហើយរដ្ឋាភិបាលត្រូវបានដាក់សម្ពាធឲ្យចាប់ជនទាំងឡាយណានៅក្នុងខ្សែវីដេអូដែលបានប្រព្រឹត្តបទល្មើស ។ នៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តសកម្មភាពឃោរឃៅចំពោះប្រជាជនរបស់ខ្លួនដែរ ។ សក្ខីកម្មនិងភស្តុតាងរបស់តុលាការដែលទទួលបានក្នុងអំឡុងពេលសវនាការករណី០០២ អាចនឹងមានសារសំខាន់ដូចគ្នា ហើយជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រជាជនកម្ពុជាទាំងមូល ។

### ២) ពិព័រណ៍

ផែនទី រូបថត គំនូរ សេចក្តីថ្លែងការណ៍ផ្សេងៗ និងអត្ថបទសម្ភាសន៍ដែលបានប្រើប្រាស់នៅឯតុលាការអាចនឹងយកមកប្រើ




ប្រជាជនកំពុងមើលពិព័រណ៍អំពីមេដឹកនាំខ្មែរក្រហមនៅគុកទួលស្លែង

ដើម្បីតាំងពិព័រណ៍បង្ហាញឲ្យសាធារណជនទូទៅដឹងលម្អិតអំពីហេតុការណ៍ផ្សេងៗនៃករណី០០២ ។ វិធានផ្ទៃក្នុង៨៧របស់សាលាក្តីខ្មែរក្រហមបានអនុញ្ញាតឲ្យមានការប្រើប្រាស់ឯកសារទាំងអស់ដែលទាក់ទងនឹងសាលាក្តី «ដែលបម្រើផលប្រយោជន៍ក្នុងការស្វែងរកការពិត» ។ វិធាននេះនឹងអនុញ្ញាតឲ្យមានការប្រើប្រាស់ឯកសារដ៏សន្ធឹកសន្ធាប់ទាក់ទងនឹងករណី០០២ ។ ភ័ស្តុតាងដែលបានដាក់ជូនអំឡុងពេលដំណើរការកាត់ក្តីដោយភាគីព្រះរាជអាជ្ញា ឬភាគីបណ្តឹងរដ្ឋប្បវេណី ហើយឯកសារដែលបានពិនិត្យនិងសាកសួរដោយជនជាប់ចោទគឺជារឿងសំខាន់ដើម្បីរៀនពីរបបខ្មែរក្រហម ទោះបីជាមិនត្រូវបានសម្រេចតាមផ្លូវច្បាប់ក៏ដោយ ។

ជារឿងមានប្រយោជន៍ណាស់បើសិនជាមានការរៀបចំពិព័រណ៍គ្រប់ខេត្តទូទាំងប្រទេស ហើយពិព័រណ៍គួរតែធ្វើឡើងក្នុងទីតាំងសាលារៀន ឬទីណាដែលអ្នកភូមិអាចចូលមើលបាន ។ ពិព័រណ៍ដែលប្តូរពីកន្លែងមួយទៅកន្លែងមួយនេះអាចនឹងផ្តល់ឱកាសយ៉ាងច្រើនក្នុងការអប់រំយុវជនដែលមានចំណេះដឹងតិចតួចទាក់ទងនឹងរបបប្រល័យពូជសាសន៍ និងអ្នកភូមិនៅទីជនបទដែលមិនអាចធ្វើដំណើរមកទីក្រុងភ្នំពេញបាន ។ ដោយសារតែអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមភាគច្រើនមិនចេះអក្សរ និងមានចំណេះដឹងតិចតួច និងដើម្បីផ្តល់ព័ត៌មានទាក់ទងនឹងករណី០០២ ឯកសារផ្លូវច្បាប់ទាក់ទងនឹងករណី០០២នេះអាចធ្វើឲ្យមានលក្ខណៈសាមញ្ញដើម្បីប្រើប្រាស់នៅក្នុងពិព័រណ៍ ។

### ៣) សៀវភៅសិក្សា

ជារឿងដ៏មានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជាគ្រប់ជំនាន់ទាំងអស់ក្នុងការដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីធានាថាសោកនាដកម្មដូចអ្វីដែលបានកើតឡើងនឹងមិនកើតឡើងម្តងទៀតទេ ។ ប៉ុន្តែទើបតែមកដល់ឆ្នាំ២០០៩នេះទេ រដ្ឋាភិបាលកម្ពុជាបញ្ចូលកម្មវិធីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចូលទៅក្នុងកម្មវិធីសិក្សាក្នុងកម្រិតមធ្យមសិក្សា ។ បច្ចុប្បន្ននេះសិស្សគ្រប់រូបត្រូវតម្រូវឲ្យរៀនពីការបង្កើតឡើងនៃរបបខ្មែរក្រហម រចនាសម្ព័ន្ធខ្មែរក្រហម និងមេដឹកនាំបក្សរួមមាន ខៀវ សំផន, នួន ជា និង អៀង សារី ដែលជាជនជាប់ចោទនៅក្នុងករណី០០២នេះ ។

ជាការប្រសើរណាស់ បើសិនជាមានការបន្ថែមព័ត៌មានថ្មីៗទៀតចូលទៅក្នុងសៀវភៅសិក្សារបស់សាលាដោយយកព័ត៌មានតាមសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជាជាគោលដើម្បីបញ្ជាក់ព័ត៌មានឲ្យលម្អិតបន្ថែមទៀតទាក់ទងនឹងករណី០០២ ។ ការពិត ភ័ស្តុតាង និងសក្ខីកម្មដែលបង្ហាញនៅក្នុងករណី០០២នេះអាចនឹងផ្តល់ឲ្យមានការយល់ដឹងបន្ថែមទៀតទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យព្រមទាំងឯកសារមួយចំនួនបន្ថែមទៀតដែលកំពុងមានសព្វថ្ងៃ ។

ទោះជាយ៉ាងនេះក្តី ការបោះពុម្ពសៀវភៅដែលប្រកបដោយការវិភាគផ្នែកច្បាប់លើសលប់ពេកទាក់ទងនឹងដំណើរការក្តីនៅសាលាក្តីខ្មែរក្រហម ក៏មិនមែនជារឿងល្អប៉ុន្មានដែរ ។ ប៉ុន្តែជម្រើសមួយទៀតគឺថា អ្នកនិពន្ធអាចសរសេរសៀវភៅសិក្សាមួយដែលទាក់ទងនឹងផ្លូវច្បាប់សម្រាប់និស្សិតច្បាប់ និងនិស្សិតផ្សេងៗដែលរៀបរាប់យ៉ាងលម្អិតទាក់ទងទៅនឹងភ័ស្តុតាងគំហើញ សក្ខីកម្ម និងដំណើរការក្តីអំពីករណី០០១ និង០០២ ។ ជាពិសេស ដោយសារតែប្រព័ន្ធច្បាប់កម្ពុជាមានលក្ខណៈទន់


សិស្សកំពុងអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ខ្សោយ ការបណ្តុះបណ្តាលមេធាវីអំពីវិធីសាស្ត្រតុលាការយុត្តិធម៌ និងរបៀបនៃការប្រើប្រាស់ធនធានដែលមាន ដើម្បីការពារកូនក្តី និងការតវ៉ាផ្លូវច្បាប់ផ្សេងៗ អាចនឹងមានប្រយោជន៍សម្រាប់ប្រទេសជាតិទាំងមូល ។

### ៤) បណ្ណសារវិសាមញ្ញ

ភ័ស្តុតាង សក្ខីកម្ម និងវីឌីអូរបស់តុលាការដែលបានប្រើប្រាស់នៅក្នុងករណី០០២ និងត្រូវបង្ហាញជាសាធារណៈ ដើម្បីឲ្យសាធារណជនដឹងពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ហើយឯកសារទាំងអស់នេះនឹងមានផលប្រយោជន៍សម្រាប់ប្រវត្តិវិទូ មេធាវី អ្នកសិក្សាស្រាវជ្រាវ និងអ្នកដែលចាប់អារម្មណ៍ផ្សេងទៀត ។ ខណៈពេលដែលឯកសារទាំងអស់នោះមិនមានការផ្ទៀងផ្ទាត់ដោយផ្លូវច្បាប់ ឯកសារទាំងនោះនឹងរក្សានូវការចងចាំដែលផ្តល់ជាពន្លឺដល់ដំណើរការកាត់ក្តី ហើយឯកសារទាំងអស់នោះនឹងជួយប្រជាជនកម្ពុជាទូទៅឲ្យដឹងពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ប្រទេសកម្ពុជាដើម្បីដឹងអំពីថាតើប្រវត្តិសាស្ត្រខ្មែរក្រហមកើតឡើងដោយរបៀបណា ហើយនរណាជាអ្នកទទួលខុសត្រូវ ។ អ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនរូបបានអះអាងថា អ្នកជំនាញអាចបង្កើតឲ្យមានការពិភាក្សាពីឯកសារដែលមាន ហើយឯកសារទាំងនោះអាចជា «ព័ត៌មានច្រើននិងច្បាស់លាស់» ។ ទោះបីជាករណី០០២ត្រូវបានអាក់ខានក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែនឹងមានឱកាសក្នុងការធ្វើការសម្រេចអំពីសេចក្តីសម្រេចចុងក្រោយបើសិនជាប្រជាជនកម្ពុជាអាចចូលទៅអានឯកសារទាំងនោះបាន ។

ក្រោយពីសេចក្តីសន្និដ្ឋានបញ្ចប់អំពីករណី០០២ នឹងមានឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលសាធារណជនអាចរកបានតាមរយៈប្រព័ន្ធអ៊ីនធើណេត ។ ប៉ុន្តែ ប្រជាជនកម្ពុជាជាច្រើននាក់មិនអាចប្រើប្រាស់អ៊ីនធើណេតបានទេ ហើយសូម្បីតែឯកសារនានារបស់សាលាក្តីខ្មែរក្រហមក៏ត្រូវបានទុកនៅតែទីក្រុងភ្នំពេញប៉ុណ្ណោះ អ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហមជាច្រើនដែលត្រូវបានប៉ះពាល់ដោយរបបខ្មែរក្រហមមិនអាចធ្វើដំណើរទៅទីក្រុងដើម្បីមើលឯកសារទាំងអស់នោះទេ ។ បើសិនជាមានអាគារសម្រាប់អានមួយដែលផ្ទុកឯកសារនិងព័ត៌មាននៅគ្រប់បណ្តាខេត្តទាំងអស់នោះនឹងមានផលប្រយោជន៍ជាច្រើន ។ បុគ្គលិកដែលនៅមើលថែទាំឯកសារទៅទីតាំងទាំងអស់នេះគួរតែជាមនុស្សដែលអាចអាន បកប្រែ និងចេះស្វែងរកឯកសារនានាបាន ។

### ៥) សេចក្តីព្រមព្រៀងដែលមាននៅក្នុងកិច្ចសន្យា ៈ ព័ត៌មានសម្ងាត់ និងសាក្សីដែលមិនត្រូវបង្ហាញអត្តសញ្ញាណ

ភ័ស្តុតាង គំហើញ និងសក្ខីកម្មទាំងអស់ដែលបានបង្ហាញនៅក្នុងអង្គសវនាការចំពោះករណី០០១ និង០០២ និងតាំងបង្ហាញជាសាធារណៈ ។ បើទោះបីជាតុលាការមិនបានចប់ចុងចប់ដើមក្តី សាលាក្តីខ្មែរក្រហមនិងបង្កើតឲ្យមានភ័ស្តុតាងដែលអាចបង្ហាញជាសាធារណៈបាន ។ ភ័ស្តុតាងខ្លះមានលក្ខណៈសម្ងាត់ ហើយភ័ស្តុតាងខ្លះទៀតគឺមានលក្ខណៈសម្ងាត់យ៉ាងខ្លាំង ។ ជាការពិតឯកសារទាំងនោះនឹងមានយ៉ាងសន្ធឹកសន្ធាប់ ។ មានតែឯកសារមួយចំនួនប៉ុណ្ណោះដែលអាចចែកជូនប្រជាជនកម្ពុជា និងអ្នកស្រាវជ្រាវទូទាំងពិភពលោកបានដើម្បីប្រយោជន៍ដល់ការអប់រំ ។ ឯកសាររួមមាន ឯកសារសម្ងាត់ ឯកសារសម្ងាត់បំផុត ឯកសារទាក់ទងទៅនឹងអង្គសវនាការអសាធារណៈ ឯកសារទាក់ទងនឹងសុខភាពរបស់ជនជាប់ចោទ ឯកសារទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញា និងឯកសារគំហើញនានា និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។ ឯកសារទាំងអស់នេះនឹងមិនអាចដាក់បង្ហាញជាសាធារណៈទេ ។ អ្នកដែលអាចចូលអានឯកសារសម្ងាត់នេះបានត្រូវគោរពការកិច្ចរបស់ខ្លួនដោយមិនត្រូវបង្ហាញឯកសារទាំងនោះទៅសាធារណជនឡើយ ហើយអ្នកទាំងនោះត្រូវបានហាមឃាត់ក្នុងការផ្សព្វផ្សាយព័ត៌មានទាំងនោះ ។

លើសពីនោះទៅទៀត ក្រោមច្បាប់របស់សាលាក្តីខ្មែរក្រហម ដំណើរការក្តីត្រូវតែធ្វើឡើងដោយគោរព និងការពារអត្តសញ្ញាណរបស់សាក្សីនិងជនរងគ្រោះ ។ ហេតុដូច្នេះ ជនរងគ្រោះនិងសាក្សីទាំងឡាយដែលបានធ្វើសក្ខីកម្ម និងជួយដល់តុលាការដែល «ប្រឈមមុខនឹងអាយុជីវិត ឬសុខភាព ឬសមាជិកគ្រួសារអាចនឹងមានគ្រោះថ្នាក់ដល់ជីវិត» ត្រូវធានាថា អ្នកទាំងនោះត្រូវបានការពារ ។ នៅក្នុងករណីដែលជនជាប់ចោទទទួលមរណភាព ហើយជាការបផ្អាក់ដល់ដំណើរការក្តី វិធានការទាំងអស់នេះនៅតែមានប្រសិទ្ធភាពនៅឡើយ ល្គឹកណាដំណើរការត្រូវ

បានលប់ចោលឬផ្លាស់ប្តូរ ។ នេះគឺជារឿងសំខាន់ណាស់ ព្រោះថាភាពបរាជ័យក្នុងការការពារអ្នកដែលត្រូវការការពារនេះអាចនឹងធ្វើឲ្យមានការសងសឹក និងបង្អាក់ទឹកចិត្តក្នុងការចូលរួមពីសំណាក់ជនរងគ្រោះនិងសាក្សីនៅក្នុងតុលាការលើកក្រោយទៀត ។

គោលការណ៍នៃប្រព័ន្ធចាត់ថ្នាក់ឯកសាររបស់សាលាក្តីខ្មែរក្រហមគឺដើម្បីការពារនូវការសម្ងាត់នៃដំណើរការដែលមិនត្រូវឲ្យមានការដឹងឮជាទូទៅខណៈពេលដែលតម្រូវឲ្យមានការរក្សាតម្លាភាពនៃព័ត៌មានចំពោះសាធារណជន ។ ឯកសារទាំងអស់នេះអាចប្រើប្រាស់ពេលដែលមានការបន្តាប់ពីសហចៅក្រមស៊ើបអង្កេត ឬអង្គសវនាការប៉ុណ្ណោះ ហើយក្រោយមកឯកសារសម្ងាត់ និងសម្ងាត់បំផុតត្រូវបានប្រើប្រាស់ដោយសាធារណៈ ។ វិធីមួយដើម្បីសម្រេចបាននូវឯកសារនេះគឺចម្លងឯកសារសម្ងាត់ ឬសម្ងាត់បំផុត នឹងត្រួតពិនិត្យមើលខ្លឹមសារនៃព័ត៌មានដែលមានលក្ខណៈរសើប ។ វិធីមួយទៀតដែលឯកសារសម្ងាត់អាចនឹងប្រើប្រាស់ជាសាធារណៈគឺនៅពេលដែលព្រឹត្តិការណ៍ទាំងឡាយដែលធ្លាប់ចាត់ទុកជាការសម្ងាត់លែងមានភាពចាំបាច់ក្នុងការចាត់ជារឿងសម្ងាត់ទៀតហើយ ហើយឯកសារទាំងនោះត្រូវបានចាត់ថ្នាក់ជាថ្មី ហើយតម្កល់ទុកក្នុងទីសាធារណៈវិញ ។

## ៧) កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អវត្តមាននៃការប្រកាសសាលក្រមគឺជាចំណុចធ្ងន់ធ្ងរតែអាចកែខៃបានទាក់ទងនឹងសាលាក្តីខ្មែរក្រហម ។ ទីមួយ អតីតមេដឹកនាំខ្មែរក្រហមពីររូបរួមមាន អៀង សារី ដែលបច្ចុប្បន្នជាជនជាប់ចោទ និង បងធំទីមួយ ប៉ុល ពត ត្រូវបានកាត់ទោសរួចហើយដោយប្រជាជនកម្ពុជា ។ ក្នុងឆ្នាំ១៩៧៩ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតតុលាការប្រជាជនបដិវត្តន៍ដើម្បីកាត់ទោសអ្នកដែលទទួលខុសត្រូវពីបទឧក្រិដ្ឋធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាតុលាការនោះត្រូវបានចាត់ទុកថាជាតុលាការមិនប្រកបដោយបទដ្ឋានច្បាប់ក៏ដោយ ក៏តុលាការនេះគឺជាកិច្ចខំប្រឹងប្រែងរបស់កម្ពុជាដើម្បីប្រាប់ពិភពលោកអំពីបទឧក្រិដ្ឋរបស់ខ្មែរក្រហម និងដើម្បីរកយុត្តិធម៌ ។ ទីពីរ អស់រយៈពេលជាងសាប់សិបឆ្នាំ ហើយដែលវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហមចេញពីអំណាច ។ នេះជារយៈពេលយូរពេកក្នុងការគិតតែអំពីការកាត់ទោសពីបទឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ការពិតដែលថា ករណី០០២ត្រូវយកមកកាត់ទោសនឹងបម្រើដល់ការបង្រួបបង្រួមជាតិយ៉ាងធំធេងដល់ប្រទេសកម្ពុជាទាំងមូល ។ តាមរយៈភ័ស្តុតាងដែលប្រើប្រាស់នៅសាលាក្តីខ្មែរក្រហមករណី០០២និងទទួលស្គាល់ជាផ្លូវការចំពោះបទឧក្រិដ្ឋដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យដែលធ្វើឲ្យមនុស្សជិតពីរលាននាក់បាត់បង់ជីវិត ។

នៅពេលដែល ស្លូបូដាន់ មីឡូសូវីក ស្លាប់នៅថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៦ គាត់បាននាំដំណើរការសវនាការដែលបានធ្វើឡើងអស់រយៈបួនឆ្នាំមកហើយទៅរកការអាក់ខានដោយការភ្ញាក់ផ្អើល ។ អ្នកខ្លះ មើលឃើញថា កង្វះនៃការធ្វើវិនិច្ឆ័យទោសបញ្ចប់គឺជាភ័ស្តុតាងមួយនៃអសមត្ថភាពរបស់តុលាការ ។ អ្នកផ្សេងទៀតយល់ឃើញថា អង្គសវនាការដោយកម្របស់ ស្លូបូដាន់ មីឡូសូវីក បានបញ្ជាក់ឡើងវិញពីសារសំខាន់នៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ អតីតប្រធានរដ្ឋនៃប្រទេសត្រូវបានចោទប្រកាន់ធ្វើបត្យាប័នទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ហើយទីបំផុតត្រូវនាំទៅឡើងទៅតុលាការ ។ ទោះបីជា ស្លូបូដាន់ មីឡូសូវីក អាចគេចផុតពីការធ្វើសេចក្តីវិនិច្ឆ័យទោសចុងក្រោយក៏ដោយ តែទីបំផុត ស្លូបូដាន់ មីឡូសូវីក បានស្លាប់នៅក្នុងបន្ទប់ឃុំឃាំង ។ គាត់មិនបានរួចខ្លួនពីភាពយុត្តិធម៌ទេ ។ ថ្ងៃដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញការចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដល់មេដឹកនាំខ្មែរក្រហម មេដឹកនាំខ្មែរក្រហមទាំងនោះក៏នឹងអាចមានជោគវាសនាដូច ស្លូបូដាន់ មីឡូសូវីក ដែរ ។

មេដឹកនាំខ្មែរក្រហមទាំងបួននាក់នឹងរស់នៅរហូតដល់ថ្ងៃដែលតុលាការធ្វើការវិនិច្ឆ័យទោសចុងក្រោយ ឬបើមិនដូច្នេះទេ មេដឹកនាំទាំងនោះនឹងស្លាប់អំឡុងពេលនៃការវិនិច្ឆ័យទោសនៅតុលាការ ។ មេដឹកនាំខ្មែរក្រហមទាំងនោះនឹងមិនអាចមានសេរីភាពពេញលេញដូចប្រជាជនកម្ពុជាទូទៅឡើយ ។

**អាណា ម៉ាំហ្វត**

# ការចរចានៅលើប្រវត្តិនៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឈមមុខនឹងបញ្ហាដ៏សំខាន់ពីរ ទីមួយបញ្ហារបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) និងទីពីរគឺបញ្ហារបស់សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ។ ទីមួយគឺជាបញ្ហានៅសវនាការដែលគួរតែអាចដោះស្រាយបានដោយចៅក្រម ។ បញ្ហាទីពីរមានភាពចម្រូងចម្រាស់ជាងបញ្ហាទីមួយ ហើយបានធ្វើឲ្យអ្នកអង្កេតការណ៍នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឈមមុខនឹងបញ្ហាច្បាប់និងអនាគតនៃអង្គជំនុំជម្រះ ។ ប៉ុន្តែ បច្ចុប្បន្ន ទាំងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតបានចាប់ផ្តើមដោះស្រាយបញ្ហារបស់ខ្លួនដែលកើតមាននៅអង្គជំនុំជម្រះជាសាធារណៈ ។ ភាពសុចរិតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមានតុល្យភាព ។ ផ្លូវដែលត្រូវដើរត្រូវបានរកឃើញ ប៉ុន្តែវាតម្រូវឲ្យមានអារម្មណ៍ និងភាពក្លាហាន ដើម្បីស្វែងរកបញ្ហានិងអនុវត្តដោយមានការទទួលខុសត្រូវ ។ ខណៈពេលដែលខ្ញុំបានស្តាប់ការតទល់ផ្ទាល់មាត់ អាន និងសិក្សាតាមឯកសារដែលដាក់ជាសាធារណៈ និងរបាយការណ៍សារព័ត៌មានស្តីពីស្ថានភាពបញ្ហាទាំងពីរនេះ ខ្ញុំមានការចាប់អារម្មណ៍ថា តើទស្សនៈមិនច្បាស់លាស់ទាក់ទងនឹងយុត្តាធិការលើបុគ្គលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែជះឥទ្ធិពលខ្លាំងដល់ការងាររបស់អ្នកទទួលខុសត្រូវតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដោយរបៀបណា?

សេចក្តីសង្ខេបនៃរឿងរ៉ាវនេះគឺ ៖ សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានប្រឈមមុខនឹងសេចក្តីសម្រេចកាលពីថ្ងៃទី២៩ ខែមេសា របស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចមិនឲ្យមានការស៊ើបអង្កេតបន្ថែមទៅលើជនសង្ស័យមួយចំនួនដែលអះអាងដោយ អេនឌ្រូ ខេលី នៅក្នុងសំណុំរឿង ០០៣ ។ បញ្ហានោះបានធ្វើឲ្យសហព្រះរាជអាជ្ញាកម្ពុជា ជា លាង មិនយល់ស្របនឹង អេនឌ្រូ ខេលី ហើយប្រកាសថាអ្នកទាំងនោះមិនបានស្ថិតនៅក្នុងយុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ ក្រោយមក សហចៅក្រមស៊ើបអង្កេតទាមទារឲ្យ អេនឌ្រូ ខេលី ដកផ្នែកខ្លះដែលមាននៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ កាលពីថ្ងៃទី៩ ខែឧសភា ។ តើអ្នកទាំងអស់គ្នាយល់ពីយុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

ខ្ញុំបានសរសេរអត្ថបទមួយដែលចុះផ្សាយនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ព័ត៌មាននេះអាចរកបានតាមរយៈគេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហមនៅផ្នែក «ព័ត៌មាន» ខែមករា ឆ្នាំ២០០៩ គឺ *(http:// www.cambodiatribunal.org/images/CTM/how many are too many defendants at the krt.pdf)* ដែលបកស្រាយពន្យល់ពីចរិតលក្ខណៈ និងចំនួនជនសង្ស័យដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងធ្វើការចោទប្រកាន់ ហើយថាតើទាំងនិយមន័យនិងចំនួនអ្នកដែលត្រូវចោទប្រកាន់ត្រូវបានពិភាក្សានៅអំឡុងពេលចរចាដែលនាំទៅដល់ការលើកឡើងពីឯកសារធម្មនុញ្ញដែលគ្រប់គ្រងទៅលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរបៀបណា? ទោះបីជារឿងរ៉ាវធ្លាប់កើតឡើងក៏ដោយ ក៏រយៈពេល២៩ខែក្រោយមក នៅតែមានការភ័ន្តច្រឡំជាច្រើនទៅលើយុត្តាធិការលើបុគ្គលដែលបានបន្សាក់ដល់ដំណើរការស៊ើបអង្កេតជនសង្ស័យបួនទៅប្រាំនាក់បន្ថែម ។ វានៅតែមានភាពចាំបាច់ដែលយើងត្រូវត្រឡប់ទៅមើលមូលដ្ឋាននៃការពិភាក្សា និងសង្ខេបពីអ្វីដែលបានកើតឡើងគឺមធ្យោបាយនៃការបកស្រាយយុត្តាធិការលើបុគ្គលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងចំនួនបុគ្គលដែលរដ្ឋាភិបាលកម្ពុជា មេធាវីរបស់អង្គការ

សហប្រជាជាតិ និងរដ្ឋាភិបាលផ្សេងទៀតដូចជារដ្ឋាភិបាលសហរដ្ឋអាមេរិក (ដែលជាអ្នកចូលរួមដ៏សំខាន់នៅក្នុងកិច្ចចរចា) បានមានបំណងចង់ចោទប្រកាន់ ។

កិច្ចពិភាក្សាសង្ខេបអំពីទំហំនៃយុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនត្រូវបានចាប់ផ្តើមរហូតដល់ឆ្នាំ១៩៩៩ ។ នៅអំឡុងឆ្នាំ១៩៩៧-១៩៩៨ មានការនិយាយពីបញ្ជីឈ្មោះដែលត្រូវចោទប្រកាន់ គឺត្រូវផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ (ហើយយើងដែលជាអ្នកចរចាមិនទាំងដឹងថា ឌុច នៅរស់ឬអត់ផង) ។ ជាជាងផ្តោតទៅលើការកំណត់យ៉ាងច្បាស់លាស់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវចោទប្រកាន់មនុស្សប៉ុន្មាននាក់ មានការផ្តោតសំខាន់ទៅលើថាតើត្រូវចាប់ខ្លួន ប៉ុល ពត, តា ម៉ុក, កែ ពក, អៀង សារី, ខៀវ សំផន, នួន ជា, អៀង ធីរិទ្ធ និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតដោយរបៀបណា?

ខ្ញុំរំឭកពីដើមខែមករា ឆ្នាំ១៩៩៩បន្ទាប់ពីការពិភាក្សាថ្មីៗនៅភ្នំពេញ គឺការធ្វើទស្សនកិច្ចរបស់ខ្ញុំនៅប៉េកាំង និងការស្នើប្រាប់ជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេសចិន វ៉ាង អ៊ី ថា គោលដៅរបស់តុលាការគឺមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមប្រមាណដប់នាក់ ហើយរដ្ឋាភិបាលកម្ពុជាអាចស្នើឈ្មោះមេដឹកនាំទាំងនោះសម្រាប់ស៊ើបអង្កេត ។ ការប៉ាន់ប្រមាណនោះមិនបានរួមបញ្ចូលឈ្មោះ ប៉ុល ពត ដែលបានស្លាប់នៅឆ្នាំ១៩៩៨ ឬ សុន សេន ដែលស្លាប់នៅឆ្នាំ១៩៩៧ ទេ ។ ប៉ុន្តែ កែ ពក (ដែលស្លាប់នៅឆ្នាំ២០០២) និង តា ម៉ុក (ដែលស្លាប់នៅឆ្នាំ២០០៦) ដែលនៅរស់នៅពេលនោះគឺជាគោលដៅរបស់យើង ។ ដូច្នេះ ការប៉ាន់ប្រមាណដ៏ត្រឹមត្រូវថាតើយុត្តាធិការលើបុគ្គលបានវិវឌ្ឍន៍នៅឆ្នាំ១៩៩៩ដោយរបៀបណាបានជាកំណត់យកឈ្មោះ កែ ពក, តា ម៉ុក, ខៀវ សំផន, អៀង សារី, នួន ជា, អៀង ធីរិទ្ធ និងក្រោយមក កាំង ហ្គេកអ៊ាវ (ហៅ ឌុច) នៅពេលគេរកឃើញថាគាត់នៅរស់ ហើយស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៅកម្ពុជា ។ ជនសង្ស័យដែលមានសក្តានុពលទាំងប្រាំពីរនាក់នេះបន្សល់ទុកនូវចន្លោះសម្រាប់ពន្លាតបញ្ជីឈ្មោះជនសង្ស័យប្រសិនបើមានគេធ្វើការសិក្សាទៅលើចំនួនជនសង្ស័យទាំង១០នាក់ ។ នេះប្រហែលជាការយល់ដឹងដ៏អភិរក្សទៅលើយុត្តាធិការលើបុគ្គលដែលខ្ញុំបានបញ្ចុះបញ្ចូលរដ្ឋាភិបាលចិនឲ្យគាំទ្រទស្សនៈបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនៅកម្ពុជា ។

ពីរខែក្រោយមក ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាបានផ្ញើរបាយការណ៍ដែលត្រូវបានគេរង់ចាំយ៉ាងយូរទៅឲ្យមហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខ (ឯកសារអង្គការសហប្រជាជាតិលេខ A/53/850, S/1999/231) ។ ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍ថា ព្រះរាជអាជ្ញាឯករាជ្យដែលចាត់តាំងដោយអង្គការសហប្រជាជាតិអាចមានព្រំដែនក្នុងការធ្វើការស៊ើបអង្កេតទៅលើអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ អ្នកជំនាញការមិនបានផ្តោតទៅលើអ្នកដែលគួរតែមានឈ្មោះនៅក្នុងបញ្ជីជនសង្ស័យ ឬចំនួនជនសង្ស័យច្រើនបំផុតដែលត្រូវស៊ើបអង្កេតនិងចោទប្រកាន់ទេ ។ របាយការណ៍របស់ក្រុមអ្នកជំនាញបានជះឥទ្ធិពលដល់កិច្ចចរចា (ដោយជំរុញឲ្យរដ្ឋាភិបាលកម្ពុជាមានទស្សនៈផ្ទុយ រីឯអ្នកចរចារបស់អង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិកបែរជាគាំទ្រ) និងធ្វើឲ្យភាគីផ្តោតទៅលើថាតើត្រូវធ្វើដូចម្តេចដើម្បីឲ្យមានការយល់ស្របគ្នាទៅលើបញ្ហាដែលរួមមានចរិតលក្ខណៈរបស់តុលាការ និងយុត្តាធិការរបស់បុគ្គល ។ ប៉ុន្តែ នៅក្នុងរយៈពេលពីរខែ អនុសាសន៍របស់ក្រុមអ្នកជំនាញដែលបានស្នើឲ្យមានតុលាការអន្តរជាតិដោយយោងតាមជំពូក៦នៃក្រុមប្រឹក្សាសន្តិសុខរបស់តុលាការអន្តរជាតិ ដែលស្រដៀងនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិនៅអតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា ត្រូវបានទុកចោលដោយសារជំហររឹងរបស់កម្ពុជា ។

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ លេខាធិការដ្ឋានអង្គការសហប្រជាជាតិបានសង្ខេបសំណើរបស់មន្ត្រីអង្គការសហប្រជាជាតិដែលធ្វើឡើងដោយក្រុមប្រឹក្សាសន្តិសុខដែលស្នើឲ្យមានតុលាការចម្រុះមួយនៅកម្ពុជាដែលបង្កើតឡើងដោយច្បាប់កម្ពុជា ប៉ុន្តែមានជំនួយពីអន្តរជាតិ ។ ចំណុចសំខាន់របស់សំណើនោះគឺត្រូវបង្កើត «យុត្តាធិការលើបុគ្គលដែលអាចកាត់ទោសមេដឹកនាំយោធានិងអ្នកនយោបាយសំខាន់របស់ខ្មែរក្រហម និងអ្នក

ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស» ។ ក៏មានកិច្ចខំប្រឹងប្រែងឲ្យកាត់ទោសមេដឹកនាំថ្នាក់ខ្ពស់ដូចតុលាការនៅ នូរ៉ែមប៊ឺកដែរ ។

ក្រោយមក នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបដិសេធផែនការរបស់អង្គការសហប្រជាជាតិ និងរិះគន់ទៅលើការអំពាវនាវរបស់អង្គការសហប្រជាជាតិឲ្យចាប់ជនសង្ស័យ២០-៣០នាក់ និងទស្សនៈបង្កើតតុលាការឲ្យដូចតុលាការនៅនូរ៉ែមប៊ឺក (ដែលគួរតែអាចជួយសម្រួលដល់ការចោទប្រកាន់ជនសង្ស័យដែលស្នើដោយមេធាវីអង្គការសហប្រជាជាតិ) ។ ដោយឃើញតា ម៉ុក និង ឌុច នៅជាប់ឃុំឃាំង អ្នកចរចាអង្គការសហប្រជាជាតិបានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជានៅចុងខែសីហា ឆ្នាំ១៩៩៩ ហើយក្នុងនោះ រ៉ាហ្វ ហ្សាក់គ្លីន បានចាកចេញពីប្រទេសកម្ពុជាដោយមានចំណាប់អារម្មណ៍ថា អាជ្ញាធរកម្ពុជាចង់ចោទប្រកាន់ត្រឹមតែជនសង្ស័យទាំងនោះប៉ុណ្ណោះ ។ ចំណាប់អារម្មណ៍នោះបានផ្លាស់ប្តូរនៅពេលដែលឃើញអាជ្ញាធរកម្ពុជាដែលជាអ្នកចរចាបានធ្វើឲ្យដំណើរការដើរទៅមុខនៅក្នុងឆ្នាំ១៩៩៩ និងឆ្នាំ២០០០ ។

ការចូលរួមដោយផ្ទាល់របស់ខ្ញុំនៅក្នុងដំណើរការចរចា គឺខ្ញុំតំណាងឲ្យផលប្រយោជន៍របស់សហរដ្ឋអាមេរិក និងដើរតួជាអ្នកសម្របសម្រួលរវាងអ្នកចរចាកម្ពុជានិងអង្គការសហប្រជាជាតិ ។ នៅចុងខែតុលា ឆ្នាំ១៩៩៩ ខ្ញុំសង្កត់ធ្ងន់ទៅកាន់ប្រជាជនកម្ពុជាថា សំណើរបស់អង្គការសហប្រជាជាតិដែលស្នើឲ្យចោទប្រកាន់ជនសង្ស័យ២០-៣០នាក់ គឺជាជំហរដ៏រឹងមាំមួយដែលគួរតែយកមកពិចារណា ។ ខ្ញុំក៏បានសង្កត់ធ្ងន់ដែរថាព្រះរាជអាជ្ញាត្រូវតែមានឆន្ទានុសិទ្ធិសម្រេចថា ត្រូវចោទប្រកាន់អ្នកណាពីព្រោះអ្នកទាំងនោះចាំបាច់ត្រូវតែមានភាពឯករាជ្យ និងសុចរិត ។ យើងបានយល់ស្របថា អៀង សារី គឺជាបុគ្គលដែលត្រូវទទួលការចោទប្រកាន់ទោះបីជាគាត់បានបង្ហាញពីបញ្ហាប្លែកមួយចំនួនដើម្បីដោះស្រាយនឹងច្បាប់របស់តុលាការ ។ នៅខែមករា ឆ្នាំ២០០០ ទស្សនៈដែលថា អៀង សារី គឺជាជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានអះអាងបញ្ជាក់ ហើយមានការអះអាងបញ្ជាក់ម្តងទៀតនៅប៉ុន្មានខែក្រោយដែរ ។

ច្បាប់ព្រាងដែលក្រោយមកក្លាយទៅជាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានរៀបចំយ៉ាងលឿននៅចុងឆ្នាំ១៩៩៩ និងដើមឆ្នាំ២០០០ ។ នៅចុងឆ្នាំ១៩៩៩ ខ្ញុំបានរៀបចំច្បាប់ព្រាងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីឲ្យអាជ្ញាធរកម្ពុជាពិចារណា ។ នៅក្នុងច្បាប់ព្រាងនោះ ខ្ញុំបានរៀបរាប់ពីយុត្តាធិការលើបុគ្គលរបស់អង្គជំនុំជម្រះគឺ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងមនុស្សទាំងអស់ដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរបំផុតទៅលើច្បាប់កម្ពុជា» ។ សេចក្តីព្រាងច្បាប់នេះបានប្រមើលមើលជនសង្ស័យពីរក្រុម ។ ប៉ុន្តែខ្ញុំហាក់ដូចជាលោភលន់ដែលសំដៅទៅ «មនុស្សគ្រប់គ្នា» ដែលធ្វើឲ្យព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិធំធេងជាងគេ ។ សេចក្តីព្រាងច្បាប់កាលពីថ្ងៃទី១៨ និង ២៥ ខែមករា ឆ្នាំ២០០០ ដែលលើកឡើងដោយកម្ពុជាឲ្យបកស្រាយពីយុត្តាធិការលើបុគ្គលគឺ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់និងទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិត្រូវបានទទួលស្គាល់ដោយកម្ពុជា ហើយសកម្មភាពនោះត្រូវប្រព្រឹត្តឡើងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសកម្មភាពខាងលើត្រូវបានចាត់ទុកជាជនសង្ស័យ» ។ សូមធ្វើកំណត់សម្គាល់ថាពាក្យ «ទទួលខុសត្រូវខ្ពស់បំផុត» មិនទាន់បានបញ្ចូលទៅក្នុងសេចក្តីព្រាងនៅពេលនោះនៅឡើយទេ ។ បទដ្ឋាននៅពេលនោះគឺសរសេរថា «ទទួលខុសត្រូវ» ប៉ុន្តែពាក្យដែលថា «មនុស្សទាំងអស់» ដែលត្រូវទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការត្រូវបានបដិសេធ ហើយជំនួសមកវិញនូវពាក្យ «អ្នកដែលត្រូវទទួលខុសត្រូវ» ។

វាមានសារសំខាន់ក្នុងការដឹងថានៅពេលនោះ (ខែមករា ឆ្នាំ២០០០) ឌុច កំពុងស្ថិតនៅក្រោមការឃុំឃាំងជាងប្រាំមួយខែទៅហើយ ហើយគឺជាអ្នកដែលអ្នកចរចាទំនងជាចាត់ទុកថាជាចុងចោទ ។ ការសន្មតដែលថា ឌុច នឹងត្រូវយកមកកាត់ទោសនៅ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានរៀបរាប់នៅក្នុងការចរចានៅឆ្នាំបន្ទាប់ៗ ។ ជាងនេះទៅទៀត មិនមានចំណុចណាដែលអ្នកចរចាលើកឡើងថារាល់ជនសង្ស័យត្រូវតែជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទេ ។ នេះប្រហែលជាបញ្ហាដែលមិនសមហេតុផល ។ ទស្សនៈបែបនេះគួរតែបើកចំហរដើម្បីឲ្យមានការតវ៉ាដេញដោលដោយអ្នកចរចា ខណៈពេលដែលយើងចង់ធានាថាបុគ្គល ឌុច ដែលប្រហែលជាមិនមែនមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែគឺជាអ្នកដែលត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំនឹងត្រូវបានស៊ើបអង្កេត និងចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រុមទាំងពីរគឺក្រុមមេដឹកនាំជាន់ខ្ពស់ និងក្រុមទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មគឺស្ថិតនៅក្នុងបុគ្គលរបស់តុលាការ ។ នេះគឺជាចំណុចមួយនៅក្នុងការចរចាដែលខ្ញុំចាំបានថា ពេលនោះមានការស្នើឲ្យមានទម្រង់ច្បាស់លាស់ដើម្បីបង្រួញមកត្រឹមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មរបស់ ប៉ុល ពត ។ ហេតុផលមួយដែលយើងពន្យាតសេចក្តីអធិប្បាយយុត្តាធិការលើបុគ្គលទៅដល់ក្រុមបុគ្គលមួយទៀតដោយប្រើប្រាស់ពាក្យ «និង» នៅក្នុងឃ្លានោះ គឺដើម្បីសម្គាល់ក្រុមនោះ ។ បើពុំដូច្នោះទេ យើងនឹងសរសេរសេចក្តីព្រាងនោះថា «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរហើយ» ។ ប៉ុន្តែ យើងប្រហែលជាបានបដិសេធ ឬយ៉ាងហោចណាស់ស្នើឲ្យមានការបដិសេធការទទួលខុសត្រូវភាគច្រើនរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប្រសិនបើយើងប្រើប្រាស់ពាក្យ «ឬ» ដែលអាចបំបែកអត្តសញ្ញាណមេដឹកនាំពីអត្តសញ្ញាណទទួលខុសត្រូវ ។ វាប្រហែលជាមិនមានយុត្តិធម៌សម្រាប់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលមិនត្រូវទទួលខុសត្រូវខ្លាំងចំពោះឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃ ប៉ុន្តែគាត់ត្រូវស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការដោយគាត់មានតួនាទីជាមេដឹកនាំ ។ យើងបានយកចិត្តទុកដាក់ទៅលើចំណុចនេះពីព្រោះយើងបានដឹងហើយថាសមាជិករដ្ឋាភិបាលកម្ពុជានៅសម័យក្រោយក៏ធ្លាប់ជាមេដឹកនាំខ្មែរក្រហមដែរ ប៉ុន្តែយើងផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់ដែលនៅរស់និងត្រូវទទួលខុសត្រូវខ្ពស់ និងអ្នកដែលមានមុខងារខ្ពស់ដូចជា ឌុច ដែលបានចូលរួមក្នុងការប្រព្រឹត្តអំពើព្រៃផ្សៃ ។

សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០០ បានសរសេរពីការបែងចែកនិយមន័យក្រុមពីរនៅក្នុងយុត្តាធិការលើបុគ្គល ។ ការបកប្រែរបស់អង្គការសហប្រជាជាតិសរសេរថា «មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកផ្សេងដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា» ។ ឃ្លានេះបានសំដៅទៅលើមេដឹកនាំជាន់ខ្ពស់ និងក្រុមមនុស្សផ្សេងទៀតថាស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០០ សេចក្តីព្រាងលើកទីមួយនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានលេចរូបរាងឡើង ។ ការបកស្រាយតែទៅលើយុត្តាធិការលើបុគ្គលរបស់តុលាការដែលនៅក្នុងឃ្លារបស់កិច្ចព្រមព្រៀងសំដៅទៅដល់ ១) «ការនាំយកអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តឡើងនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ទៅរកយុត្តិធម៌» ២) «ការនាំយកមេដឹកនាំខ្មែរក្រហមទៅរកយុត្តិធម៌» និង ៣) នាំយកអ្នកដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរបំផុតទៅលើសិទ្ធិមនុស្សដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺពីឆ្នាំ១៩៧៥-១៩៧៩ ទៅរកយុត្តិធម៌» ។

នៅក្នុងលិខិតមួយពីអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន នៅខែមីនា ឆ្នាំ២០០០ លោក កូហ្វី អាណាន់ បានបកស្រាយពីយុត្តាធិការលើបុគ្គលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចតទៅ ៖ «យុត្តាធិការលើបុគ្គលរបស់តុលាការគួរតែមានកំណត់មកត្រឹមមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើ

ច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់និងទំនៀមទម្លាប់អន្តរជាតិ និង អនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយកម្ពុជា និងដែលត្រូវ បានប្រព្រឹត្តឡើងនៅអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩»។ ការបកស្រាយទូទៅទៅ លើភាសានេះទាក់ទងនឹងក្រុមពីរនោះគឺ ១) មេដឹកនាំជាន់ខ្ពស់ និង ២) «អ្នកដែលត្រូវទទួលខុសត្រូវ»។ វាហាក់ដូចជាមិនត្រឹម ត្រូវប្រសិនបើយើងសំដៅឃ្លានេះទៅរកតែមេដឹកនាំជាន់ខ្ពស់ ដែលទទួលខុសត្រូវ។ ម្យ៉ាងទៀត ប្រសិនបើយើងមានចេតនាដូច នោះ នោះភាសាសាមញ្ញនឹងត្រូវបានយកមកប្រើប្រាស់ដើម្បី បង្ហាញពីបំណងនោះ ជាឧទាហរណ៍គឺសរសេរទៅជា «មេដឹកនាំ ជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យដែលទទួលខុសត្រូវចំពោះ...»។

លោក ហែន កូរ៉ែល ដែលជាក្រុមប្រឹក្សាច្បាប់នៅ អង្គការសហប្រជាជាតិបានបង្ហាញពីការព្រួយបារម្ភចំពោះលោក សុខ អាន ដែលជាមន្ត្រីជាន់ខ្ពស់និងមន្ត្រីទទួលបន្ទុកនៅទីស្តីការ នាយករដ្ឋមន្ត្រី តាមរយៈលិខិតចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ ថាទម្រង់យុត្តាធិការបុគ្គលមានលក្ខណៈទូលាយជាងអ្វីដែលមេធាវី អង្គការសហប្រជាជាតិមានបំណងចង់បាន។ ការព្រួយបារម្ភ របស់លោកគឺការដែលមិនមានការកំណត់ទៅលើក្រុមពីរនោះ គឺថាតើក្រុមទីពីរ «ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម» នឹងមាន ទំហំធំដល់កម្រិតណា? លោក កូរ៉ែល មានការព្រួយបារម្ភថា ប្រជាជនកម្ពុជាកំពុងតែស្នើឲ្យមានជនសង្ស័យដែលមានសក្តានុពល ច្រើនពេក ប៉ុន្តែទស្សនៈរបស់លោកក៏បានឆ្លុះបញ្ចាំងពីការកាត់ បន្ថយជនសង្ស័យដែលថាមានចំនួនពី២០ទៅ៣០នាក់ និងដែល ស្នើឡើងដំបូងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ លោក កូរ៉ែល ចង់បានព្រំដែនកំណត់ ប៉ុន្តែជាព្រំដែនកំណត់ដែលសមហេតុ សមផល។ ខាងក្រោមនេះគឺជាកថាខណ្ឌដែលជាប់ពាក់ព័ន្ធនឹង លិខិតរបស់គាត់៖

«ការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងយន្តការភាគីទីបីគឺមាន បង្ហាញនៅក្នុងមាត្រា១ នៃច្បាប់ព្រាងរបស់អ្នក។ នៅក្នុងកិច្ច ពិភាក្សាដែលយើងបានពិភាក្សាគ្នា ខ្ញុំបានបង្ហាញពីការព្រួយ បារម្ភថា បទបញ្ញត្តិនេះប្រហែលជាទូលាយពេកសម្រាប់ឆ្លុះ បញ្ចាំងទស្សនៈដែលខ្ញុំយល់ថារដ្ឋាភិបាលបានដឹងពីកិច្ចខំប្រឹងប្រែង ទាំងមូលរួចហើយ។ នៅពេលដែលលោក ឌីម យិនទៀង មក ទទួលខ្ញុំនៅព្រលានយន្តហោះ ខ្ញុំបានលើកឡើងពីបញ្ហានេះជា មួយគាត់។ បន្ទាប់មក គាត់បានលើកឡើងពីអ្នកដែលត្រូវទទួល ខុសត្រូវ «ខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅអំឡុង ពេលនោះ។ ក្រោមនោះ ខ្ញុំបានបញ្ចេញប្រតិកម្មដោយលើកឡើង ថា ចំណុចនេះមិនមាននៅក្នុងច្បាប់ព្រាងទេ។ ពាក្យនៅក្នុងនោះ គឺ អ្នកទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ។ ដូច្នេះតើនេះគឺជាចេតនាពិតប្រាកដឬទេ? សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាត្រូវតែមាន អំណះអំណាងច្បាស់លាស់មួយ។ ការអនុវត្តអំណាចដ៏ទូលាយ ដែលដូចនឹងអ្វីដែលបានរៀបរាប់នៅក្នុងមាត្រាមួយនឹងធ្វើឲ្យអ្នក ទទួលទាំងនោះទទួលការរិះគន់នៅពេលដែលអ្នកទាំងនោះមិនបាន ស្វែងរកសំណុំរឿងដែលស្ថិតនៅក្នុងបទបញ្ញត្តិនោះច្រើនជាង។

«សម្តីរបស់ លោក ឌីម យិនទៀង នៅឯព្រលានយន្ត ហោះធ្វើឲ្យខ្ញុំជឿថាទស្សនៈរបស់រដ្ឋាភិបាលទៅលើវិសាលភាពនៃ ច្បាប់ប្រហែលជាមិនបានឆ្លុះបញ្ចាំងទៅលើច្បាប់ព្រាងទាំងស្រុង នោះទេ។ ហើយប្រសិនបើវាគឺជាការពិតមែន យើងត្រូវជួប ប្រទះនឹងបញ្ហាសំខាន់មួយដែលត្រូវកែប្រែមុនពេលដែលច្បាប់ នោះត្រូវបានអនុម័ត។ ខ្ញុំយល់ថានេះគឺជាបញ្ហាផ្ទៃក្នុងកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះក៏អាចឆ្លុះបញ្ចាំងពីការផ្សារ ដ៏លំបាកដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើត នៅក្នុងមាត្រានៃកិច្ចសហការដែរ។ ដូច្នេះ មធ្យោបាយនៃការ បង្កើតអង្គជំនុំជម្រះអាចបង្ហាញថាមានតែសំណុំរឿងមួយចំនួន ប៉ុណ្ណោះនឹងត្រូវបានយកមកដោះស្រាយ។ ដូច្នេះ ខ្ញុំលើកឡើង ម្តងទៀតដើម្បីសង្កត់ធ្ងន់នូវអ្វីដែលខ្ញុំបាននិយាយនៅក្នុងកិច្ច ពិភាក្សាគឺថារដ្ឋាភិបាលចាំបាច់ត្រូវតែពិនិត្យយ៉ាងល្អិតល្អន់ទៅលើ មាត្រា១ នៃច្បាប់ព្រាង។ រាល់ការកែប្រែទៅលើបទបញ្ញត្តិនេះ ត្រូវតែស្របទៅតាមអត្ថន័យនៃការផ្លាស់ប្តូរលិខិតរបស់អគ្គលេខា ធិការអង្គការសហប្រជាជាតិ និងនាយករដ្ឋមន្ត្រី និងស្របតាម កថាខណ្ឌទី៣ នៃមាត្រា៨ និងកថាខណ្ឌទី៣ នៃមាត្រា៩ ស្តីពីកិច្ច សហប្រតិបត្តិការ។

អាស្រ័យហេតុនេះ នៅខែមីនា ឆ្នាំ២០០០ មេធាវី

អង្គការសហប្រជាជាតិកំពុងតែព្យាយាមកែសម្រួលភាសាប្រប្រូកប្រប្រល់របស់រដ្ឋាភិបាលដែលស្នើឲ្យមានជនសង្ស័យច្រើនដែលផ្ទុយគ្នាពីទស្សនដែលជំរុញឲ្យចោទប្រកាន់ជនសង្ស័យតែប៉ុន្មាននាក់ និង ឌុច ។ ការធ្វើបែបនេះបានស្នើឲ្យមានភាពផ្ទុយគ្នាខាងអំណាចរបស់អង្គជំនុំជម្រះដែលមាននៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺមេធាវីអង្គការសហប្រជាជាតិចង់ទាញទៅក្រោយ (នៅក្នុងក្រុមទីពីរ) ចំណែកឯភាគីខាងកម្ពុជាចង់បង្កើតភាសាដែលអាចគ្របដណ្តប់ទៅលើអ្នកដែលត្រូវ «ទទួលខុសត្រូវ» ចំពោះឧក្រិដ្ឋកម្មទូលាយជាងនេះ ។

នៅក្នុងកំណត់សម្គាល់មួយដែលផ្ញើមកខ្ញុំនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ លោក កូរ៉ែល បានបកស្រាយថា «និយមន័យមាត្រា១ (ទាក់ទងនឹងយុត្តាធិការលើបុគ្គល) ប្រហែលជាមិនអាចឆ្លុះបញ្ចាំងទស្សនដែលថាប្រជាជនកម្ពុជាមានវិសាលភាពចំពោះយុត្តាធិការទេ» ។ ការផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់ គឺត្រឹមត្រូវ ប៉ុន្តែការយោងទៅ «អ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមានលក្ខណៈទូលាយពេកដែលអាចរួមបញ្ចូលគ្រប់មនុស្សដែលជាប់ពាក់ព័ន្ធ ។ ចម្ងល់របស់ខ្ញុំគឺថាវាគឺជាចេតនាឬទេ? លក្ខណៈសម្បត្តិមួយចំនួនមានសារសំខាន់ ហើយភាសានៅក្នុងនោះ និងអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតក៏មានសារសំខាន់ដែរ» ។ ខ្ញុំបានរួមបញ្ចូលភាសានេះនៅក្នុងសំណើកែសម្រួលច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០០ ។ ហើយនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០០ ខ្ញុំបានលើកឡើងនូវបញ្ហានេះទៅឲ្យអ្នកចរចាថា គួរតែមានការអះអាង «ការបញ្ជាក់ពីដែនកំណត់នៃជនសង្ស័យ» ។

ត្រឡប់ទៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ មានលេចឡើងនូវ «សេចក្តីព្រាងចុងបញ្ចប់នៅក្នុងគណៈកម្មការច្បាប់នៃសភាជាតិដែលរួមមានអនុសាសន៍ពីក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស និងគណៈកម្មការប្រព្រឹត្តកម្មសិទ្ធិមនុស្សនៅកម្ពុជា» ដែលជាសេចក្តីព្រាងចុងក្រោយនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មានការបញ្ជាក់ដ៏សំខាន់មួយនៅក្នុងសេចក្តីព្រាងនោះដែលរួមមានការអះអាងម្តងទៀតនូវទម្រង់នៃក្រុមមនុស្សពីរក្រុម ។ យុត្តាធិការលើបុគ្គលសរសេរថា «មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមព្រហ្មទណ្ឌកម្ពុជា» ។

នៅចុងខែមេសា ឆ្នាំ២០០០ ព្រឹទ្ធសមាជិក ចន ឃែរី បានធ្វើទស្សនកិច្ចមកភ្នំពេញ ដើម្បីដោះស្រាយផ្នែកខ្លះនៃការលំបាកដែលមាននៅក្នុងកិច្ចចរចា ។ មុននឹងលោកធ្វើដំណើរមកភ្នំពេញ លោកបានពិភាក្សាជាមួយខ្ញុំអំពីស្ថានភាពនៃការធ្វើច្បាប់ព្រាង ។ នៅក្នុងលិខិតរបស់ខ្ញុំដែលផ្ញើទៅឲ្យគាត់នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ខ្ញុំបានអះអាងបញ្ជាក់ថា «អង្គការសហប្រជាជាតិបានឈានទៅមុខបានឆ្ងាយដោយមានការយល់ស្របគ្នា និងគាំទ្រចំពោះការបង្រួមទំហំយុត្តាធិការលើបុគ្គលនៅក្នុងមាត្រា១នៃច្បាប់ព្រាង ។ ពីមុន មេធាវីអង្គការសហប្រជាជាតិបាននិយាយពីតម្រូវការចង់ឲ្យមានដែនកំណត់ចំពោះយុត្តាធិការទូលាយដើម្បីឆ្លើយតបនឹងការចង់បានរបស់អង្គការក្រៅរដ្ឋាភិបាលដែលចង់ដាក់សំណាញ់ធំចោទប្រកាន់ជនសង្ស័យ» ។ «វិសាលភាពដ៏ទូលាយ» នោះបានប្រមើលមើលឃើញជនសង្ស័យប្រមាណ ២០នាក់ ។

សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ បានរួមបញ្ចូលភាសាដែលស្នើដោយអង្គការសហប្រជាជាតិ និង «ធ្វើកំណត់សម្គាល់» ដោយសរសេរពាក្យនោះយ៉ាងជិត ។ ផ្នែកដកស្រង់ដែលជាប់ពាក់ព័ន្ធអានថាៈ «មាត្រា១ៈ គោលបំណងនៃច្បាប់នេះគឺដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌និងទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយកម្ពុជាដែលបានប្រព្រឹត្តឡើងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

សម្គាល់ ៈ គណៈប្រតិភូអង្គការសហប្រជាជាតិនៅ

ដំណាក់កាលដំបូងបានបង្ហាញពីការព្រួយបារម្ភថា មាត្រា១ព្រាងនៅពេលនោះគឺមានលក្ខណៈទូលាយពេក ។ វាបានរួមបញ្ចូលគ្រប់មនុស្សដែលមានជាប់ពាក់ព័ន្ធនឹងសកម្មភាពឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ លទ្ធផលបែបនេះមិនមែនកើតឡើង ដោយចេតនារបស់រដ្ឋាភិបាលទេ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាមិនអាចដោះស្រាយទំហំនៃសំណុំរឿងដ៏ធំនេះទេ ។ អាស្រ័យហេតុនេះ គណៈប្រតិភូអង្គការសហប្រជាជាតិបានបន្ថែមពាក្យ «ខ្ពស់បំផុត» ដើម្បីកំណត់ទៅលើវិសាលភាពនៃយុត្តាធិការលើបុគ្គលឲ្យសមរម្យ ។ ប្រសិនបើដំណោះស្រាយផ្សេងទៀតត្រូវបានយកមកពិចារណាដើម្បីសម្រេចនូវគោលដៅដដែលនោះ អង្គការសហប្រជាជាតិប្រាកដជានឹងរៀបចំត្រួតពិនិត្យដំណោះស្រាយនោះ ។ នៅក្នុងសំណើរបស់ឯកឧត្តម សុខ អាន គណៈប្រតិភូអង្គការសហប្រជាជាតិបានពិនិត្យទៅលើដំណោះស្រាយបែបនោះ និងសង្កត់ធ្ងន់ថាការបង្កើតមាត្រានេះគឺជាសេចក្តីសម្រេចនយោបាយដែលអនុវត្តនៅកម្រិតជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវតែបញ្ជាក់ម្តងទៀតថាភាសានៅក្នុងបទបញ្ញត្តិនេះត្រូវតែស្របនឹងលទ្ធភាពរបស់អង្គជំនុំជម្រះ ។ ជាមួយនឹងបទបញ្ញត្តិនេះ យើងបានស្នើឲ្យមានពាក្យជំនួស ឧទាហរណ៍ អាចជាជនដៃដល់ដែលប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវបំផុត និងប្រព្រឹត្តការរំលោភបំពានយ៉ាងធ្ងន់ធ្ងរជាដើម ។ សូមធ្វើកំណត់សម្គាល់ថា នៅពេលដែលមាត្រា១ត្រូវបានបញ្ចប់ ត្រូវកែសម្រួលមាត្រា២ ដើម្បីឲ្យស្របគ្នា ។

ដូច្នេះ នៅខែកក្កដា ឆ្នាំ២០០០ មេធាវីអង្គការសហប្រជាជាតិបានស្នើឲ្យមានការកំណត់ក្រុមទាំងពីរ ដែលក្រុមទីពីរ គឺ «អ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត» ។ ភាសាដែលស្នើដោយអង្គការសហប្រជាជាតិនៅក្នុងមាត្រា១ត្រូវបានយកទៅប្រើប្រាស់នៅក្នុងច្បាប់ព្រាងដែលរាយការណ៍ដោយកាសែតភ្នំពេញប៉ុស្តិ៍ លេខ ៩/២២ ២៧តុលា-២៩ វិច្ឆិកា ឆ្នាំ២០០០ ។

មុនពេលដែលព្រឹទ្ធសមាជិក កែរី ធ្វើទស្សនកិច្ចមកភ្នំពេញនៅខែវិច្ឆិកា ឆ្នាំ២០០០ ខ្ញុំបានសរសេរកំណត់សម្គាល់មួយផ្ញើទៅលោកដោយនិយាយដោយផ្អែកថា «វាមានសារសំខាន់ដែលថា លោកចាំបាច់ត្រូវតែប្រកាសពីការបិទមាត្រា១នៃច្បាប់ព្រាងស្តីពីយុត្តាធិការលើបុគ្គល» និងធានាថា ភាសានៅក្នុងមាត្រា១គឺជាអ្វីដែលអង្គការសហប្រជាជាតិចង់បាន ឧទាហរណ៍ គឺធានាថាមាត្រា១មាន រួមបញ្ចូលពាក្យថា «អ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត» ហើយលោកគួរតែបញ្ជាក់ពីចំណុចនេះជាមួយ សុខ អាន» ។

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយសរសេរថា «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា» ។ នៅថ្ងៃនោះ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានចេញសេចក្តីថ្លែងការណ៍ដោយប្រកាសដោយផ្អែកថា «សហរដ្ឋអាមេរិកស្វាគមន៍នូវសកម្មភាពរបស់សភាជាតិកម្ពុជាដែលបានអនុម័តច្បាប់ព្រាងដើម្បីបង្កើតអង្គជំនុំជម្រះសម្រាប់ស៊ើបអង្កេត និងចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតអំពើព្រៃផ្សៃ ដែលបានកើតឡើងនៅប្រទេសកម្ពុជាអំឡុងឆ្នាំ១៩៧៥ - ១៩៧៩» ។

វាប្រហែលជាគួរឲ្យកត់សម្គាល់ថានៅក្នុងបទបង្ហាញជាផ្លូវការរបស់លោកទេសរដ្ឋមន្ត្រី សុខ អាន និងការធ្វើអនុសាសន៍ស្តីពីច្បាប់ព្រាងរបស់លោកទៅកាន់សភាជាតិនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ និងនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ លោកមិនបានលើកឡើងពីយុត្តាធិការលើបុគ្គលនៅអង្គជំនុំជម្រះសូម្បីតែម្តង» ។ ភាពស្ងប់ស្ងាត់នេះគឺជាការយល់ស្របមួយទោះបីជាលោកបានលើកឡើងបញ្ហាដែលស្មុគស្មាញ និងនាំឲ្យមានការពន្យារការចរចាមួយចំនួន ។ យើងប្រាកដជាគិតថា ប្រសិនបើចំនួនដ៏តិចនៃជនសង្ស័យ (ដូចជា៥នាក់) មានសារសំខាន់ចំពោះរដ្ឋាភិបាលកម្ពុជា ហើយផ្នែកមួយនៃប្រវត្តិសាស្ត្រច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះនោះ ទេសរដ្ឋមន្ត្រី សុខ អាន ប្រាកដជានឹងលើកឡើងពីចំណុចមួយដើម្បីសង្កត់ធ្ងន់ទៅលើវិសាលភាពមានកំណត់ចំពោះយុត្តាធិការលើបុគ្គលនៅពេលដែលគាត់ធ្វើបទបង្ហាញជាសាធារណៈនៅក្នុងសភាជាតិហើយ ។ ប៉ុន្តែ រឿងនោះមិនបានកើតឡើងទេ ។

នៅក្នុងលិខិតផ្ញើឲ្យទេសរដ្ឋមន្ត្រី សុខ អាន ដែលចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ ក្រុមប្រឹក្សាច្បាប់អង្គការសហប្រជាជាតិ ហែន កូរ៉ែល មិនបានលើកឡើងពីយុត្តាធិការលើបុគ្គលថា ជាបញ្ហាដែលគាត់ឃើញនៅក្នុងច្បាប់ដែលត្រូវបានអនុម័តដោយសភាជាតិនៃកម្ពុជាទេ។ ការមិនលើកឡើងនេះបង្ហាញថា នៅទីបញ្ចប់ភាសាដែលនិយាយពីយុត្តាធិការលើបុគ្គលត្រូវបានដោះស្រាយដោយគ្រប់ភាគី។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ កាសែត អេ ភី បានចេញរបាយការណ៍ថា «នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថារដ្ឋាភិបាលត្រៀមនឹងចាប់ជនទាំងឡាយណាដែលតុលាការនឹងចោទប្រកាន់ ប៉ុន្តែគាត់បានព្រមានមិនឲ្យមានការចោទប្រកាន់ អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេស និងជាប្អូនថ្លៃរបស់ ប៉ុល ពត ដោយនិយាយថាវាអាចនាំឲ្យមានសង្គ្រាម។ ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីខុទ្ទកាល័យ សុខ អាន ដែលទទួលខុសត្រូវចំពោះតុលាការបានអះអាងថា អៀង សារី អាចស្ថិតនៅក្រោមការស៊ើបអង្កេត»។ លោកបាននិយាយថា «នៅពេលដែលច្បាប់ត្រូវបានអនុម័ត យើងទាំងអស់គ្នាត្រូវតែនៅក្រោមច្បាប់»។ ប៉ុន្មានឆ្នាំក្រោយមក នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានប្រឆាំងនឹងដីកាចោទប្រកាន់ទេ ហើយការកាត់ទោស អៀង សារី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងប្រព្រឹត្តទៅនៅពេលខាងមុខ។

បន្ទាប់មកនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ ណាយ៉ាន់ចាន់ដា បានរាយការណ៍នៅក្នុងទស្សនាវដ្ដី *Far Eastern Economic Review* ថាលោកទេសរដ្ឋមន្ត្រី សុខ អាន បានមានប្រសាសន៍ថា «សេចក្តីសម្រេចថាតើត្រូវកាត់ទោសអ្នកណាខ្លះនឹងត្រូវធ្វើឡើងដើម្បីឲ្យស្របនឹងច្បាប់»។ «សេចក្តីថ្លែងការណ៍ផ្លូវការមិនអាចកំណត់ថាអ្វីជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវយកមក កាត់ទោសទេ ដូច្នេះវាត្រូវតែមានការកែសម្រួលដើម្បីកំណត់ថា អ្នកណាជាគោលដៅនៃការកាត់ទោស»។ ពាក្យសម្តីទាំងនេះគឺជាសញ្ញាណដែលអាចបញ្ជាក់ថាអាចមានការជជែកពិភាក្សាទៅលើភាសាយុត្តាធិការលើបុគ្គលថែមទៀត ប៉ុន្តែភាពឯករាជ្យរបស់អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាត្រូវរួមបញ្ចូលការបកស្រាយបែបនេះ។

នៅថ្ងៃបន្ទាប់ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើទស្សនកិច្ចទៅអន្លង់វែង ជាកន្លែងដែល តា ម៉ុក ត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៩៩ និងជាមូលដ្ឋានខ្មែរក្រហមចុងក្រោយដែលតស៊ូជាមួយរដ្ឋាភិបាល។ នៅទីនោះគាត់បាននិយាយជាមួយខ្មែរក្រហមប្រុស ស្រី និងក្មេងប្រមាណ ៣០០០នាក់ និងអគ្គរដ្ឋទូតរបស់អាស៊ាន អគ្គរដ្ឋទូតកូរ៉េខាងជើង និងអនុប្រធានបេសកកម្មមកពីស្ថានទូតអង់គ្លេស ប្រធានមូលនិធិរូបិយវត្ថុអន្តរជាតិ ទីភ្នាក់ងារផ្តល់ជំនួយ និងក្រុមមិនមែនរដ្ឋាភិបាលផ្សេងទៀត (របាយការណ៍ព័ត៌មានខ្លះបានប៉ាន់ប្រមាណថា មានប្រជាជននៅអន្លង់វែងតិចជាងនេះបានចូលរួមស្តាប់សុន្ទរកថា គឺជាងមួយពាន់នាក់)។ ខ្ញុំបានទទួលរបាយការណ៍ដែលមិនទាន់បែងចែកជាក្រុមស្តីពីការធ្វើទស្សនកិច្ចរបស់លោកពីអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា គឺលោក វៀតមែន។ គាត់បានសរសេរដោយផ្អែកថា «ហ៊ុន សែន បានសង្កត់ធ្ងន់ជាច្រើនលើកច្រើនសាថា វិសាលភាពនៃការចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺមានតែមេដឹកនាំដែលទទួលខុសត្រូវលើបទឧក្រិដ្ឋ និងអ្នកប្រព្រឹត្តបទល្មើសសាហាវព្រៃផ្សៃ ដូចជា ឌុច ដែលជាប្រធានមន្ទីរធ្វើទារុណកម្មនៅភ្នំពេញ គឺទួលស្លែងទេ។ ដោយដឹងពីភាពចាំបាច់សម្រាប់អប់រំអ្នកស្តាប់ឲ្យដឹងពីភាពឯករាជ្យនិងភាពសុចរិតរបស់តុលាការ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសង្កត់ធ្ងន់ថាតុលាការនឹងត្រូវធ្វើការសម្រេចគ្រប់បែបយ៉ាងទៅលើថាតើត្រូវចោទប្រកាន់អ្នកណាពីបទឧក្រិដ្ឋនោះ? ហើយលោកផ្ទាល់ដែលជានាយករដ្ឋមន្ត្រី ឬសមាជិកផ្នែកនីតិប្រតិបត្តិ និងច្បាប់ផ្សេងទៀតរបស់រដ្ឋាភិបាលមិនអាចជ្រៀតជ្រែកទៅក្នុងសេចក្តីសម្រេចរបស់តុលាការបានឡើយ»។

កាសែត *Deutsche Presses-Agentur* បានរាយការណ៍ថា នៅថ្ងៃនោះនិងនៅពេលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថា លោកបានមានប្រសាសន៍ថា «សូមប្រជាជនដែលមានទំនាក់ទំនងជាមួយខ្មែរក្រហមកុំមានអារម្មណ៍ភ័យខ្លាច ឬរត់ចូលព្រៃដើម្បីគាំទ្រអតីតមេដឹកនាំរបស់ខ្លួនឲ្យសោះ។ យើងមិនយកប្រជាជនកម្ពុជា១២លាននាក់ ឬសូម្បី១.០០០នាក់ ឬសូម្បី ១០០នាក់ទៅតុលាការទេ គឺយកតែមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះ»។

អត្ថបទរាយការណ៍នោះបានបន្តទៀតថា លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ពីការព្រួយបារម្ភរបស់ខ្លួនថាលោកនឹងធ្វើអន្តរាគមន៍ទៅលើដំណើររបស់តុលាការកុំឲ្យចោទប្រកាន់ អៀង សារី ដែលធ្លាប់ទទួលបានការប្រទានការលើកលែងទោស ដោយសារគាត់បានដឹកនាំខ្មែរក្រហមចុះចូលជាមួយរដ្ឋាភិបាល ។ លោកបានមានប្រសាសន៍ថា «ខ្ញុំមិនអាចធានាចំពោះមុខអ្នកទាំងអស់គ្នាថាតុលាការនឹងមិនចោទប្រកាន់អ្នកទាំងនោះទេ ពីព្រោះនោះជាអំណាចរបស់តុលាការ ។ ខ្ញុំមិនមានសិទ្ធិការពារនរណាម្នាក់មិនឲ្យទទួលការចោទប្រកាន់ឡើយ ហើយវាមិនមានច្បាប់ណាអនុញ្ញាតឲ្យខ្ញុំធ្វើដូច្នោះផងដែរ» ។

កាសែត អា.អេហ្វ.ប៉េ ក៏បានរាយការណ៍ថា នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០១ នៅពេលដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើទស្សនកិច្ចទៅអន្លង់វែង លោកបានអះអាងថា «ការកាត់ទោសមនុស្ស៤ឬ១០នាក់នឹងអាចនាំយកយុត្តិធម៌ដល់ប្រជាជនកម្ពុជា១២លាននាក់ហើយ ។ វាគ្រប់គ្រាន់ហើយ» ។ កាសែតក្យូតូក៏បានរាយការណ៍ថា លោក ហ៊ុន សែន មានប្រសាសន៍ពីចំនួនអ្នកដែលត្រូវកាត់ទោសគឺ «៤ឬ៥ទៅ១០នាក់ប៉ុណ្ណោះ» ។

ប្រវត្តិសង្ខេបពីការចរចា និងច្បាប់ព្រាងចុងក្រោយនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងយុត្តាធិការលើបុគ្គល នៅអង្គជំនុំជម្រះគួរតែអាចបង្ហាញថា ខណៈពេលដំបូងដែលរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ភាសាដែលអាចបង្កើននូវចំនួនជនសង្ស័យ មន្ត្រីអង្គការសហប្រជាជាតិបានដាក់ដែនកំណត់ទៅលើភាសានោះ ។ ប៉ុន្តែដោយខ្ញុំក៏បានរួមចំណែកជាច្រើនឆ្នាំ នៅក្នុងការចរចានោះដែរ ខ្ញុំដឹងថាអ្នកចរចាអង្គការសហប្រជាជាតិមិនបានធ្វើការបកស្រាយទៅលើយុត្តាធិការលើបុគ្គលដើម្បីកំណត់ចំនួនជនសង្ស័យមកត្រឹមប្រាំនាក់ទេ ។ ដូចដែលខ្ញុំបានសរសេរនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ខ្ញុំបានសរសេរថាជាធម្មតាអ្នកចរចា «បាននិយាយពីបុគ្គលដល់ទៅ១៥នាក់ ដែលត្រូវទទួលការចោទប្រកាន់» ។ ចំនួននោះបានថយចុះខ្លាំង ពីព្រោះដំបូងអង្គការសហប្រជាជាតិ និងអង្គភាពក្រៅរដ្ឋាភិបាលសង្ឃឹមថានឹងមានជនសង្ស័យ២០ឬ៣០នាក់ ឬច្រើនជាងនេះ ត្រូវបានយកទៅកាត់ទោស ។ ដូច្នេះការដែលថាអាជ្ញាធរកម្ពុជាបកស្រាយទៅលើភាសាចុងក្រោយរបស់យុត្តាធិការលើបុគ្គលថាកំណត់យកជនសង្ស័យត្រឹម៥នាក់ គឺមិនត្រឹមត្រូវដោយយោងទៅតាមការចរចាជាច្រើនឆ្នាំ និងការដែលកម្ពុជាបានគាំទ្រឲ្យយុត្តាធិការលើបុគ្គលកំណត់ទៅលើមនុស្សច្រើនជាងនេះនៅឆ្នាំ២០០០ ។

ជាងនេះទៅទៀត ដូចដែលខ្ញុំបានរៀបរាប់នៅក្នុងអត្ថបទនេះ មិនមានមធ្យោបាយសមស្របណាអាចយកមកបកស្រាយយុត្តាធិការលើបុគ្គលរបស់ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះឲ្យកំណត់ជនសង្ស័យមកត្រឹមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃនៃរបប ប៉ុល ពត ទេ ។ បណ្តឹងសារទុក្ខរបស់ ឌុច ប្រឆាំងនឹងការដាក់ឲ្យគាត់ស្ថិតនៅក្នុងយុត្តាធិការលើបុគ្គលនៃអង្គជំនុំជម្រះគឺត្រូវច្រានចោលដោយសារប្រវត្តិនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបកស្រាយទៅលើវេយ្យាករណ៍នៃឃ្លានោះ និងការបង្ហាញយ៉ាងច្បាស់ទៅលើគោលបំណងរបស់អ្នកចរចាកម្ពុជា និងអង្គការសហប្រជាជាតិមុនពេលអនុវត្តច្បាប់នោះ ។

វាមិនស័ក្តិសមដែលថាសហព្រះរាជអាជ្ញាកម្ពុជា លោកស្រី ជា លាង បានប្រកាសនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ថា ជនសង្ស័យបន្ថែមដែលមិនបញ្ចេញឈ្មោះនៅក្នុង «សំណុំរឿង ០០៣ មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យទេ» ។ ដោយដឹងពីព័ត៌មានអំពីជនសង្ស័យ និងឧក្រិដ្ឋកម្មរបស់អ្នកទាំងនោះពីប្រភពសារព័ត៌មាន និងដោយដឹងពីការបកស្រាយដ៏សមហេតុផលទៅលើយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះទាក់ទងនឹង «អ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត» តាមរយៈប្រវត្តិនៃការចរចាទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តើលោកស្រី និងសហចៅក្រមស៊ើបអង្កេតមានទស្សនៈនេះ ដោយរបៀបណា? ។ តើនេះគឺជាការនិយាយពីនយោបាយ ឬក៏ច្បាប់? ខ្ញុំសង្ឃឹមថាសហចៅក្រមស៊ើបអង្កេតនឹងធ្វើការស៊ើបអង្កេតឲ្យស្របទៅតាមការស្នើរបស់ អនឌ្រូ ខេលី និងឈប់ចេញដីកាមិន

សមរម្យដែលគ្រាន់តែបង្ហាញពីភាពអសន្តិសុខនៃសកម្មភាពនៅអតីតកាលប៉ុណ្ណោះ ។ ទោះបីជាសហចៅក្រមស៊ើបអង្កេត ឬភាគីផ្សេងទៀតអាចប្តឹងឧទ្ធរណ៍ក៏ដោយ នៅចុងបញ្ចប់អង្គបុរេជំនុំជម្រះត្រូវតែបង្ហាញពីភាពសុចរិតឲ្យស្របទៅតាមភាពដើមនៃការបង្កើតអង្គជំនុំជម្រះ គឺត្រូវមានការកំណត់ជនសង្ស័យឲ្យសមហេតុផល គឺជនសង្ស័យពីរក្រុម ៖ អ្នកដែលជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម និងអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែលមានចែងនៅក្នុងមាត្រា១នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ហើយត្រូវតែមានប្រភពដែលអាចស្វែងរកបាន ។ ពិភពលោកកំពុងតែមើលទៅលើបញ្ហានេះយ៉ាងយកចិត្តទុកដាក់ ហើយប្រវត្តិសាស្ត្រគឺជាការសម្រេចចុងក្រោយ ។

**ដេវីដ សេហ្វ័រ**

# ស្វែងរកកុមារកម្ពុជាមកពីជំរំហ្កាឡង់តាមរយៈរូបថត







ប្រសិនបើនរណាម្នាក់ដែលជាមនុស្សនៅក្នុងចំណោមកុមារដូចនៅក្នុងរូបថត នេះឬដឹងថាកុមារទាំងនេះរស់នៅទីណា សូមទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៩០ ៥៥ ៩៥ ។

# រឿងរ៉ាវពិតរបស់ខ្ញុំ



ឡៃ ហួត

## ព្រឹត្តិការណ៍ថ្ងៃ១៧មេសា

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំស្លៀកពាក់ឯកសណ្ឋានសិស្ស ហើយត្រៀមចេញទៅរៀនដូចសព្វដង ។ ពេលដែលខ្ញុំបើកទ្វារផ្ទះឡើង ស្រាប់តែឃើញសភាពការណ៍ខុសពីប្រក្រតី ដោយប្រជាពលរដ្ឋកំពុងឈរត្រៀបត្រាតាមដងផ្លូវ និងតាមផ្ទះនីមួយៗមានដោតទង់ស ខ្លះទៀតយកអាវសទៅចងជាសញ្ញា និងឮសំឡេងប្រកាសតាមវិទ្យុឲ្យប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញចេញមកស្វាគមន៍កងទ័ពបដិវត្តន៍រំដោះជាតិ ។

ដោយសារតែឃើញសភាពការណ៍ខុសប្លែកបែបនេះ ខ្ញុំក៏មិនទៅរៀនដែរ ដោយឮចាស់ៗនាំគ្នានិយាយគ្នាថា «ស្រុកទេសបានរំដោះហើយ ប្រទេសយើងអស់សង្គ្រាម ប្រទេសយើងមានសន្តិភាពហើយ» ។ ម្នាក់ៗសប្បាយចិត្តណាស់ ខ្លះទៀតយកនំចំណីផ្លែឈើ ឬភេសជ្ជៈដាក់លើតុតាមដងវិថី ដើម្បីទទួលកងទ័ពរំដោះជាតិ ដោយខ្ញុំក៏ឈរទះដៃអបអរសាទរដូចក្មេងចាស់ប្រុសស្រីដទៃទៀតដែរ ។ បន្ទាប់មក ប្រហែលជាម៉ោងប្រាំបីកន្លះព្រឹក ខ្ញុំបានឃើញកងទ័ពរំដោះជាតិស្លៀកពាក់ឯកសណ្ឋានខ្មៅមានកាំភ្លើងគ្រប់ដៃ និងមានទាំងរថក្រោះផងធ្វើដំណើរដោយស្មារតីប្រុងប្រយ័ត្នឆ្ពោះមកកាន់ទីប្រជុំជនក្រុងភ្នំពេញស្រែកពាក្យស្លោកថា «ជយោ! ជយោ! ជយោ! កងទ័ពរំដោះជាតិកម្ពុជា ។ បរាជ័យពួកចក្រពត្តិអាមេរិក និងបរិវារ» ។ ប៉ុន្តែសភាពការណ៍មិនអាចនឹកស្មានដល់ ដោយមិនបានកន្លះម៉ោងផង យោធាខ្មែរក្រហមដែលកំពុងដើរដង្ហែក្បួនបានបំបែកជួរគ្នា ដៃកាន់កាំភ្លើងស្ថិតក្នុងទឹកមុខមាំប្រកាសតាមមីក្រូថា «អង្គការបដិវត្តន៍មានទិសដៅបោសសម្អាតពួកចក្រពត្តិអាមេរិក និងបរិវារ ។ សូមមិត្ត ពុកម៉ែ បងប្អូននៅក្នុងផ្ទះកុំទៅណា ប្រយ័ត្នប្រទ្បុំពួក លន់ នល់ និងអាយ៉ងអាមេរិកាំង» ។ ពេលនោះ ខ្ញុំក្រឡេកទៅម្ខាងផ្លូវឃើញទាហាន លន់ នល់ ប្រហែលជាដប់នាក់ត្រូវបានចងជាខ្សែបណ្តើរយកទៅបាត់ ។ ចំណែកតាមដងផ្លូវឃើញមានសភាពជ្រួលច្របល់ជាខ្លាំង ដោយមានស្នូរកាំភ្លើងបាញ់ផ្ទួងផ្ទាំង ហើយក៏មានសាកសពស្ថិតនៅក្នុងថ្លុកឈាមដែរ ។

ដោយមានអារម្មណ៍ភ័យខ្លាចខ្លាំងពេក ក៏បានរត់ចូលផ្ទះខ្ញុំ (ឃីហោអារុណរះដួសដុលម៉ូតូ) ស្ថិតតាមដងផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់ខាងកើតសាលាសន្ទរម៉ុកប្រហែល៣០០ម៉ែត្រ ជិតហាងនំបុ័ងម៉ុងឌីយ៉ា ។ គ្រួសាររបស់ខ្ញុំទាំងអស់គ្នាមានចំនួន១២នាក់ ។ ខ្ញុំមានអាយុ១៨ឆ្នាំ ជាសិស្សរៀននៅអនុវិទ្យាល័យឥន្ទ្រទេវីថ្នាក់ទី៥ ។ ខ្ញុំរៀនពូកែណាស់ គឺជាប់លេខ២ ឬលេខ៣ជារៀងរាល់ឆ្នាំ ។ ឪពុកម្តាយខ្ញុំមានកូន៨នាក់ ដោយខ្ញុំជាកូនទីបីក្នុងចំណោមបងប្អូនប្រាំនាក់ (ប្រុស៥ ស្រី៣) ។ កុងម៉ារបស់ខ្ញុំគឺជាចិនឆៅរត់ពីស្រុកចិនមកស្រុកខ្មែរដើម្បីគេចពីពួកចិនកុម្មុយនីស្ត ។ គាត់បានរៀបរាប់ឲ្យខ្ញុំដឹងថា ប្រទេសបដិវត្តន៍កុម្មុយនីស្តមិនចាយលុយទេ គេធ្វើការរួម បរិភោគរួម និងដេករួម ហើយអ្នកទាំងនេះ

សម្រាប់មនុស្សសាហាវខ្លាំងណាស់ ។

ដូចជាសម្តីរបស់គាត់មែន ខ្ញុំបានឃើញរថយន្តហ្ស៊ីបរបស់ទាហាន លន់ លន់ ដោយលើរថយន្តនោះមានឧឃោសនស័ព្ទបំពងសំឡេងមួយ និងទាហានខ្មែរក្រហមបួននាក់ម្នាក់ស្លៀកពាក់ឈុតខ្មៅមានក្រមាក្រហមបង់កទំនងជាមេបញ្ជាការបាននិយាយប្រកាសតាមមីក្រូថា ៖ «រដ្ឋាភិបាល ឡុង ប៉ុន់រ៉េត ដួលរលំហើយ ។ ចក្រពត្តិអាមេរិកមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ។ សូមបងប្អូន ពុក ម៉ែ ចេញពីផ្ទះជាបណ្តោះអាសន្នសិន» ។ បន្ទាប់មកយោធាក្មេងៗដែលកំពុងដើរចុះឡើងនោះចាប់ផ្តើមដេញអ្នកទីក្រុងចេញពីក្នុងផ្ទះ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចជាខ្លាំង ព្រោះខ្ញុំធ្លាប់ឃើញគ្រាប់ផ្លោងចូលចំកណ្តាលទ្រូងផ្លូវខាងកើតឈានខាងត្បូងផ្សារថ្មី ធ្វើឲ្យមនុស្សស្លាប់និងរបួសច្រើនណាស់ ។ ដូច្នេះ អ្នកលក់ដូរស្អប់ទាហាន លន់ លន់ ខ្លាំងណាស់ ព្រោះអ្នកទាំងនេះតែងតែទៅទិញទំនិញនិងបរិភោគអាហាររួចនិយាយថា អត់មានលុយទេ សូមបញ្ចាំគ្រាប់បែកទុកសិន ពេលណាមានលុយ ឬចាំបើកលុយនឹងមកលួសវិញ ។ គ្រប់គ្នាស្អប់និងខ្លាចទាហាន លន់ នល់ ណាស់ ដោយទាំងក្មេងទាំងចាស់បន់ឲ្យតែប្រទេសជាតិចាប់បានរំដោះ ព្រោះយោធាខ្មែរក្រហមមានសីលធម៌ល្អ ។ តែនៅពេលនេះផ្ទុយស្រឡះ តែប៉ុន្មានម៉ោងក្រោយសោះ ទីក្រុងភ្នំពេញក្លាយជាថ្នកឈាមទៅវិញ ។

ឪពុកម្តាយខ្ញុំបានរៀបចំរបស់របរមួយចំនួនដូចជា ខោអាវ លុយមួយចំនួន អង្ករ និង ម្ហូប ព្រមទាំងទឹកមួយកានដាក់លើរទេះត្រៀមទុកជាស្រេច ព្រោះគាត់ដឹងថា ខ្មែរក្រហមមិនឲ្យវិលត្រឡប់មកផ្ទះវិញទេ ។ នៅម៉ោង១រសៀលថ្ងៃទី១៧ ខែមេសា យោធាខ្មែរក្រហមក៏ចាប់ផ្តើមដេញអ្នកទីក្រុងភ្នំពេញនៅខាងជើងថ្នល់ចេញពីលំនៅឋាន ដោយមានកាយវិការប្រទេងប្រទាង ហើយនិយាយខ្លាំងៗថា «ចេញឲ្យឆាប់» ។ ពេលនោះ ប្រជាជនខ្លះមានតែក្រមាមួយស្លៀកជាប់ចង្កេះ ខ្លះស្ពាយតែសាក់កាដូមួយ ខ្លះទៀតមានអីវ៉ាន់ច្រើនធ្វើដំណើរដោយទឹកមុខស្រពាប់ស្រពោន ។ ចំណែកអ្នកដែលនិយាយតវ៉ាមិនព្រមចេញត្រូវបានបាញ់សម្លាប់ក្នុងផ្ទះតែម្តង ។

ចំណែកផ្ទះដែលខ្ញុំរស់នៅត្រូវចាប់ផ្តើមចាកចេញនៅម៉ោងបីរសៀល ។ ពេលនោះ មានយោធាខ្មែរក្រហមម្នាក់អាយុជាង ២០ឆ្នាំបានមកគោះទ្វារផ្ទះខ្ញុំ ហើយស្រែកថា ដល់ម៉ោងចេញហើយ ។ ម្តាយខ្ញុំឲ្យខ្ញុំបើកទ្វារឲ្យ រួចហុចទឹកក្រូចឲ្យយោធានេះមួយដប ។ យោធានោះក៏ផឹកបណ្តើរនិយាយបណ្តើរប្រាប់ម្តាយខ្ញុំថា «សូមពុកម៉ែចាកចេញទៅ នេះជាទិសដៅអង្គការ» ។ បន្ទាប់មកម្តាយខ្ញុំសួរថា ទៅប៉ុន្មានថ្ងៃលោកក្មួយ? គាត់ឆ្លើយថា មិនដឹងទេ ប្រហែលជាយូរ ហើយយកស្បៀងអាហារផង ។ គ្រួសាររបស់ខ្ញុំសំណាងណាស់ដោយយោធាខ្មែរក្រហមម្នាក់នោះទុកពេលឲ្យគ្រួសារខ្ញុំចេញតាមសម្រួល ។

គ្រួសារខ្ញុំបានចាប់ផ្តើមបណ្តើរកង់ម៉ូតូ និងរទេះតាមផ្លូវកម្ពុជាក្រោមឆ្ពោះទៅទិសខាងលិចសំដៅទៅរូបសំណាកគោពីរ ។ នៅតាមផ្លូវចេញពីផ្ទះមានប្រជាពលរដ្ឋធ្វើដំណើរស្របទិសគ្នាយ៉ាងច្រើនកុះករស្ទើរតែដើរពុំរួច មានទាំងចាស់ជរា ស្ត្រីពោះធំ អ្នកជំងឺកំពុងព្យួរសេរ៉ូម លោកសង្ឃ ដូនជី និងអាចារ្យ ។ គ្រប់គ្នាសុទ្ធតែមានក្នុងទឹកមុខក្រៀមក្រំអស់ក្តីសង្ឃឹម ។ គ្រួសារខ្ញុំបានដើរដល់រូបសំណាកគោពីរឆ្លងចូលមហាវិថីសហភាពខ្មែរសូវៀតទៅដល់កែងផ្លូវចូល (សព្វថ្ងៃនៅត្រឡោកបែក) ស្រាប់តែមានយោធាខ្មែរក្រហម៤-៥នាក់ ក្នុងនោះមានម្នាក់ស្ទុះមករកខ្ញុំ ហើយសម្លឹងកង់របស់ខ្ញុំ រួចនិយាយថា «មិត្តឲ្យខ្ញុំស្នើសុំកង់របស់មិត្តបានទេ?» ឃើញដូច្នេះ ម៉ែខ្ញុំដើរមកជិតខ្ញុំ រួចនិយាយទៅកាន់យោធានោះថា សូមលោកក្មួយយកលុយទៅ ។ យោធានោះក៏ប្រាប់ថា «អរគុណ! ម៉ែឯងកុំទុកលុយទៀត ព្រោះគេឈប់ចាយហើយ ចាប់ពីថ្ងៃនេះតទៅ មានគេលក់អ្វីទិញឲ្យអស់ទៅ» ។ ខ្ញុំក៏បន្តដំណើរទៅមុខទៀតរហូតដល់ផ្លូវក្រួសក្រហមផ្សារដីហុយក៏បត់ចូលសំដៅទៅភ្នំពេញថ្មីដោយនៅទីនោះមានមនុស្សតិចណាស់ធ្វើដំណើរទៅ ។ គ្រួសារខ្ញុំបានមកដល់ដីចម្ការល្ហុងរបស់ប៉ាខ្ញុំ និងដីពីរឡូត៍ជាប់គ្នាមានផ្ទះក្បឿងមួយខ្នងដែលគាត់ឲ្យអ្នករស់នៅស្រុកនេះជួយមើលថែរក្សា ។ ដោយសារតែតាមផ្លូវចូលភ្នំពេញថ្មីមានតូបលក់ទំនិញផ្សេងៗដូចជនបទដែរ ឪពុកម្តាយខ្ញុំគិតថា ប្រហែលជាខ្មែរក្រហមដេញតែអ្នករស់នៅទីក្រុងភ្នំពេញប៉ុណ្ណោះទេ ដូច្នេះគាត់ក៏យកលុយទៅឲ្យពូម្នាក់ដែលជាអ្នកចាំផ្ទះ និងដាំចម្ការដើម្បីទិញម្ហូប ។ យប់នោះគ្រួសារខ្ញុំស្នាក់នៅស្រុកភ្នំពេញថ្មីទាំងព្រួយបារម្ភនិងភ័យ

ខ្លាច ។ ក្នុងរយៈពេលបីថ្ងៃនេះ ការលក់ដូរគឺនៅដដែល គ្រាន់តែទំនិញអ្វីៗសព្វយ៉ាងឡើងថ្លៃមួយគុណនឹងដប់ ។ ដូច្នេះ ខ្ញុំគិតថា ប្រហែលជាកូនទាហានខ្មែរក្រហមដែលចង់បានកងរបស់ខ្ញុំនោះ និយាយភរពីរឿងមិនចាយលុយ ។

## ដំណើរតាមផ្លូវជាតិលេខ៥

ព្រឹកព្រលឹមស្រាងៗថ្ងៃទី១៩ ខែមេសា មានយោធាខ្មែរក្រហមមួយក្រុមផ្សេងទៀតមកដល់តំបន់ភ្នំពេញថ្មី ហើយចាប់ផ្ដើមបណ្ដេញអ្នកស្រុកភ្នំពេញថ្មី និងអ្នកមកពីភ្នំពេញឲ្យចេញជាបន្ទាន់ ដោយក្នុងនោះក៏មានគ្រួសារខ្ញុំផងដែរឲ្យចេញដំណើរតាមទំនប់កប់ស្រូវមកឡើងព្រែកព្នៅផ្លូវជាតិលេខ៥ សំដៅទៅបាត់ដំបង ។ ពេលនោះ មនុស្សណែនពេញផ្លូវ អ្នកមានជំងឺ ឬកម្លាំងខ្សោយ ហើយដួលត្រូវគេជាន់ថែមរហូតស្លាប់ ។ ដើររហូតដល់ថ្ងៃត្រង់ ទើបយោធាខ្មែរក្រហមឲ្យសម្រាកហូបបាយ ។ ហូបបាយបានមួយសន្ទុះ ខ្មែរក្រហមក៏មកដេញឲ្យធ្វើដំណើរទៅមុខទៀតរហូតដល់ព្រលប់ៗទើបរកកន្លែងឈប់សម្រាក ។ គ្រួសារខ្ញុំបានមកដល់វត្តក្រួសក៏ដាក់ឆ្នាំងដាំបាយហូប រួចនាំគ្នាដេកនៅក្បៀនរបងវត្ត ។ លុះព្រឹកឡើង ម៉ែខ្ញុំឲ្យបងប្រុសខ្ញុំ និងខ្ញុំទៅរកទឹកមកទុកប្រើ ។ ដោយសារតែខ្ញុំជាក្មេងប្រុសពីស ពេលឃើញព្រៃក្បែរវត្តមានផ្សែងហុយៗ និងមានក្លិនឈ្ងៀម ខ្ញុំនិងបងប្រុសខ្ញុំក៏រត់ទៅមើល ពេលនោះស្រាប់តែឃើញខ្មោចទាហាន លន់ នល់ ត្រូវគេដុតឆេះឡើងរួចក្រញ៉ង់ ខ្លះឆេះអស់សល់គំនរដេះ ។ នៅទីនោះមើលទៅដូចជាទីតាំងប្រយុទ្ធរវាងទាហានលន់ នល់ និងយោធាខ្មែរក្រហម ព្រោះមានលេណដ្ឋាន និងសម្បកគ្រាប់កាំភ្លើងធំតូចភ្លឺចាំងដូចមាស បន្សល់នៅលើដី តែមិនឃើញខ្មែរក្រហមយាមទេ ។ ទិដ្ឋភាពនេះមើលទៅព្រឺព្រួចណាស់ ដូច្នេះខ្ញុំក៏ប្រញាប់ត្រឡប់មកវិញ រួចនិយាយប្រាប់ម្ដាយខ្ញុំ ។ ព្រលឹមឡើង គ្រួសារខ្ញុំបាននាំគ្នាបន្តដំណើរទៅមុខទៀត ក៏ឃើញខ្មោចស្ត្រីពោះធំដេកស្លាប់ និងមួយកន្លែងទៀតមានក្រាលសំពត់កៅស៊ូពណ៌ទាហាន ដោយលើសំពត់កៅស៊ូមានខ្មោចស្ត្រីម្នាក់និងទារកទើបកើតដេកស្លាប់ប្រឡោះដើងម្ដាយទាំងពីរនាក់ ។

តាមដាយផ្លូវជាតិលេខ៥នេះ ខ្ញុំឃើញរថយន្ត និងម៉ូតូគ្រប់ធុនចតចោលជាហូរហែ ។ ពេលនោះ ឪពុកខ្ញុំឲ្យបងប្រុសខ្ញុំទាំងពីរនាក់ទុកម៉ូតូ និងបោះរបស់មិនចាំបាច់មួយចំនួនចោល ទុកតែរទេះពីរដើម្បីធ្វើដំណើរប៉ុណ្ណោះ ។ សំណាងណាស់ គ្រួសារខ្ញុំដឹងរឿងគេឈប់ចាយលុយ រួចបានត្រៀមស្បៀងអាហារបម្រុងទុកខ្លះសម្រាប់ហូបបានយ៉ាងហោចណាស់មួយសប្ដាហ៍ ។ ពេលព្រឹកម៉ោងប្រាំពីរកន្លះព្រឹក គ្រួសារខ្ញុំបានមកដល់កំពង់ចម្លងព្រែកក្ដាម ។ ពេលហូបបាយរួច រៀបចេញដំណើរ ខ្ញុំក្រឡេកមើលទៅទន្លេឃើញរថយន្តថ្មីមួយគ្រឿងមានមនុស្សបួននាក់ជិះក្នុងរថយន្ត គឺប្ដីប្រពន្ធនិងកូនតូចៗប្រុសមួយស្រីមួយបើកចុះទឹកទន្លេលិចសន្សឹមៗ រួចក៏បាត់ស្រមោលរថយន្តនោះទៅ ។ ម្នាក់ៗសម្លឹងមើលយ៉ាងអាណោចអធ័ម រួចគិតថា ពីរនាក់ប្ដីប្រពន្ធនោះអស់សង្ឃឹម ទើបស្លាប់ឲ្យហើយមិនបាច់វេទនា ។

ឃើញដូច្នេះ ឪពុកខ្ញុំនិយាយថា យើងនៅមានជីវិត យើងត្រូវមានសង្ឃឹម រួចក្រុមគ្រួសារខ្ញុំក៏បន្តដំណើរទៅមុខទៀត ។ មកដល់ភូមិមួយដែលគ្មានអ្នកភូមិរស់នៅ ស្រាប់តែឃើញយោធាខ្មែរក្រហម៤-៥នាក់កំពុងឈរជិតតុចាស់មួយមានដាក់មីក្រូពីលើ និងយោធាខ្មែរក្រហមម្នាក់ទៀតកំពុងអំពាវនាវរកមន្ត្រីរដ្ឋការ ប៉ូលិស និងទាហាន លន់ នល់ ឲ្យវិលត្រឡប់ចូលក្រុងភ្នំពេញវិញ ។ នៅចម្ងាយប្រហែល៣០ម៉ែត្រពីទីនេះ ខ្ញុំឃើញមានផ្ទះក្បឿងធំមួយក្រោមផ្ទះមានប្រុសៗវ័យជាង៣០ឆ្នាំជាង១០នាក់ ខ្លះឈរខ្លះអង្គុយដោយទឹកមុខញញឹមជជែកគ្នាលែងរង់ចាំត្រឡប់ទៅធ្វើការនៅក្រុងភ្នំពេញវិញ ។ ខ្មែរក្រហមឆែកឆេររកញុប់អីវ៉ាន់គ្រប់ៗគ្នា និងសួររកលិខិតស្នាមផ្សេងៗ ឬអាវុធជាតិផ្ទុះ រួចឲ្យរទេះរបស់គ្រួសារខ្ញុំឈប់ ហើយមកមើលអីវ៉ាន់ក្នុងរទេះនោះ ។ ខណៈពេលដែលកំពុងតែឆែក ស្រាប់តែមានយោធាខ្មែរក្រហមម្នាក់មានរូបរាងខ្ពស់សម្បុរសចុះមកពីលើផ្ទះធំនោះដើរសំដៅមករកឪពុករបស់ខ្ញុំ រួចនិយាយថា «អ៊ំស្គាល់ខ្ញុំទេ?» ឪពុកខ្ញុំឆ្លើយថា ចាំមិនបានទេ ។ គាត់ប្រាប់ថា «ខ្ញុំធ្លាប់នៅជាមួយអ៊ំកាលពីពីរឆ្នាំមុននោះ កាលនោះអ៊ំធ្វើទឹកកក និងការ៉េម ហើយខ្ញុំស្នាក់នៅជាមួយអ៊ំ ។ ខ្ញុំជួយធ្វើការងារឲ្យអ៊ំ ហើយអ៊ំជួយឧបត្ថម្ភលុយរៀនសូត្រឲ្យខ្ញុំទៀត» ។ ឪពុកខ្ញុំនិយាយថា «អូ! ចាំបានហើយឥឡូវនេះធ្វើមេគេផង!» ។ ខ្ញុំមិនឮឪពុកខ្ញុំហៅឈ្មោះគាត់ទេ មិនដឹងជាឪពុកខ្ញុំភ្លេច ឬមិនហ៊ានហៅ ព្រោះគាត់ក្លាយជាមេខ្មែរក្រហម

មើលទៅមានអំណាចខ្លាំងណាស់ ។ គាត់បាននិយាយមកកាន់ឪពុកខ្ញុំថា «កុំអាលទៅអីអ៊ំ នៅហូបបាយថ្ងៃត្រង់ជាមួយខ្ញុំហើយ ។ ខ្ញុំនឹកអ៊ំឯងណាស់ ចាំស្អែកចាំទៅយកអីវ៉ាន់ចូលក្នុងមក» ។ បន្ទាប់មក បងប្រុសខ្ញុំទាំងពីរនាក់នាំគ្នារុញរទេះចូលសំដៅផ្ទះមួយតូចនៅក្រោយផ្ទះធំដោយមានគាត់នាំមុខ ។ ក្រុមគ្រួសារខ្ញុំឈប់សម្រាកគ្រប់ៗគ្នាជាមួយទឹកមុខត្រេកអរជាខ្លាំង ជាពិសេសយាយតារបស់ខ្ញុំ ។ មួយម៉ោងក្រោយមក កូនចៅរបស់គាត់បានយកត្រីរស់អាំងក្តៅៗចំនួនពីរប៉ុនកំភួនជើង និងទឹកត្រីផ្អែមជងមកក៏មកដល់ល្មម ហើយរៀបបាយហូបជាមួយឪពុកខ្ញុំពីរនាក់ ចំណែកពួកខ្ញុំហូបជិតគាត់ដែរ ។ ហូបបណ្តើរក៏និយាយបណ្តើរពីប្រវត្តិរបស់គាត់ឲ្យពួកខ្ញុំស្តាប់ថា គាត់មកភ្នំពេញហើយជួយធ្វើទឹកកកឲ្យឪពុកខ្ញុំ ។ គាត់ស្នាក់នៅ រៀនសូត្រ និងជួយមើលខុសត្រូវការងារឲ្យឪពុកខ្ញុំ ។ គាត់ជាជនបដិវត្តន៍ មានខ្សែរយៈយូរមកហើយ ។ ក្រោយពីម៉ាស៊ីនទឹកកកផ្ទះត្រូវរបួសឪពុកខ្ញុំ ហើយគាត់ក៏ឈប់ធ្វើទឹកកកព្រោះឪពុកខ្ញុំលក់កន្លែងនោះឲ្យទៅអ្នកផ្សេងវិញ ។ ដល់ពេលគាត់រៀនចប់ល្មម ហើយវិលទៅតំបន់រំដោះវិញក៏បានចូលរួមក្នុងចលនារំដោះជាតិកម្ពុជាធ្វើជាកងទ័ពរហូតសព្វថ្ងៃនេះ ។ គាត់ជាប្រធានកងពល ប៉ុន្តែមិនបានប្រាប់ឈ្មោះស្រុកកំណើត និងកងពលអ្វីទេ ។ ឥឡូវនេះប្រទេសជាតិបានរំដោះទាំងស្រុង អង្គការថ្នាក់លើបានប្រគល់ភារកិច្ចឲ្យគាត់ចាំទទួលមន្ត្រីរដ្ឋការ ប៉ូលិសនិងអ្នកបច្ចេកទេសរបស់ លន់ នល់ ឲ្យចូលក្រុងភ្នំពេញវិញ ។ គាត់បន្តទៀតថា នេះជារឿងសម្ងាត់របស់អង្គការបដិវត្តន៍ ដោគវាសនារបស់អ្នកទាំងនោះមិនដឹងជាយ៉ាងដូចម្តេចដែរទេ ព្រោះអង្គការមានវិន័យតឹងរ៉ឹង គាត់មិនអាចជួយគ្រួសារខ្ញុំបានទេ ។ ពេលគ្រួសារខ្ញុំធ្វើដំណើរទៅមុខទៀតត្រូវតែប្រុងប្រយ័ត្ន កុំនិយាយត្រង់ៗពេក ហើយត្រូវចេះលាក់ប្រវត្តិរូបពិត ព្រោះអង្គការចម្រាញ់យកវណ្ណៈកសិករតែមួយគត់ ។ លើសពីនេះទៅទៀតត្រូវចេះដាំដើមគរ (ធ្វើគធ្វើថ្លង់) កុំនិយាយរឿងអ្នកផ្សេងប្រាប់អង្គការ ព្រមទាំងត្រូវហាត់ពត់លត់ដំខ្លួន ខស្បាហ៍ព្យាយាមពេលអង្គការប្រើធ្វើការ កុំប្រឆាំងទើបអាចរស់បាន ។ កង់ប្រវត្តិសាស្ត្រកំពុងវិលទៅមុខ មិនអាចរាំងស្ទះបានទេ ។ ចំណែកគាត់ក៏មិនដឹងពីជោគវាសនារបស់ខ្លួនគាត់ផងដែរ ។ ខ្ញុំនៅចំណាំគាត់បានដែរ ព្រោះខ្ញុំខស្បាហ៍ទៅរោងចក្រធ្វើទឹកកកនៅល្ងាចថ្ងៃអាទិត្យ ។ ក្រោយពីលក់រោងធ្វើទឹកកកមកទិញផ្ទះថ្មនៅផ្លូវកម្ពុជាក្រោម បែកគ្នាជាងមួយឆ្នាំសោះ គាត់ក្លាយជាប្រធានកងពលទៅហើយ ។

ក្រោយពីនិយាយផ្តាំផ្ញើចប់ គាត់រៀបចេញទៅធ្វើការងារក៏បានប្រាប់ថា ភូមិនេះគេហៅភូមិធំដែលនៅខាងក្រោយភូមិនេះមានបឹងមួយគេហៅបឹងពោងពាយ ដោយគាត់ប្រាប់ឲ្យគ្រួសារខ្ញុំប្រើទឹកនេះចុះ ហើយគ្មាននរណាហ៊ានប៉ះពាល់គ្រួសារខ្ញុំទេ កុំខ្លាចកូនចៅគាត់អី ។ ដោយសារខានបានងូតទឹករយៈពេលបីថ្ងៃតាំងពីចេញទីក្រុងភ្នំពេញថ្មីមក ឥឡូវនេះយើងបានប្តូរវេនគ្នាទៅងូតទឹកនិងបោកខោអាវ ប៉ុន្តែមិនហ៊ានដើរចោលឥវ៉ាន់រទេះនំទេ ព្រោះមានមាសមួយចំនួន ។ លុះល្ងាចម៉ោង៥ កូនចៅរបស់គាត់បានលើកបាយមួយឆ្នាំងធំនិងសាច់ជ្រូកខមួយឆ្នាំងធំល្មមយកមកឲ្យគ្រួសារខ្ញុំដោយសម្តីទន់ភ្លន់ថា មិត្តបងល្ងាចនេះគាត់រវល់ ។ គាត់ឲ្យគ្រួសារសមមិត្តហូបបាយនេះចុះ និងសល់ប៉ុន្មានយកទាំងឆ្នាំងចាននេះទុកប្រើចុះ ។ ល្ងាចនេះគ្រួសារខ្ញុំសប្បាយចិត្តណាស់ រួចនាំគ្នាហូប និងសម្រាកយ៉ាងកក់ក្តៅ លុះព្រឹកឡើងគាត់មកជូនដំណើរគ្រួសារខ្ញុំទៀត ។ ពេលដើរមកដល់ស្រុកខដុង្គ យើងឃើញមានមនុស្សយកបាយមកជារឿយៗដោយប្រាប់ថា ខាងមុខនេះមានអង្គការចែកបាយឲ្យ ។ ម៉ែខ្ញុំទទួលបានបាយមួយកូនឆ្នាំង និងត្រីងៀតមួយកន្ទុយ ។ ហូបបាយរួច យើងនាំគ្នាដើរផ្លូវដីមួយល្ងាចទៀត ទើបទៅដល់ភូមិចាស់មួយដែលគ្មានអ្នកភូមិរស់នៅមានតែដើមសសរផ្ទះ និងគំនរក្បឿង ព្រមទាំងព្រៃដុះជុំវិញ ។ ពេលឃើញអ្នកជម្លៀសឈប់ គ្រួសារខ្ញុំក៏ឈប់ដូចគេដែរ រួចយោធាខ្មែរក្រហម ៤-៥នាក់និយាយថា ដល់គោលដៅ អង្គការឲ្យអ្នកទាំងអស់គ្នាតាំងមូលដ្ឋាននៅទីនេះ រួចហៅឲ្យទៅយករបបអង្ករចំនួនបីថ្ងៃ និងប្រាប់ទីតាំងអណ្តូង ។ ល្ងាចនេះម្នាក់ៗរៀបចំកន្លែងសម្រាប់សម្រាក និងដាំបាយហូប ។

លុះព្រឹកឡើង យោធាខ្មែរក្រហមស្លៀកខោអាវខ្មៅ៤-៥នាក់មានទាំងខ្សែ ពូថៅ ដែកគោល រណា និងកាំបិតផ្គាក់ និយាយប្រាប់ថា ពូមីងមកពីភ្នំពេញមកទទួលរបបដីលំនៅដ្ឋានដែលក្នុងមួយគ្រួសារៗទទួលបានដី៣០គុណ នឹង១០០ម៉ែត្រជាកម្មសិទ្ធិ

រួចប្រាប់ឲ្យទៅរុះរើឈើនៅតាមទីវត្ត ឬសាលារៀនមកធ្វើផ្ទះដោយខ្លួនឯង ដើម្បីបង្កើត «ភូមិអ្នកថ្មី ឬអ្នក១៧មេសា»។ បន្ទាប់មកទុកពូថៅ កាំបិត រណា និងដែកគោលឲ្យប្រើប្រាស់ រួចកត់ឈ្មោះ និងរាប់ចំនួនមនុស្សក្នុងគ្រួសារ។ ដោយមនុស្សមានច្រើននិងសម្ភារៈមានតិច ឪពុកខ្ញុំយកបានដែកគាស់មួយ អ្នកខ្លះបានពូថៅ ឬរណា រួចនាំគ្នាដើររកឈើនៅតាមវត្ត សាលារៀន ឬផ្ទះ ធំៗមកធ្វើខ្ទមរៀងៗខ្លួន។

## ភូមិពងទឹករយៈពេលជាងពីរខែ

ក្នុងថ្ងៃដដែលនោះ ឪពុកខ្ញុំបាននាំខ្ញុំទាំងអស់មានគ្នា៩នាក់ និងរទេះពីរទៅរកឈើមកធ្វើផ្ទះ។ យើងមិនហ៊ាននៅដំអក់យូរទេ ព្រោះខ្លាចទៅក្រោយគេរកឈើមិនបាន។ ឪពុកខ្ញុំដើរគាស់ឈើតាមផ្ទះចាស់បាក់បែកបានឈើល្មមពីររទេះ បានត្បាល់កិនម្សៅមួយ និងពាងមួយ ចំណែកខ្ញុំរើសដែកគោល និងរបស់ផ្សេងៗដែលអាចប្រើបាន។ គ្រួសារខ្ញុំធ្វើបានផ្ទះខ្ទមជាប់ដីគ្មានជញ្ជាំង ដំបូលប្រក់កៅស៊ូ ចំណែកគ្រួសារគេផ្សេងៗក៏ដូចធ្វើតាមលទ្ធភាពអ្វីដែលនៅសេសសល់។

ម្តាយខ្ញុំជាកូនខ្មែរអ្នកចម្ការ ចេះគ្រប់កិច្ចការ ធ្លាប់ធ្វើម្ហូបឲ្យបារាំង ធ្វើនំចិន និងនំខ្មែរ។ គាត់បានយកចិញ្ចៀនមួយវង់ទៅដូរបានស្ករ និងដូងទុំពីអ្នកមូលដ្ឋាន រួចក៏ធ្វើនំអាកោត្នោតឲ្យយើងទាំងអស់គ្នាហូប។ ថ្ងៃបន្តបន្ទាប់មកទៀត គាត់ធ្វើនំអន្សមចេក អន្សមជ្រូកដូរបានទាំងស្លឹកប្រក់ផ្ទះ និងគ្រាប់ពូជដំណាំផ្សេងៗ។ ប្រហែលកន្លះខែប៉ុណ្ណោះ ដីផ្ទះខ្ញុំក៏ក្លាយជាចម្ការមានទាំងចិញ្ចឹមមាន់ និងទាទៀត។ ប៉ុន្តែគួរឲ្យសោកស្តាយ យាយខ្ញុំចាស់ជរា បានឈឺទ្រុឌទ្រោមតាំងពីមកភ្នំពេញក៏មានជំងឺស្លាប់នៅទីនោះ។

មុនពេលស្លាប់ គាត់និយាយថា គាត់នឹងមកថែរក្សាកូនចៅទាំងអស់គ្នាឲ្យបានសេចក្តីសុខជាពិសេសរូបខ្ញុំក្នុងចំណោមចៅៗទាំងអស់ (គាត់មានកូន៦នាក់ ចៅ៣០-៤០នាក់) ព្រោះពេលដែលខ្ញុំកើត គ្រួសារខ្ញុំបានក្លាយទៅជាអ្នកមាន។

បន្ទាប់មក អង្គការចាប់ផ្តើមចាត់តាំងឲ្យយុវជនកាប់ដីស្រែវ័យចំណាស់រើសស្មៅ ក្មេងជំទង់ធ្វើជីធម្មជាតិ និងលោកសង្ឃក៏កាប់ដីស្រែដែរ។ ខ្មែរក្រហមបានកោះប្រជុំជីវភាពការងារអ្នក១៧មេសាថា មិនស្មោះត្រង់នឹងអង្គការ មិនគោរពវិន័យអង្គការ មិនព្រមជម្រុះកម្មសិទ្ធិផ្ទាល់ខ្លួន នៅធ្វើវណ្ណៈនាយទុន ជិះជាន់កម្លាំងពលកម្មអ្នកម្ចាស់ស្រុកជាពិសេសខ្មាំងនៅគ្រប់គ្រងសតិអារម្មណ៍បាន។ ក្រោយពីប្រជុំហើយ គ្រួសារណាមិនទៅធ្វើការត្រូវកាត់បន្ថយរបបអង្ករ និងចាត់ទុកថាជាមនុស្សរឹងរូសចង់ប្រឆាំងអង្គការ ដូច្នេះត្រូវតែហៅទៅប្រជុំទិតៀន។ រយៈពេលជាងពីរខែកន្លះនេះ អ្នក១៧មេសាអាចសម្របខ្លួននឹងការរស់នៅជាលក្ខណៈសមូហភាព គឺទទួលរបបអង្ករ ឬពោតពីអង្គការ។

## ការជម្លៀសទៅធ្វើស្រែនៅទិសពាយព្យ

ល្ងាចមួយព្រលប់ទៅហើយ អ្នកមូលដ្ឋានបានដើរកោះហៅអ្នក១៧មេសាទាំងអស់ឲ្យទៅប្រជុំជាបន្ទាន់ ដោយមិនអាចខានបានទេ។ នៅទីនោះអ្នកមូលដ្ឋានអង្គុយនៅទីទួល អ្នក១៧មេសាអង្គុយក្នុងវាលស្រែក្រោយភូមិស្តាប់ការប្រជុំថា ស្អែកនេះអង្គការឲ្យសមមិត្តគ្រប់គ្នាទៅធ្វើស្រែនៅភាគពាយព្យ សមមិត្តដែលមានឈ្មោះគឺទៅទាំងគ្រួសារមិនចាំបាច់យករបស់របរច្រើនទៅជាមួយទេ ព្រោះអង្គការមានផ្ទះ សម្លៀកបំពាក់ ស្បៀងអាហារជូនសមមិត្តហើយ ដូច្នេះសមមិត្តត្រូវគោរពការចាត់តាំងរបស់អង្គការថ្នាក់លើជាដាច់ខាត។

ក្នុងយប់នោះខ្ញុំដេកមិនលក់ទេ គឺនឹកស្តាយដំណាំដែលបងប្អូន និងឪពុកម្តាយខ្ញុំខំប្រឹងដាំ ជាពិសេសដំឡូងជ្វាជិតដល់ថ្ងៃគាស់និងផ្ទះទើបមានស្លឹកយកប្រក់ថ្មីៗដែលម៉ែខ្ញុំធ្វើនំយកទៅដូរ។ លុះព្រឹកព្រលឹមស្រាងៗ កងទ័ពខ្មែរក្រហមជាច្រើននាក់បានមកឈរចាំនៅមុខផ្ទះរួចជាស្រេចនិងមានរទេះគោប្រហែល១០រង់ចាំដឹកពួកយើង។ យើងបានឮអ្នកមូលដ្ឋាននិយាយថា ប្រញាប់ឡើងដល់ពេលចេញដំណើរហើយ ដោយក្នុងរទេះគោមួយដាក់ចាស់និងក្មេង៣-៥គ្រួសារបញ្ចូលគ្នា។ ចេញទៅដល់ផ្លូវធំដីក្រហមខ្ញុំឃើញរទេះគោដឹកជាច្រើនដឹកប្រជាជនឆ្ពោះទៅខាងកើតដែរ។ ពេលទៅដល់មាត់ទន្លេម៉ោងប្រហែលជា៩ មានរថយន្តធំមួយគ្រឿងមាននារីខ្មែរក្រហមកំពុងឈរហុចបាយស្មុគ និងត្រីងៀតឲ្យទៅអ្នក១៧មេសាដែលត្រូវធ្វើដំណើរចុះទូក។ គ្រួសារខ្ញុំទទួលបានបាយពីរស្មុគ (កន្លែងដែលខ្មែរក្រហមចែកបាយ និងឲ្យចុះពីលើរទេះដើម្បីឈរជុំមួយគ្រួសារៗ)។ ក្រឡេកទៅមាត់ទន្លេខ្ញុំឃើញទូកឈើធំៗបីគ្រឿង មួយគ្រឿងខាងមុខមានមនុស្សជិះ

ពេញ ដូច្នេះគ្រួសារខ្ញុំក៏ចុះទូកទីពីរ ឆ្ពោះទៅខាងកើត ។

នៅលើទូក ម្តាយខ្ញុំមិនឲ្យខ្ញុំហូបបាយថ្ងៃត្រង់ទេ ប៉ុន្តែគាត់បានចែកនំអន្សមចេកមួយម្នាក់ឲ្យពួកខ្ញុំគ្រប់ៗគ្នាដែរ ព្រោះខ្លាចពុលដោយគាត់ឃើញមានអ្នកពុលក្អួតចង្អោរជាច្រើននាក់ ។ មួយសន្ទុះក្រោយមក កប៉ាល់ទាំងពីរគ្រឿងបានមកដល់ខេត្តកំពង់ឆ្នាំងនៅរសៀលម៉ោង៣ រួចឈប់សំចតនៅកន្លែងមួយ ហើយឲ្យអ្នកជម្លៀសឡើងគោក ។ អ្នកឡើងទូកគ្រប់គ្នាសម្រាកនៅទីនោះលាយឡំជាមួយអ្នកភូមិផ្សេងទៀត ។ លុះព្រឹកឡើងក៏មានរថយន្តជាច្រើនគ្រឿងបើកបរមក ហើយប្រាប់ឲ្យយកបាយដើម្បីធ្វើដំណើរតទៅទៀត ។ ពេលទទួលបានបាយហើយ អ្នកខ្លះក៏ហូប អ្នកខ្លះក៏ទុក ចំណែកម្តាយខ្ញុំគាត់មិនឲ្យហូបច្រើនទេ ដោយគាត់ពូតបាយឲ្យមួយពំនូតដៃម្នាក់មួយដុំៗប្រាប់ថា ទុកដល់ល្ងាចចាំហូប បើមិនទុកទេល្ងាចនេះយើងច្បាស់ជាអត់បាយ ។ ខ្ញុំហូបហើយក៏យកកូនឆ្នាំងទៅរកដងទឹកមកហូប និងឲ្យគ្រប់ៗគ្នាហូបដែរ ។ នៅម៉ោងពីររសៀល អ្នកបើករថយន្តមានសម្លៀកបំពាក់ខ្មៅដើរមកដេញអ្នកជម្លៀសឲ្យឡើងរថយន្តដោយរថយន្តនីមួយៗដឹកមនុស្សពេញៗធ្វើដំណើរឆ្ពោះទៅទិសខាងជើង ។ បើករយៈពេលប្រហែលជាពីរម៉ោង រថយន្តនេះក៏បត់ទៅខាងលិចដែលជាផ្លូវដីក្រហម ខ្ញុំឃើញមានមានព្រៃទាំងសងខាងផ្លូវលែងឃើញមានភូមិឬវាលដូចកាលពីខ្ញុំចេញពីដំបូងតាមផ្លូវកៅស៊ូនោះទៀតហើយ ។ រថយន្តមួយខ្សែនេះបើកទៅមករហូតដោយមិនឈប់ឲ្យអ្នកជិះចុះបត់ជើងតូច បត់ជើងធំទេ រហូតដល់អ្នកខ្លះទ្រាំមិនបានក៏នោមដាក់ខោ ក្នុងនោះក៏មានខ្ញុំដែរ ។ ក្រោយមក ពេលទៅដល់ទីវាលមួយទើបរថយន្តឈប់ហើយអនុញ្ញាតឲ្យអ្នកជិះចុះទាំងអស់គ្នា មួយសន្ទុះក៏ឲ្យឡើងរថយន្តវិញ ។

## ដល់គោលដៅខេត្តពោធិ៍សាត់

ក្រោយពីចុះពីរថយន្ត មើលផ្លូវដែលបានបត់ពីទិសខាងលិចមកខាងត្បូងនេះជាផ្លូវដីឥដ្ឋមានស្មៅដុះពេញ និងឃើញដានជើងមនុស្សដើរគ្រប់ៗគ្នា ។ ក្រឡេកទៅខាងកើតឃើញតែព្រៃខ្ពស់ៗ និងខាងលិចជាព្រៃរបោះមានសុទ្ធតែដើមត្រែង ។ បន្ទាប់មក គ្រប់គ្នាដើរស្វែងរកកន្លែងសម្រាក និងកន្លែងសម្រាប់ដាំបាយ ។ ចំណែកគ្រួសារខ្ញុំគឺនាំគ្នាហូបបាយស្ងួត ដែលបានត្រៀមទុកពីមុនមក ។ ពេលយប់ងងឹតចូលមកដល់ ម្នាក់ៗរកកន្លែងសម្រាករៀងខ្លួនៗ ។ ប៉ុន្តែយប់នោះគ្មាននរណាម្នាក់គេងលក់ទេ ព្រោះឮតែសំឡេងថ្ងូរឈឺចាប់ ដោយត្រូវសត្វល្អិតទិច ។ ចំណែកគ្រួសាររបស់ខ្ញុំវិញមិនបានគេងនឹងគេដែរ ព្រោះត្រូវរវល់មើលតាខ្ញុំដែលគាត់ឈឺរាគ ។ នៅទីនោះ ក្រុមគ្រួសារខ្ញុំគ្មាននរណាម្នាក់គ្រុន ឬត្រូវសត្វល្អិតទិច ពីព្រោះម្តាយខ្ញុំមានមុងធំៗពីរចងឲ្យពួកខ្ញុំគេង ។

ពេលថ្ងៃរះ ទើបខ្ញុំចេញពីមុង ដោយម្នាក់ៗត្រដាក់ខ្លាំងពេក ព្រោះត្រូវទឹកសន្សើមមានអារម្មណ៍ឈឺចុកក្នុងសាច់ដុំ និងស្ពឹកក្រោកមិនចង់រួច ។ ម្តាយខ្ញុំបានយកមុងនោះហាលថ្ងៃ រួចខ្ញុំទៅរកដងទឹកថ្លុកមកទុកសម្រាប់ប្រើប្រាស់ ។ អ្នក១៧មេសារង់ចាំក្រែងមានអ្នកស្រុកមកទទួល តែរយៈពេលមួយព្រឹករហូតជិតដល់ថ្ងៃត្រង់មិនឃើញមានអ្នកមូលដ្ឋាននរណាម្នាក់មកទេ ។ បន្ទាប់មកម្តាយខ្ញុំបានឲ្យខ្ញុំទៅរកខសជាមួយប្រជាជនផ្សេងទៀតនៅព្រៃដើម្បីធ្វើម្ហូបហូបទាំងអស់គ្នា ។ នៅទីនោះ ខ្ញុំឃើញមានតែដើមក្រូចឃ្វិច ដើមខ្លះងាប់យូរឆ្នាំមកហើយ ឯដើមខ្លះទៀតរុំព័ទ្ធទៅដោយវល្លិ៍ ។ ខ្ញុំក៏ទៅកាប់ដើមក្រូច និងបេះផ្សិតដាក់បាវអង្ករត្រឡប់មកវិញ ។ ប៉ុន្តែម្តាយខ្ញុំបង្គាប់ឲ្យខ្ញុំយកផ្សិតនោះទៅបោះចោល ព្រោះខ្លាចពុល ដូច្នេះគ្រួសារក៏នាំគ្នាហូបបបរជាមួយអំបិលវិញ ។ ដល់រសៀលបន្តិច ខ្ញុំឃើញអ្នកខ្លះពុលផ្សិតនេះដោយចេញឈាមតាមភ្នែក តាមច្រមុះ បន្ទាប់មកក៏ស្លាប់ ដោយខ្ញុំឃើញមនុស្សស្លាប់ច្រើននាក់ណាស់ក្រោយពីហូបផ្សិតនេះ ។

## ភូមិនៅកណ្តាលព្រៃភ្នំរបស់ជនជាតិភាគតិច

ប្រជាជន១៧មេសា ដែលត្រូវដឹកទៅខេត្តពោធិ៍សាត់ គឺឲ្យរស់នៅស្រុកភ្នំក្រវាញ ។ នៅទីនោះ ខ្ញុំឃើញប្រុសមូលដ្ឋានប្រាំនាក់ ក្នុងនោះមានពីរនាក់ស្លៀកខោខ្មៅបុរាណមូលចង្កេះអត់ពាក់អាវ និងបីនាក់ទៀតម្នាក់មានស្នា ការបិតស្លៀតសៀតនៅចង្កេះ និងខ្សែគោមួយចង្វាយ ។ អ្នកទាំងប្រាំនាក់ចែកជាពីរក្រុម មួយក្រុមមានបីនាក់យាមទៅខាងកើត និងពីរនាក់យាមនៅខាងលិចឈានខាងត្បូង ។ គ្រួសារខ្ញុំត្រូវចាត់តាំងឲ្យទៅរស់នៅខាងលិចឈានខាងត្បូងជាមួយអ្នកមូលដ្ឋានប្រហែល៧០០-៨០០នាក់ ។ យើងទាំងអស់គ្នាត្រូវដើរជាខ្សែដ៏វែងកាត់តាមព្រៃត្រែង

នេះ ។ ដោយសារផ្លូវនេះឆ្ងាយ តាខ្ញុំគាត់ដើរលែងរួច ឪពុកនិងបងប្រុសខ្ញុំបានបណ្តូរគ្នាអៀវគាត់ ម្តាយខ្ញុំពរប្អូនតូចដែលទើបចេះដើរ អ្នកនៅសល់ទាំងប៉ុន្មានក្នុងគ្រួសារត្រូវស្ពាយបុទ្ទូលបាវអីវ៉ាន់ដើរឆ្លងកាត់ព្រៃ ។ ក្រោយពីដើរផុតព្រៃនេះ យើងក៏ឃើញផ្ទះតូចៗរបស់ជនជាតិភាគតិចទំហំពីរម៉ែត្របួនជ្រុង និងមានកម្ពស់៣-៤ម៉ែត្រ ឯផ្ទះជនជាតិខ្លះទៀតធ្វើជាប់ដីក្បែរគល់ឈើធំ គ្មានទ្វារទេ ។

រសៀលម៉ោងជិតបី គ្រប់ៗគ្នារកកន្លែងសម្រាករៀងខ្លួន ចំណែកគ្រួសារខ្ញុំក៏រកម្លប់ដើមឈើជ្រកដែរ ។ នៅទីនោះ តាខ្ញុំមានសភាពខ្សោយណាស់ ដោយសារតែមិនអាចទ្រាំនឹងអាកាសធាតុក្នុងព្រៃភ្នំបានទេ ។ ដូច្នេះ ម្តាយខ្ញុំក៏ប្រញាប់យកកងដៃប្តូរទឹនដែលបានមកពីការដោះដូរពីមុនទៅដូរយកបានអង្ករមួយថ្នក់ក្រមាជាមួយសាច់ងៀត និងទឹកមួយបំពង់ឫស្សី ។ បងប្រុសខ្ញុំធ្វើមាន់ម៉ែខ្ញុំដាំបាយឆ្អិន ដួសជូនតាខ្ញុំពិសា ។ ប៉ុន្តែគួរឲ្យសោកស្តាយ គាត់រឹងថ្គាមស្លាប់នៅពេលល្ងាចនោះទៅ បាយនិងសាច់ដែលធ្វើសម្រាប់គាត់ប្រែក្លាយជាបាយសំណែនជូនគាត់ទៅវិញ ។ យប់នោះគ្រួសារខ្ញុំដេកកំដរសពរហូតដល់ភ្លឺ ។ ព្រលឹមឡើង ម្តាយខ្ញុំបានបញ្ចុះសពគាត់នៅក្នុងព្រៃក្បែរភូមិ ។ ខ្ញុំគិតថា យាយនិងតាខ្ញុំមានសំណាង ព្រោះយើងបានបញ្ចុះសពគាត់ត្រឹមត្រូវប្រសើរជាងសពដទៃទៀតដែលត្រូវខ្មែរក្រហមដឹកយកមកបោះចោលក្នុងព្រៃ ហើយត្រូវសត្វឆ្កែចចកស៊ី ។

## ការរស់នៅនិងធ្វើការជាមួយជនជាតិភាគតិច

ការមកដល់របស់អ្នក១៧មេសាក្នុងភូមិជនជាតិព័រ គឺកាន់តែពិបាកជាងការរស់នៅក្នុងភូមិពងទឹក ស្រុកខត្តុង្គទៅទៀតព្រោះគ្មានអង្គការខ្មែរក្រហមចែកអង្ករ ឬពោតទេ ។ អ្នកណាអាចតស៊ូឈ្នះជំងឺក៏អាចរស់រានមានជីវិត អ្នកដែលទន់ខ្សោយក៏ស្លាប់ជាបន្តបន្ទាប់គ្នា ។ នៅក្នុងភូមិនេះដឹកនាំដោយមេកន្ទ្រាញជនជាតិព័រឈ្មោះ ឌាវ ដោយគាត់និយាយភាសាខ្មែររដឹនខ្លាំងណាស់ស្ទើរស្តាប់មិនយល់នូវអ្វីដែលគាត់និយាយ ។ គាត់និងបងប្អូនជនជាតិព័រនេះបានដឹកនាំអ្នក១៧មេសាឲ្យទៅកាប់ព្រៃ រានដីធ្វើស្រែ និងរកមើមឈើមកហូប ។ បន្ទាប់មក គាត់បានគោះត្រដោកកោះហៅអ្នកចំណូលថ្មីទៅប្រជុំថាក្នុងភូមិនេះអ្នកចំណូលថ្មីមិនត្រូវដើរបេះអ្វីផ្តេសផ្តាសតាមចិត្តបានទេ បើឃើញមានស្រូវ ឬដំណាំអ្វីផ្សេងៗត្រូវសុំម្ចាស់គេ ព្រោះមានអ្នកថែរក្សាការពារ ។ ព្ធដូច្នេះឪពុកម្តាយខ្ញុំបានហាមខ្ញុំមិនឲ្យបេះអ្វីផ្តេសផ្តាសទេ ។ ថ្ងៃបន្ទាប់ម្តាយខ្ញុំបានយកមានគ្រឿងមាសរបស់គាត់ទៅដូរយកបានអង្ករត្រី និងសាច់ព្រៃមកធ្វើជាអាហារ ព្រមទាំងស្លឹកទុកប្រក់ផ្ទះដែរ ។ ក្រោយពីមានស្លឹកហើយឪពុកខ្ញុំបាននាំបងប្រុសខ្ញុំទៅកាប់ឫស្សីយកមកធ្វើផ្ទះ ។ ចំណែកគ្រួសារអ្នកចំណូលផ្សេងៗទៀតដែលគ្មានអ្វីដោះដូរបានទៅបេះដំណាំរបស់ជនជាតិនេះស្រាប់តែត្រូវចុកពោះស្លាប់ ឬពស់ចឹកស្លាប់ ។ ជនជាតិនេះមិនសម្លាប់ពស់ទាំងនោះទេ ព្រោះគេថាពស់អ្នកតា ម្យ៉ាងទៀតក្នុងភូមិជាជម្រកមនុស្សផង និងជម្រកសត្វព្រៃផងដែរ ។

ទឹកដីនេះជាតំបន់គ្រុនចាញ់ ក្នុងរយៈពេលពីរ ឬបីថ្ងៃមានមនុស្សស្លាប់ម្នាក់ឬពីរនាក់ហើយ ។ ចំណែកអ្នកផ្សេងទៀត ដោយសារការអត់ឃ្លានក៏បានស្លាប់ជាបន្តបន្ទាប់ដែរ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កាលនោះជារដូវភ្លៀងប្រហែលជាខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំត្រងទឹកសន្សើមបានពីរបំពង់ទុកសម្រាប់ហូប ដូច្នេះទើបបងប្អូនខ្ញុំគ្រប់គ្នាមិនដែលកើតគ្រុនចាញ់ទេក្នុងសម័យខ្មែរក្រហម ។

នៅទីនោះ ខ្ញុំបានទៅរកពងសត្វ ឬរើសផ្លែឈើដែលទុំជ្រុះហើយថែមទាំងកាប់ព្រៃជាមួយគេដែរនៅវួងដំរី ។ ខ្ញុំឃើញនៅសងខាងមាត់អូរមានដើមឈើស៊ីផ្លែដុះចាក់ស្រែះលើគ្នាក្រាស់ឃ្មឹកបង្កើតជាវូងមួយ ។ ផ្លែទាំងនេះមានដើមក្របៅ កកោះ សេមាន់សាវម៉ាវ និងគុយជាដើម ។ ចំណែកបាតអូរឃើញមានត្រីអណ្តែងធំៗ ត្រីក្រាន្ត និងត្រីផ្សេងៗទៀតសម្ងំតាមឫសគល់ឈើ ប៉ុន្តែខ្ញុំឆ្ងល់ណាស់ហេតុអ្វីជនជាតិនេះមិនព្រមហូបត្រីនេះទៅវិញ ។ ប៉ុន្តែក្រោយមកទើបខ្ញុំដឹងថា អ្នក១៧មេសាហូបទៅគឺកើតជំងឺគ្រុនចាញ់ ហើយខ្លះក៏ស្លាប់ ។ កន្លែងនោះមើលទៅគឺជាជ្រលងភ្នំខៀវ ឬភ្នំខ្មោច និងភ្នំផ្សេងៗទៀតបង្កើតបានជាខ្សែទឹកមួយហើយមានប្រភពទឹកធ្លាក់មកពីកំពូលភ្នំខៀវ នៅពេលដែលមានភ្លៀងធ្លាក់នៅតំបន់ភ្នំ ទឹកភ្លៀងហូរចាក់ពីកំពូលភ្នំផ្សេងៗមកជួបគ្នានៅអាងទឹកណាមួយ រួចក៏ហូរធ្លាក់តាមអូរនេះទៅស៊ីងលាចក្នុងខេត្តពោធិ៍សាត់ ។ ខ្ញុំតែងតែទៅរកត្រីម្ញុំទឹកច្រោះខាងលើព្រោះទឹករាក់ត្រឹមកដើង ហើយសម្បូរត្រីណាស់ ឃើញហែលទាំងហ្វូង

យើងគ្រាន់តែយកចុងដើមឫស្សីមានប្រវែងបីម៉ែត្រវាយលើទឹកឲ្យខ្លាំង ត្រីលេញ ត្រីរាល ត្រីប្រវាំ នឹងលោតឡើងលើខ្សាច់ ហើយចាប់បានត្រីដោយងាយ ។ ហើយប្រសិនបើចុះមកអន្លង់ទឹកខាងក្រោមដែលមានចម្ងាយប្រហែល៥០០ម៉ែត្រវិញ គេយកបំពង់ឫស្សីចាស់ៗចោះប្រហោងបាន២-៣កន្លែង រួចយកទៅដោតនៅទឹកជ្រៅជិតកន្លែងរុនទឹកហូរធ្លាក់ឲ្យ៤-៥បំពង់ ប្រាំថ្ងៃក្រោយមក ទៅលើកបំពង់ឫស្សីនោះឡើងគោក ហើយយើងនឹងមានត្រីជ្រួក ឬត្រីកញ្ចុះហូបជាមិនខាន ។

## ប្រពៃណី និងការរស់នៅរបស់ជនជាតិ

ជីវភាពរស់នៅរបស់ជនជាតិព័រប្លែក តែជាការសាមគ្គីល្អណាស់ ព្រោះជារបៀបរស់នៅតាមបែបធម្មជាតិដូចមនុស្សសម័យបុរេប្រវត្តិដែលខ្ញុំបានរៀនមុខវិជ្ជាប្រវត្តិសាស្ត្រ មនុស្សជាតិ ។

*ការចិញ្ចឹមជីវិត* : ប្រុសៗពេលចេញពីផ្ទះតែងតែមានស្នា កាំបិតបន្ទោះ ឬកាំបិតផ្គាក់ និងខ្សែយកទៅជាមួយមិនថាពេលទៅធ្វើចម្ការ ឬទៅកន្លែងណាទេ ។ ហើយពេលទៅណា ជួនកាលគេទៅទាំងគ្រួសារដោយទុកផ្ទះចោល ។ ចំណែកស្រីៗនៅផ្ទះដាំស្ល និងមើលថែកូន ដោយប្រើឆ្នាំងស្ពាន់បូរាណសម្រាប់ដាំស្ល ។ ដល់ពេលឆ្អិន គេលើកបាយចុះ ហើយយកវែកឫស្សីមកដួសបាយដាក់ស្លឹកបរិភោគ ឯសម្លគោកខាប់ៗក៏ដួសដាក់ស្លឹកដូចគ្នា ឬក៏ស្រូបលើបាយ ដោយប្រើម្រាមដៃចាប់បាយហូប រួចអង្គុយតម្រង់ក្បែរភ្នក់ភ្លើងបរិភោគជុំគ្នា ។

*អំពីការស្លៀកពាក់* : ប្រុសៗស្លៀកពាក់ខោថ្ទេរប្រាំមួលចង្កុះ ឬក្រណាត់មួយផ្ទាំងដូចស្លៀកក្រមា រួចចងក្បិន ចំណែកស្រីៗស្លៀកសំពត់ចងពង់ ប្រសិនបើស្ត្រីមានកូនតូចត្រូវស្លៀកសំពត់ជាប់ក រួចទុកឆ្នុកធ្លាក់ដល់ពោះ ហើយដាក់កូនតូចនោះក្នុងថ្នក់សំពត់ ធ្វើដូចនេះកូននោះអាចបៅបោះ ឬដេកដោយស្រួល ហើយម្ដាយក៏អាចធ្វើការងារបានទៀត ។ ក្មេងស្រី និងស្ត្រីក្រមុំស្លៀកពាក់សំពត់ផ្ទាំងព័ទ្ធពីខាងខ្នងមកខាងមុខយកជាយសំពត់ចងភ្ជាប់ហ្នឹងក ឯយាយតាចាស់ៗ និងក្មេងៗស្លៀកពាក់ចងក្បិនគ្រប់គ្នា ហើយប្រុសស្រីមិនពាក់អាវទេ ក្រណាត់សំពត់គឺសុទ្ធតែជាក្រណាត់ខ្មៅ ។

*ការងូតទឹកសម្អាតខ្លួន* : ជនជាតិនេះងូតទឹកជារៀងរាល់ពេលល្ងាច ឬព្រលប់ថ្ងៃរៀបលិច ។ ស្រីៗងូតទឹកមុនប្រុសៗនៅកំពង់ទឹកកន្លែងសម្រាប់ស្រីៗ ។ តាមផ្លូវទៅស្ទឹងគេបេះស្លឹកភ្លា ឬផ្លែឈើព្រៃម្យ៉ាងយកទៅដុសខ្លួនប្រាណនិងញីសក់ ។ ពេលស្រីៗត្រឡប់មកវិញ ប្រុសទៅម្ដងដោយយកបំពង់ឫស្សីមានខ្លី មានវែងបីបួនបំពង់ទៅជាមួយ ។ ហើយពេលត្រឡប់មកវិញ គេដងទឹកមកជាមួយ ។ ពេលចុះងូតទឹកគឺអង្គុយឈរបែរមុខតាមបណ្ដោយទឹកហូរ ពេលឡើងពីទឹកក៏តាមបណ្ដោយទឹកហូរដូចគ្នាដែរ ព្រោះធ្វើបែបនេះដើម្បីការពារការចាញ់ទឹកចាញ់ដី ។ ដូច្នេះហើយ អ្នក១៧មេសាក៏ងូតទឹកតាមរបៀបជនជាតិព័រដែរ ។

*ប្រពៃណីជនជាតិ* : ស្ត្រីជនជាតិព័រពេលឆ្លងទន្លេគឺត្រូវដេកអាំងភ្លើង និងដាំថ្នាំឫសឈើផឹក ពេលគ្រប់ចំនួនថ្ងៃធ្វើពិធីយំសោកព្រោះគេថាកើតមកជាសត្វលោកមានជីវិតគឺមានទុក្ខសោក ។ បើមាននរណាម្នាក់ស្លាប់ គេធ្វើពិធីបុណ្យផឹកស្រាបំពង់ឫស្សីព្រោះគិតថាអស់ជីវិត អស់ទុក្ខសោក ។ ក្រៅពីពិធីនេះ នៅមានធ្វើពិធីឲ្យចាស់ៗជរាឡើងតោងដើមឈើទាបៗក្នុងភូមិមួយឆ្នាំម្ដង ហើយកូនចៅរបស់គេទៅអង្រួនដើមឈើនោះ ។ បើយាយតារបស់គេតោងមិនជាប់ ត្រូវធ្លាក់ ឬរបូតដៃ កូនចៅរបស់គេចាំទ្រ ។ ដល់វេលាដូនតាគេអស់ជីវិតស្លាប់ហើយនោះ គេមិនយំស្រណោះទេ ដើម្បីឲ្យដូនតាកុំនៅអាល័យ រួចយកសាកសពរុំនិងព្រួលឫស្សីតម្កល់ក្នុងផ្ទះដែលគាត់ធ្លាប់រស់នៅ រយៈពេលតែមួយថ្ងៃមួយយប់សាកសពនឹងត្រូវសត្វកណ្ដៀរមកពូន (ស្រុកព្រៃនេះសម្បូរកណ្ដៀរណាស់) ។ ថ្ងៃទីពីរ កណ្ដៀរពូនខ្មោចជិតមើលទៅដូចកប់ដែរ ។ ថ្ងៃទីបីនិងទីបួន ខ្មោចត្រូវកណ្ដៀរពូននឹងក្លាយទៅជាដំបូកមួយ ។

ខ្ញុំឃើញផ្ទះចាស់ៗពុកផុយមានកម្ពស់មួយម៉ែត្រកន្លះ ឬពីរម៉ែត្រជាច្រើនកន្លែងត្រូវកណ្ដៀរពូនក្លាយជាដំបូកសល់តែចុងឫស្សីនិងស្លឹកត្នោត ។ មានដំបូកខ្លះនៅក្បែរផ្ទះជនជាតិ និងមានកូនឈើដុះអែបធំតូច ។

*ក្រមុំកម្លោះ* : ពេលកូនពេញក្រមុំកម្លោះ ជាពិសេសកូនក្រមុំតែម្ដង ឪពុកម្ដាយកូនក្រមុំបានធ្វើផ្ទះឲ្យកូនក្រមុំរបស់ខ្លួនរស់នៅដោយឡែកពីឪពុកម្ដាយ ដើម្បីទុកឱកាសឲ្យកម្លោះៗទៅចង

មិត្តភាព ឬចងសម្ព័ន្ធមេត្រី ។ កម្លោះៗអាចទៅរស់នៅជាមួយក្រុមុំជាសង្សារ ឬប្តីប្រពន្ធដោយរៀបការជឿ ។ ក្រោយពេលបានគ្នាជាប្តីប្រពន្ធហើយ ទើបគេរៀបសែនព្រេនតាមក្រោយក៏បាន ។ ប្តីប្រពន្ធជនជាតិខ្លះមានកូនមួយទៅពីរនាក់ទើបសែនព្រេនតាមក្រោយគឺធ្វើទៅតាមលទ្ធភាពមានក្របី (កាប់ក្របីដឹកស្រាសែនព្រេនអាពាហ៍ពិពាហ៍) ។

អំពីភាសា : ជនជាតិព័រនិយាយភាសារបស់គេ ។ ជនជាតិនេះនិយាយភាសាខ្មែរកណ្តាលចំៗត្រូវតាមតួអក្សរ ស្តាប់ទៅរដឹនខ្លាំងណាស់ ។ ពេលនិយាយជាមួយគ្នា ជនជាតិព័រនិយាយភាសារបស់គាត់ តែពេលនិយាយជាមួយអ្នក១៧មេសា និយាយភាសាខ្មែរកណ្តាល ។ នៅទីនេះក៏មានជនជាតិព័រខ្សែស្រឡាយចិនសម្បុរសជ្រះដូចកូនចិនកាត់ខ្មែរដែរ ។ ជនជាតិនេះមិនចេះធ្វើស្តុកគ្នោតប្តុនំទេ ។ ពេលខ្លះទៀត ខ្ញុំក៏បានទៅជួយបុកស្រូវឲ្យជនជាតិព័រដែរ ។

## ការជម្លៀសទៅឃុំលាជ

រយៈពេលប្រាំបីខែ ដែលអ្នក១៧មេសាបានរស់នៅភូមិកំពង់ដីរ ស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់ជាមួយជនជាតិព័រ អ្នក១៧មេសាជាច្រើនបានស្លាប់ដោយសារជំងឺផ្សេងៗ ជាពិសេសជំងឺគ្រុនចាញ់និងបាក់កម្លាំងដោយការអត់ឃ្លាននៅរស់ប្រហែលជាង២០០នាក់ប៉ុណ្ណោះ ប៉ុន្តែបងប្អូននិងឪពុកម្តាយក្នុងគ្រួសាររបស់ខ្ញុំមិនមាននរណាម្នាក់ស្លាប់ទេ ។ ក្រោយពីពិធីចាស់ជរាជនជាតិព័រឡើងគោងដើមឈើមក អ្នកមូលដ្ឋាន (មិនមែនជនជាតិព័រ) បានមកប្រមូលអ្នក១៧មេសាឲ្យទៅធ្វើស្រែនៅឃុំលាជវិញ ។ លើកនេះសម្ភារគ្រប់យ៉ាងដែលនៅសល់បន្តិចបន្តួចត្រូវបានហាមឃាត់មិនអនុញ្ញាតឲ្យយកតាមខ្លួនទេ ព្រោះនេះជាការជម្រុះកម្មសិទ្ធិផ្ទាល់ខ្លួនឲ្យអស់ និងជម្រះសតិអារម្មណ៍ឲ្យបានស្អាតស្អំ ។

អ្នក១៧មេសាត្រូវបានអនុញ្ញាតឲ្យយកតែខោអាវប៉ុណ្ណោះ ។ ព្រឹកនោះ គ្រួសារខ្ញុំនិងគ្រួសារអ្នក១៧មេសាត្រូវបង្ខិតចិត្តទុកចានឆ្នាំងចោលទាំងអស់ ហើយដើរតាមផ្លូវត្រឡប់មកកាន់ចម្ការក្រូចវិញ ។ ខ្ញុំស្ទើរចំណាំផ្លូវនេះមិនបាន ព្រោះវាលស្មៅនៅទីនេះក្រៀមឃើញតែដីបែកក្រហែង ។ គេនាំអ្នក១៧មេសាដើរទៅខាងជើងផ្លូវនេះបានមួយស្របក់ទើបចូលដល់ដីក្រហមហើយក៏បត់ទៅខាងកើតនៃផ្លូវដីក្រហមនេះ ។ មួយសន្ទុះក្រោយមកយើងក៏មកដល់ភូមិរបស់អ្នកមូលដ្ឋាន ។ យើងឃើញនៅខាងលិចផ្លូវមានសុទ្ធតែផ្ទះធ្វើពីដើមឫស្សី និងប្រក់ដំបូលស្លឹកដូចៗគ្នាដែលផ្ទះមួយខណ្ឌចែកជាពីរបន្ទប់ ប៉ុន្តែអត់មានមនុស្សរស់នៅទេ ។ ផ្ទះទាំងនេះទំនងធ្លាប់មានមនុស្សនៅពីមុនហើយ ព្រោះមានសំណល់ចានឆ្នាំងបែក ។

បន្ទាប់មក អ្នកមូលដ្ឋានបានប្រាប់ឲ្យយើងចាំទៅបរិភោគបាយនៅឯរោងបាយរួមមួយនៅកណ្តាលភូមិ ។ នៅថ្ងៃនោះខ្ញុំអត់បានហូបអាហារថ្ងៃត្រង់ទេ ។ ខ្ញុំនិងមនុស្សគ្រប់ៗគ្នាដែលមកពីភូមិក្នុងព្រៃបាននាំគ្នាទៅមើលរោងបាយរួមនោះ ។ ពេលទៅដល់រោងបាយនោះ ទើបយើងដឹងថា នៅខាងជើងភូមិនេះគេទុកឲ្យអ្នក១៧មេសារស់នៅ ដោយមានការដ្ឋានរោងបាយ និងសួនបន្លែ ។ ចំណែកឯនៅខាងចុងភូមិ ឃើញមានផ្ទះដូចគ្នានឹងខាងជើងភូមិដែរ ។ ភូមិនេះមានអ្នក១៧មេសារស់នៅពីមុនដែរ ពីព្រោះខ្ញុំបានឃើញមនុស្សចាស់ៗ និងក្មេងតូចៗនៅលើផ្ទះខ្លះដែរ ។ ប៉ុន្តែផ្ទះដទៃទៀតមិនមានឃើញមនុស្សម្នាក់ទេ ។ ផ្ទះទាំងអស់នេះមានច្រកផ្លូវចូលតាមទិសខាងកើតផង និងខាងលិចផង ។ ខាងចុងភូមិមានផ្ទះច្រើនជាងគេ ហើយមានអណ្តូងទឹកមួយនៅខាងកើតផ្លូវទល់មុខរោងបាយ ។ នៅក្នុងរោងបាយមានតុវែងចែកជាពីរជួរ កៅអីវែងៗ អមសងខាងតុនីមួយៗ ។ ផ្ទះបាយមានប្រវែងសាមសិបម៉ែត្រចែកជាពីកំណាត់ ដោយមួយកំណាត់ជាចង្ក្រានបាយ មួយកំណាត់ទៀតជាតុបាយដែលនៅលើតុមានបាយដែលគេដួសដាក់ចានចង្កឹះចាក់ផ្កាប់លើចានរៀបជាជួររួចជាស្រេច ប៉ុន្តែមិនទាន់ឃើញម្ហូបនៅឡើយទេ ។ អ្នកមូលដ្ឋានដែលបាននាំយើងមកទីនេះបានប្រាប់យើងឲ្យមកហូបបាយទាំងអស់គ្នា ។ បន្ទាប់មកអង្គការបានប្រាប់ថា ចាំប្រជុំចប់សិន ទើបរៀបចំឲ្យក្មេងៗអង្គុយជាជួរ ប្រុសៗមួយកន្លែង ស្រីមួយកន្លែង ចាស់ៗក៏អ៊ីចឹងដែរ គឺអង្គុយចោងហោងតាមជួររៀងៗខ្លួន ។ អ្នកមូលដ្ឋានទាំងអស់នេះមានទឹកមុខមាំ ដូចចងគំនុំជាមួយអ្នក១៧មេសាខ្លាំងណាស់ ។

**(នៅមានត)**

**ឡៃ ហួត**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

edIm,Iyut iFm nigkarcgcaM

EdlCamUld and sMxan;kæœgkarpSHpSaCat

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬥ Preah Sihanouk Blvd ⬥ Phnom Penh ⬥ Cambodia ⬥ Tel: (855) 23 211 875 ⬥ Fax: (855) 23 210 358 ⬥ dccam@online.com.kh ⬥ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ⬥ Number 140, August 2011 ⬥ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.